**សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# អំពើលួចក្នុងក្រមព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែ មីនា ឆ្នាំ ២០២២ ដល់ថ្ងៃទី២៣ ខែ ឧសភា ឆ្នាំ ២០២២

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ប៊ី អ៊ីម៉ី**
**ប៉េង ពូទីន**

សាស្ត្រាចារ្យណែនាំ
**មីន សំអុល**

បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២២

ឆ្នាំចូលរៀន ២០១៨
ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំកញ្ញា **ប៊ី អ៊ុម៉ី** និង លោក **ប៉េង ពូទីន** ជានិស្សិតបរិញ្ញាបត្រនីតិសាស្រ្តជំនាន់ទី ២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។ សូមថ្លែងនូវការគោរពដឹងគុណយ៉ាងក្រៃលែងជូនចំពោះ លោកឪពុកអ្នកម្តាយរបស់យើងខ្ញុំ ដែលលោកបានចិញ្ចឹមបីបាច់ថែរក្សាដល់កូន ដោយក្តីអាណិត ស្រឡាញ់ មេត្តា ករុណា ខិតខំប្រឹងប្រែងតស៊ូធ្វើការ ជំនះគ្រប់បញ្ហាលំបាកដើម្បីផ្គត់ផ្គង់ដល់កូន និងបង្រៀនកូនឲ្យក្លាយជាមនុស្សល្អ។គ្រប់ដំបូន្មាន និងការអប់រំប្រដៅរបស់អ្នកមានគុណទាំងពីរណែនាំកូនៗឱ្យ ក្លាយជាសិស្សល្អ កូនល្អ ពលរដ្ឋល្អ មិនតែប៉ុណ្ណោះគឺលោកទាំងពីរបានឧបត្ថម្ភជាច្រើន និងតែងតែជួយជាកម្លាំងចិត្ត ធ្វើឱ្យកូនជំនះខំរៀនតាំងពីថ្នាក់បឋមសិក្សារហូតដល់រូបពួកកូនបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តប្រកបដោយភាពជោគជ័យ។

ទន្ទឹមនេះផងដែរ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។ ម្យ៉ាងវិញទៀត យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យទាំងអស់ដែលបានខិតខំបង្ហាត់បង្ហាញ និងផ្តល់ជាចំណេះដឹងឱ្យយើងខ្ញុំ ទើបយើងខ្ញុំអាចសរសេរសារណាប្រកបដោយជោគជ័យនេះបាន។ ជាងនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកគ្រូសាស្រ្តាចារ្យ **មីន សំអុល** ជាសាស្រ្តាចារ្យណែនាំ ដែលបានជួយផ្តល់មតិយោបល់ កែតម្រូវ និងជំរុញធ្វើឱ្យកិច្ចការសារណានេះទទួលបានជោគជ័យ។

ចុងបញ្ចប់នេះ យើងខ្ញុំសូមបួងសួងដល់វត្ថុសក្តិសិទ្ធទាំងឡាយ ក្នុងព្រះរាជាណាចក្រកម្ពុជា ជួយប្រសិទ្ធិពរជ័យជូនដល់អ្នកមានគុណទាំងទ្វេ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្រ្តាចារ្យសិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ ជួបតែនឹងសេចក្តីសុខ សេចក្តីចម្រើន នៅក្នុងជីវិតតរៀងទៅ ព្រមទាំងជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

នៅក្នុងបរិបទសង្គមបច្ចុប្បន្ន សិទ្ធិសេរីភាពបានបើកទូលាយខ្លាំងណាស់សម្រាប់មនុស្សទូទៅ។ នៅក្នុងកាលៈទេសៈ ដែលសង្គមផ្ដល់នូវភាពអនុគ្រោះបែបនេះ ក៏មានបុគ្គលមួយចំនួនឆ្លៀតប្រើសិទ្ធិ និងសេរីភាពខ្លួនដោយបំពានហួសកំរិតព្រំដែន នាំឱ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃ ក៏ដូចជាបង្កើតឱ្យមាននូវបញ្ហាដល់សណ្ដាប់ធ្នាប់នៃសាធារណៈ។ ដើម្បីបង្ការនូវអធិករណ៍ទាំងនេះ អ្នកច្បាប់ក៏ដូចជាថ្នាក់ដឹកនាំប្រទេស បានរៀបចំចងក្រងបង្កើតឱ្យមានច្បាប់ ដែលជាគតិយុត្តបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការធ្វើនូវនិយ័តកម្មក្នុងសង្គមទាំងផ្នែកច្បាប់សារធាតុ និងច្បាប់នីតិវិធី។

ទោះបីជាច្បាប់ បានបង្កើតមកជារឿយៗក្ដី និងមានការអនុវត្តយ៉ាងតឹងរ៉ឹងក្ដី ក៏គង់តែមានអ្នកដែលមិនខ្លាចរអាផងដែរ ហើយថែមទាំងរកវិធីសាស្ត្រប្រព្រឹត្តផ្ទុយច្បាប់ ទាំងចន្លោះច្បាប់ និងទទឹងច្បាប់។ ប្រការទាំងនេះក៏ជាហេតុផងដែរ ដែលនាំឱ្យច្បាប់ត្រូវវិវត្តជារឿយៗ ពីដំណាក់កាលមួយទៅដំណាក់កាលមួយ ដើម្បីឱ្យទាន់កាលសម័យ។

ដើម្បីលើកកម្ពស់នីតិវិស័យ ឱ្យកាន់តែប្រសើរ និងតបតាមតម្រូវការក្នុងការគ្រប់គ្រង រក្សាសណ្ដាប់ធ្នាប់ក្នុងសង្គមនោះ ការសិក្សាពីទង្វើដែលទុច្ចរិតបំពានច្បាប់ ក៏ដូចជាបណ្ដាទង្វើដែលជាមហន្តរាយដល់របៀបរៀបរយសង្គមជាកិច្ចដ៏សំខាន់គួរគប្បីនឹងធ្វើផងដែរ។ នៅក្នុងអត្ថបទសារណានេះ នឹងធ្វើការដកយកទង្វើទុច្ចរិតមួយប្រភេទ ដែលជាបទល្មើសព្រហ្មទណ្ឌប៉ះពាល់ដល់ទ្រព្យសម្បត្តិមកធ្វើការបកស្រាយ។ ដូចនេះ ការសិក្សាស្រាវជ្រាវនេះ នឹងធ្វើការវែកញែកលើប្រធានបទ ***អំពើលួចក្នុងក្រមព្រហ្មទណ្ឌ*** ដើម្បីជាប្រយោជន៍សម្រាប់អ្នកសិក្សា និងសាធារណជនទូទៅ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**អំពើលួចក្នុងក្រមព្រហ្មទណ្ឌ**

**១. សញ្ញាណទូទៅនៃបទល្មើសលួចក្នុងនីតិជាតិខ្មែរ** ........ ៣

១.១. និយមន័យ ........ ៣

១.១.១. តាមវចនានុក្រមខ្មែរ ........ ៣

១.១.២. តាមវាក្យសព្ទគតិយុត្ត ........ ៣

១.២. ទស្សនទាននីតិប្បវត្តិលើអំពើលួច ........ ៣

**២. អំពើលួច** ........ ៥

២.១. ធាតុផ្សំនៃអំពើលួច ........ ៦

២.១.១. ធាតុនីត្យានុកូល ........ ៦

២.១.២. ធាតុសត្យានុម័ត ........ ៦

២.១.២.១. អំពើដកហូតដោយទុច្ចរិត ........ ៧

ក. និយមន័យនៃការដកហូតដោយទុច្ចរិត ........ ៧

ក.១. បម្លាស់ទីវត្ថុ ឬទ្រព្យសម្បត្តិ ........ ៧

ក.២. ទុច្ចរិតភាពនៃបម្លាស់ទី ........ ៧

ក.៣. អវត្តមាននៃការប្រគល់ ឬលះបង់ ........ ៨

ខ. រូបភាពនៃការដកហូតដោយទុច្ចរិត ........ ៨

ខ.១.ការដកហូតមានលក្ខណៈទុច្ចរិតដោយផ្ទាល់ ........ ៨

ខ.២. ការដកហូតមានលក្ខណៈទុច្ចរិតដោយប្រយោល ........ ៩

២.១.២.២. ស្ថានភាពនៃទ្រព្យសម្បត្តិ ឬវត្ថុ ដែលត្រូវបានលួច ........ ៩

ក. ទ្រព្យសម្បត្តិ ឬវត្ថុ របស់អ្នកដទៃ ........ ៩

ខ. លក្ខណៈនៃទ្រព្យសម្បត្តិ ឬវត្ថុ ........ ១០

ខ.១. ទម្រង់រូបី ........ ១២

ខ.១.១. ទ្រព្យសម្បត្តិ ឬវត្ថុរូបីសាមញ្ញ ........ ១២

ខ.១.២. ទ្រព្យសម្បត្តិ ឬវត្ថុរូបីពិសេស ........ ១៣

ខ.២. ទម្រង់អរូបី ........ ១៣

២.១.២.៣. មធ្យោបាយនៃការប្រព្រឹត្តអំពើលួច ........ ១៤

២.១.៣. ធាតុអត្តនោម័ត ........ ១៥

២.១.៣.១. កំហុសក្នុងអំពើលួច ........ ១៦

ក. ចេតនាទុច្ចរិតទូទៅ ........ ១៦

ខ.ចេតនាទុច្ចរិតពិសេស ........ ១៦
គ.ចេតនាទុច្ចរិតច្បាស់លាស់ និងចេតនាទុច្ចរិតមិនច្បាស់លាស់ ........ ១៧
ឃ. ចេតនាទុច្ចរិតចំពោះ និងចេតនាទុច្ចរិតមិនចំពោះ ........ ១៧
២.១.៣.២. គំនិតផ្តួចផ្តើមក្នុងការប្រព្រឹត្តអំពើលួច........ ១៨
ក. កត្តាចារីផ្ទាល់........ ១៨
ក.១. ករណី ដែលចារីត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ........ ១៨
ក.២. ករណី ដែលចារីមិនទទួលខុសត្រូវព្រហ្មទណ្ឌ ........ ១៩
ខ. កត្តាខាងក្រៅ........ ១៩
ខ.១. ករណី ដែលចារីត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ........ ២០
ខ.២. ករណី ដែលចារីមិនទទួលខុសត្រូវព្រហ្មទណ្ឌ ........ ២០
ខ.២.១. ការប្រព្រឹត្តក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ........ ២០
ខ.២.២. ការប្រព្រឹត្តក្រោមស្ថានភាពចាំបាច់........ ២១
២.១.៣.៣. កម្មវត្ថុនៃអំពើលួច ........ ២២
ក. តាមទស្សនៈទី១........ ២២
ខ. តាមទស្សនៈទី២........ ២២
២.២. ទោស និង អញ្ញត្រកម្មនៃទោស ........ ២២
២.២.១. ទោស........ ២៣
២.២.១.១. មូលទោស ........ ២៣
ក. អំពើលួច ដែលជាបទមជ្ឈិម ........ ២៣
ក.១. អំពើលួចទ្រព្យសម្បត្តិសាមញ្ញ ........ ២៣
ក.២. អំពើលួចទ្រព្យសម្បត្តិ ឬវត្ថុបើពិសេស........ ២៣
ខ. អំពើលួច ដែលជាបទឧក្រិដ្ឋ........ ២៣
ខ.១. អំពើលួចដោយមានការប្រព្រឹត្តអំពើហិង្សា ........ ២៤
ខ.២. អំពើលួចដោយមានការកាត់អវយវៈ ឬពិការភាព ........ ២៥
ខ.៣. អំពើលួចដោយមានការធ្វើទារុណកម្ម ឬអំពើឃោរឃៅ........ ២៦
ខ.៤. អំពើលួចក្នុងស្ថានភាព ដែលជនរងគ្រោះបាត់បង់ជីវិត ........ ២៧
២.២.១.២. ទោសបន្ថែម........ ២៧
ក.ទោសបន្ថែមចំពោះអំពើលួចទ្រព្យសម្បត្តិ ឬវត្ថុសាមញ្ញ........ ២៧
ខ. ទោសបន្ថែមចំពោះអំពើលួចបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា........ ២៩
២.២.២. អញ្ញត្រកម្មនៃទោស........ ២៩

**ជំពូកទី២**

**បទល្មើស ដែលស្រដៀងទៅនឹងអំពើលួចក្នុងក្រមព្រហ្មទណ្ឌ**

**១. បទល្មើសលួចក្នុងបញ្ញត្តិច្បាប់ផ្សេងទៀត**........ ៣១
១.១. ការលួចទ្រព្យសម្បត្តិវប្បធម៌........ ៣១

១.២. ការលួចទាក់ទងនឹងអចលនវត្ថុ ..................................................................... ៣៤
១.៣. ការលួចស្នាដៃ ..................................................................... ៣៤
**២. បទល្មើសប្រហាក់ប្រហែល និងបទល្មើស ដែលត្រូវបានប្រដូចទៅនឹងអំពើលួច** .......... ៣៧
២.១. បទល្មើសប្រហាក់ប្រហែលទៅនឹងអំពើលួច ..................................................................... ៣៧
២.១.១. ការកំហែងយក ..................................................................... ៣៧
២.១.២. ការគំរាមកំហែងហែកកេរ្តិ៍ ..................................................................... ៣៨
២.២. បទល្មើស ដែលត្រូវបានប្រដូចទៅនឹងអំពើលួច ..................................................................... ៣៩
២.២.១. ការឆបោក ..................................................................... ៤០
២.២.២. ការរំលោភលើទំនុកចិត្ត ..................................................................... ៤០
២.២.៣. ការទទួលផលចោរកម្ម ..................................................................... ៤១
**សេចក្តីសន្និដ្ឋាន** ..................................................................... ៤៣
**អនុសាសន៍** ..................................................................... ៤៤
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## លំនាំបញ្ហា

អំពើលួច គឺជាអំពើទុច្ចរិត ដែលប៉ះពាល់ដល់កម្មសិទ្ធិរបស់បុគ្គលណាមួយ ហើយអំពើនេះ ត្រូវបានរបបសេរីនិយមចាត់ទុកថាជាទង្វើ ដែលមានចរិតគ្រោះថ្នាក់ និងបំពានដល់សិទ្ធិអ្នកដទៃ ព្រោះរបបនេះ មានការការពារយ៉ាងជិតដល់ចំពោះសេរីភាព ក៏ដូចជាស្វ័យភាព នៃសិទ្ធិកម្មសិទ្ធិ។ គួយ៉ាងផ្អែកតាមស្មារតីនៃ**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣** មាត្រា៤៤ បានចែងថា *ជនណាក៏ដោយទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។*[1] *កម្មសិទ្ធិឯកជនស្របច្បាប់ស្ថិតនៅក្រោមការគាំពារនៃច្បាប់។*[2] *ដែលនឹងដកហូត កម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើក្នុងករណី ដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌។*[3] មានន័យថា មិនថាបុគ្គលនោះជារូបវន្តបុគ្គល ឬនីតិបុគ្គលនោះទេ រដ្ឋធម្មនុញ្ញកម្ពុជាបានទទួលស្គាល់នូវកម្មសិទ្ធិភាពនៃបុគ្គលទាំងនោះលើកម្មសិទ្ធិឯកជនរបស់ពួកគេ។ ប៉ុន្តែ សម្រាប់កម្មសិទ្ធិ ដែលកម្មវត្ថុនៃកម្មសិទ្ធិនោះ ជាប្រភេទអចលនវត្ថុ ដូចជា ដីធ្លី ជាអាទិ៍ កម្មសិទ្ធិករ ដាច់ខាត ត្រូវតែជាបុគ្គល ដែលមានសញ្ជាតិខ្មែរ។ ទ្រព្យសម្បត្តិឯកជនទាំងនេះ ត្រូវបានច្បាប់ការពារ បញ្ចៀសនូវការរំលោភដកហូតដោយទុច្ចរិត។ ប៉ុន្តែក្នុងករណីការដកហូតធ្វើឡើងដោយស្របច្បាប់ ដើម្បីប្រយោជន៍នៃសាធារណៈនោះ ការដកហូតកម្មសិទ្ធិឯកជនអាចធ្វើទៅបាន។[4]

ការការពារនេះ ធ្វើឱ្យប្រជាពលរដ្ឋ មានលទ្ធភាពគ្រប់គ្រាន់ក្នុង ការប្រើប្រាស់សិទ្ធិជាម្ចាស់លើទ្រព្យបានពេញលេញ និងសុវត្ថិភាព ដែលជាហេតុញុំាងឱ្យចរន្តសេដ្ឋកិច្ចមានភាពរីកចម្រើនទូលំទូលាយ។ ទន្ទឹមនឹងមានការកំណត់អំពីសិទ្ធិតាមរយៈស្មារតីនៃរដ្ឋធម្មនុញ្ញ ក៏តម្រូវឱ្យមាននូវបញ្ញត្តិ ដែលមានចរិតចាប់បង្ខំ ដើម្បីធានាឱ្យការការពារកាន់តែមានប្រសិទ្ធភាព ក៏ដូចជាការពារការរំលោភបំពាន ដោយការដកហូតដោយទុច្ចរិត ពោលគឺអំពើលួចជាដើម ហើយបញ្ញត្តិចាប់បង្ខំនេះដែរ ក៏ត្រូវមានព្រំដែនកំណត់ឱ្យច្បាស់លាស់ទៀតផង។

បញ្ញត្តិ ដែលមានភារកិច្ចចាត់ការ ក៏ដូចជាអនុវត្តនូវស្មារតីនៃរដ្ឋធម្មនុញ្ញខាងលើឱ្យបានពេញលេញនោះគឺ ច្បាប់ព្រហ្មទណ្ឌ ជាពិសេសក្រមព្រហ្មទណ្ឌ ព្រមទាំងមានការបំពេញបន្ថែមដោយច្បាប់ពិសេសផ្សេងៗទៀត។ នៅក្នុង**ក្រមព្រហ្មទណ្ឌ** ដែលប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ **គន្ថីទី ៣** បានកំណត់អំពី**បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ** ហើយ**មាតិកាទី១**នៃគន្ថីនេះ បានពន្លេចពី **ការយកទ្រព្យសម្បត្តិអ្នកដទៃមក**

---

[1] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ បោះពុម្ពឆ្នាំ ២០១៧ ដោយ អគ្គលេខាធិការដ្ឋានរដ្ឋសភា ទំព័រ ១៩ មាត្រា ៤៤ កថាខណ្ឌទី១។

[2] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ បោះពុម្ពឆ្នាំ ២០១៧ ដោយ អគ្គលេខាធិការដ្ឋានរដ្ឋសភា ទំព័រ ២០ មាត្រា ៤៤ កថាខណ្ឌទី២។

[3] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ បោះពុម្ពឆ្នាំ ២០១៧ ដោយ អគ្គលេខាធិការដ្ឋានរដ្ឋសភា ទំព័រ ២០ មាត្រា ៤៤ កថាខណ្ឌទី៣។

[4] សូមមើលច្បាប់ស្តីពីអស្សាមិករណ៍ ដែលប្រកាសឱ្យប្រើដោយប្រមុខរដ្ឋស្តីទី សម្តេច ជា ស៊ីម ក្នុងព្រះបរមនាមនៃព្រះ មហាក្សត្រខ្មែរ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០។

**ធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយទុច្ចរិត**។ ក្រៅពី**ក្រមព្រហ្មទណ្ឌ** ក៏មានច្បាប់ផ្សេងទៀត ដូចជា **ច្បាប់ភូមិបាល** ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ កាលពីថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ ក៏បានបញ្ញត្តទាក់ទងនឹងការលួច ដែលកម្មវត្ថុជាអចលនទ្រព្យផងដែរ។

**ចំណោទបញ្ហា**

**តើអំពើលួច ត្រូវបានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ កំណត់ និងផ្តន្ទាទោសយ៉ាងណា?**

**គោលបំណងនៃការស្រាវជ្រាវ**

ដើម្បីឆ្លើយតបនឹងចំណោទបញ្ហាខាងលើនេះ ការស្រាវជ្រាវបានចាប់ផ្តើមឡើងក្រោមគោលបំណងសិក្សាពីបទល្មើស ដែលកើតចេញពីអំពើលួច ធាតុផ្សំនៃបទល្មើស ការផ្តន្ទាទោស ក៏ដូចជាបទល្មើសប្រហាក់ប្រហែលនានាដែលមានថែង ដើម្បីអាចយល់ពីការកំណត់របស់នីតិនិពន្ធខ្មែរជុំវិញបញ្ហានេះ។

**ទំហំស្រាវជ្រាវ**

ហេតុតែបញ្ហានេះមានវិសាលភាពទូលាយ យើងនឹងលើកយកតែបទល្មើសនៃអំពើលួច ដែលត្រូវបានបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ប៉ុណ្ណោះ ដើម្បីវិភាគវែកញែក និងសិក្សាលំអិត។ ប៉ុន្តែអំពើលួច ដែលបានបញ្ញត្តក្នុងច្បាប់ពិសេសផ្សេងទៀត ក៏ត្រូវបានរំលេចផងដែរក្នុងស្រាវជ្រាវនេះ ដើម្បីជាបច្ច័យទាននៃគំនិតសិក្សា។

**សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ**

ការស្រាវជ្រាវនេះនឹងផ្តល់នូវគុណប្រយោជន៍ដល់និស្សិត អ្នកច្បាប់ ក៏ដូចជាសាធារណជនទូទៅ បានដឹងពី អំពើលួច ធាតុផ្សំនៃបទល្មើសលួច និងការផ្តន្ទាទោស។ ជាងនេះទៀត ការស្រាវជ្រាវនេះ ក៏រួមចំណែក កសាងសង្គមឆ្ពោះទៅរកនីតិរដ្ឋ តាមរយៈការផ្សព្វផ្សាយច្បាប់ និងលើកកម្ពស់ការយល់ដឹងអំពីច្បាប់ផងដែរ។

**វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ**

ដើម្បីសិក្សាស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំបានស្វែងរកឯកសារពីប្រភពនានា រួមមានច្បាប់ និងបទដ្ឋានគតិយុត្តនានា ក៏ដូចជាសៀវភៅ និងមេរៀន ដែលមានបោះពុម្ពផ្សាយជាសាធារណៈ។ គំនិត និងពត៌មាននានា ដែលមាននៅក្នុងអត្ថបទស្រាវជ្រាវសារណានេះគឺផ្អែកតាមការប្រមូលពីប្រភពឯកសារ ដែលបានលើកឡើងខាងលើនេះ។ ដោយឆ្លងកាត់ការជ្រើរើស និងវិភាគ ព្រមទាំងពិភាក្សាជាមួយដៃគូសារណា ទិន្នន័យ ពត៌មាន និងសំយោគកម្មនៃគំនិត ដែលប្រមូលបានពីប្រភពឯកសារទាំងនេះ ត្រូវបានយកមករៀបចំ និងលៃលកបញ្ចូលក្នុងអត្ថបទស្រាវជ្រាវ ដែលញ៉ាំងឱ្យសារណាមួយនេះលេចចេញជារូបរាងមក។

**រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**

ក្នុងប្រធានបទនេះដែរ យើងនឹងបែងចែកជំពូកសិក្សាជា**២**ធំៗ គឺ**ជំពូកទី១** នឹងសិក្សាទាក់ទងជាមួយ **អំពើលួចក្នុងក្រមព្រហ្មទណ្ឌ** និងជំពូក**ទី២** នឹងបកស្រាយទាក់ទងអំពី **បទល្មើស ដែលស្រដៀងទៅនឹងអំពើលួចក្នុងក្រមព្រហ្មទណ្ឌ**។

# ជំពូកទី១

# អំពើលួចក្នុងក្រមព្រហ្មទណ្ឌ

## ១. សញ្ញាណទូទៅនៃបទល្មើសលួចក្នុងនីតិជាតិខ្មែរ

### ១.១ និយមន័យ

#### ១.១.១. តាមវចនានុក្រមខ្មែរ

**លួច** កិ. លបយកអ្វីមួយរបស់អ្នកដទៃ ដែលគេមិនឱ្យដោយថេយ្យចិត្ត[5]: លួចទ្រព្យគេ។ លួចគំនិត លបធ្វើតាមគំនិតគេ ឬលបបំបាត់គំនិត ដែលគេបង្គាប់ ធ្វើតាមគំនិតខ្លួនឯងវិញ។ លួចចិត្ត ក្បត់ចិត្ត។ លួចចំណេះ លបយកចំណេះដោយមិនបាច់រៀនផ្ទាល់ពីគេ។ លួចឈ្មោះ លបសរសេរចុះឈ្មោះគេ ឬលបយកឈ្មោះគេទៅថ្លែង។ លួចប្ដីគេ ឬលួចប្រពន្ធគេ លបធ្វើអំពើស្មន់អន្ទករជាមួយនឹងប្ដី ឬ ប្រពន្ធគេ។ លួចភេទ ក្លែងភេទធ្វើជាអ្នកបួសខ្លួនឯង។ លួចលាក់ លបលាក់។ លួចល្បាក់ លបធ្វើក្នុងពេល ឬក្នុងស្របក់ ដែលគេប្រហែសធ្វេស។ លួចល្បិច លបយកល្បិចគេ។ លួចសព លបយកសពក្នុងវេលាយប់ស្ងាត់ពីក្នុងទីសាមញ្ញ មកតម្កល់ក្នុងទីដ៏រុងរឿង ដើម្បីនឹងដង្ហែឱ្យគគ្រឹកគគ្រេង។ លួចសំវាស ក្លែងធ្វើជាភិក្ខុ រួមសំវាសជាមួយនឹងភិក្ខុសង្ឃ។ល។[6]

#### ១.១.២. តាមវាក្យសព្ទគតិយុត្ត

ដោយពិនិត្យទៅលើនិយមន័យនៃពាក្យ **លួច** ក្នុងវាក្យសព្ទសាមញ្ញ គឺមានន័យទូលំ ទូលាយជាខ្លាំង រហូតតម្រូវឱ្យអ្នកច្បាប់ត្រូវកំណត់នូវព្រំដែននៃពាក្យ លួច សម្រាប់ប្រើក្នុងយុត្តាធិការច្បាប់ព្រហ្មទណ្ឌដោយឡែកមួយផ្សេងទៀត។ **ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ មាត្រា៣៥៣** បានឱ្យ**និយមន័យនៃអំពើលួច**ថា ***គឺជាអំពើដកហូតដោយ ទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោល បំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។***[7] ជាងនេះទៅទៀត **មាត្រា៣៥៤** នៃច្បាប់ដដែល ក៏បន្ថែមនូវចំណុចមួយទៀត ដែលត្រូវសន្មតថាជាអំពើលួចផងដែរ ដូចមានកំណត់ថា ***ត្រូវចាត់ទុកជាអំពើលួច អំពើប្រើប្រាស់ដោយទុច្ចរិតនូវថាមពល ដែលនាំឱ្យខូចប្រយោជន៍អ្នកដទៃ។***[8]

### ១.២. ទស្សនទាននីតិប្បវត្តិលើអំពើលួច[9]

---

[5] ថេយ្យចិត្ត ន. ចិត្ត ដែលប្រកបដោយការលួច។ សទ្ទានុក្រមព្រះពុទ្ធសាសនា រៀបរៀង និងប្រែ ដោយ ស៊ឹម រតនៈ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ គ.ស. ២០១៣ ទំព័រ ១៥៨។

[6] វចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ គ.ស. ១៩៦៧ ទំព័រ ៨២៩។

[7] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ១១៦ មាត្រា ៣៥៣។

[8] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ១១៦ មាត្រា ៣៥៤។

[9] សេចក្ដីព្រាងក្រមព្រហ្មទណ្ឌថ្មី វិភាគទានចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ បោះពុម្ពផ្សាយ ឆ្នាំ ២០០៥ ទំព័រ២៩៨ ដល់ ទំព័រ៣០០ មាត្រា កម ៣១១១-១ និយមន័យនៃការលួច អត្ថបទយោង: ប្រភពប្រវត្តិសាស្ត្រកម្ពុជា។

នៅក្នុងនីតិខ្មែរពីបុរាណកាល សម្មតិកម្មទាំងឡាយនៃការលួចមានចំនួនជាច្រើន ហើយហាក់ដូចជា ពុំមាននិយមន័យ ដែលត្រូវបានចងក្រងឡើងដោយជាក់លាក់នោះទេ។ ជាលទ្ធផល មាត្រានីមួយៗ បញ្ជាក់តាមរបៀបជាច្រើន នូវសញ្ញាណនៃកម្មសិទ្ធិរបស់អ្នកដទៃ។ ដូច្នេះ មាត្រា ១៧ នៃព្រហ្មទណ្ឌ សំដែងថា «ជនណាបានលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ» មាត្រា ១ នៃក្រមអាជ្ញាមញ្ញាបាតុភាស លើកឡើងពី «ការលួចទ្រព្យសម្បត្តិរបស់ព្រះមហាក្សត្រ»។ មានបរិប្រយោគ (សេចក្តីពង្វាង) ជាច្រើនផ្សេងទៀត ដែលត្រូវបានគេប្រើប្រាស់ដូចជា «វត្ថុដែលគេបានលួចពីអ្នកដទៃ» ក៏ដូចជានៅក្នុងមាត្រា២៣ នៃក្រមអាជ្ញាហ្លួង «លួចទ្រព្យសម្បត្តិប្រពន្ធ កូន របស់អ្នកស្រុក»។ នៅក្នុងបណ្តាសម្មតិកម្មទាំងអស់នេះ កម្មសិទ្ធិនៃទ្រព្យសម្បត្តិរបស់អ្នកដទៃត្រូវបានចង្អុលបង្ហាញដោយជាក់លាក់តិច ឬច្រើន ប៉ុន្តែកម្មសិទ្ធិនេះពុំបានបង្កឱ្យមានមន្ទិលសង្ស័យឡើយ។ **អាដេម៉ាឡឺក្លែរ ក្រមកម្ពុជា ភាគទី ២**។

នីតិនិពន្ធខ្មែរបានប្រកាន់យកនូវសម្មតិកម្មជាច្រើននៃការលួច ដែលត្រូវបានប្រព្រឹត្តនៅក្នុងកាលៈទេសៈពិសេសមួយចំនួន ហើយប្រព្រឹត្តទៅតាមលក្ខណៈសម្បត្តិរបស់ចោរ ដូចជា: ការលួចប្រព្រឹត្ត ដោយអ្នកបួស ការលួចប្រព្រឹត្តដោយមានការទម្លុះទម្លាយ ការលួចរវាងទាហាន ការលួចក្នុងពេលមានអគ្គីភ័យ ការលួចដោយប្រើហិង្សា ឬការលួចដំរី របស់ព្រះមហាក្សត្រ។

ក្រមពហុលទេព ដែលប្រកាសឱ្យប្រើនៅឆ្នាំ ១៦២២ បានបញ្ញត្ត នូវការលួចជាច្រើន ប្រភេទ ដោយគិតទាំងកាលៈទេសៈពិសេសជាច្រើនទៀត ដែលបានកើតឡើងមុន ដំណាលគ្នា ឬបន្ទាប់ពីសកម្មភាពទាំងនោះ។ **អាដេម៉ាឡឺក្លែរ** បានសាកល្បងធ្វើចំណាត់ថ្នាក់លើការលួចទាំងនេះ ដែលបានចែងទុកដោយ នីតិនិពន្ធខ្មែរពីបុរាណកាល ដោយចែកចេញជាប្រាំជំពូកធំៗគឺ: ការលួចដោយទោសៈ និង ដោយការសងសឹក ការលួចធម្មតា ការលួចនៅតាមផ្លូវធំៗ ឬ នៅលើផ្លូវសាធារណៈ ការលួចដោយបន្ថែមនូវស្ថានទម្ងន់ទោស និងការរំលោភលើទំនុកចិត្តរវាងបងប្អូន។ ម៉្យាងទៀត លោក **ឡឺក្លែរ** បានស្នើសុំធ្វើការពន្យល់ដ៏គួរឱ្យចាប់អារម្មណ៍យ៉ាងខ្លាំងមួយលើការវិវត្ត និងការស្វែងយល់នូវសិទ្ធិលើកម្មសិទ្ធិនៅកម្ពុជា: លោកបានបង្ហាញថា ចៅក្រមខ្មែរទាំងអស់នៅក្នុងសម័យអាណាព្យាបាលបានភ្ជាប់នូវលក្ខណៈពិសិដ្ឋ ចំពោះកម្មសិទ្ធិឯកត្តបុគ្គល។ លោកបានទាញអំណះអំណាងចេញពីការណ៍ដែលថា នីតិនិពន្ធដាក់ ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរខ្លាំងណាស់ចំពោះការលួច ដែលប្រព្រឹត្តឡើងដោយមានស្មារតីសងសឹក ឬដោយទោសៈ ដែលបង្កឱ្យវិនាសដល់ទ្រព្យសម្បត្តិ បើប្រៀបធៀបទៅនឹងការលួច ដែលបញ្ចប់ត្រឹមតែការយកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដោយទុច្ចរិតប៉ុណ្ណោះ។

**អាដេម៉ាឡឺក្លែរ** បានសាកល្បងស្វែងយល់ និងវិភាគឆន្ទៈរបស់នីតិនិពន្ធខ្មែរពីបុរាណកាលមានការលួច «នៅពេលដែលមានអំពើដកហូត ទោះជាចោរមានការសំអាងហេតុអ្វីក៏ដោយ ទោះជាបំណងដែលស្វែងរក ឬសម្រេចដោយចោរជាអ្វីក៏ដោយ ទោះជាចោរបាន ឬមិនបានរក្សាឱ្យប្រើប្រាស់ បំផ្លាញ បាត់បង់វត្ថុ ដែលដកហូតនោះក៏ដោយ។ ជនណា ដែលបានយកពីអ្នកដទៃ នូវរបស់ដែលមិនមែនជាកម្មសិទ្ធិនៃខ្លួនបានប្រព្រឹត្តនូវការលួច ទោះជាជននោះបានទទួលប្រយោជន៍ ឬមិនបានទទួលពីវត្ថុនោះក៏ដោយ។ នេះគឺច្បាស់លាស់ និងជាក់លាក់»។ នៅចំណុចនេះ

គេត្រូវគូសបញ្ជាក់ថា ច្បាប់ខ្មែរដាក់ទណ្ឌកម្មលើការលួចវត្ថុដែលត្រូវបានលួចរួចម្តងហើយ ហើយការលួចនោះត្រូវបានប្រព្រឹត្តឡើងទៅជា ព្យសនកម្មដល់ចោរម្នាក់ ដោយចោរម្នាក់ទៀត។ **អាដេម៉ាឡឺក្លែរ ក្រមកម្ពុជា ទំព័រ ៤៥៣ និងបន្ទាប់។**

**ក្រមនៅឆ្នាំ១៩២៨ និង១៩៥៥** បានតាំងបទប្បញ្ញត្តិអំពីការលួចនៅត្រង់**មាត្រា ៥២៥** នៃក្រមទាំងនោះ។ ដូច្នេះការលួច ត្រូវបានឱ្យនិយមន័យថា ជាអំពើនៃការដណ្តើមយក ដោយគ្មានសិទ្ធិ និងដោយទុច្ចរិត «នូវរបស់អ្វីៗដែលមិនមែនជាកម្មសិទ្ធិរបស់ខ្លួន»។ លើសពីនេះទៅទៀត មាត្រានេះបានប្រមូលផ្តុំ ការលួច ការរំលោភលើទំនុកចិត្ត និងការឆបោក ទៅក្នុងប្រភេទនៃបទល្មើសទាំងឡាយដែលត្រូវនិគ្រោះ[10]ដោយទោសដូចគ្នា ហើយដែល បានសម្រេចលទ្ធផលដូចគ្នា ពោលគឺការប៉ះពាល់ដល់កម្មសិទ្ធិអ្នកដទៃ។[11] នៅក្នុង**ក្រមឆ្នាំ ១៩២៨ ជំពូកដែលមានមាត្រា៥១៥** មានចំណងជើងថា **«បទល្មើស ប្រឆាំងទៅលើទ្រព្យសម្បត្តិរបស់បុគ្គលឯកជន»**។ **ក្រមនៅឆ្នាំ១៩៥៥** បានកែប្រែដោយស្រាលៗ នូវចំណងជើងថា **«បទល្មើសប្រឆាំងទៅនឹងភោគទ្រព្យរបស់បុគ្គលឯកជន»** ហើយបានបញ្ចូល វាក្យខណ្ឌទី៤មួយទៀត ដែលបញ្ញត្តអំពីការលួចលក់ ឬការលួចបញ្ចាំអចលនវត្ថុ មានន័យថា អំពើរបស់បុគ្គលម្នាក់ដែលបង្ហាញនូវ «អចលនវត្ថុមួយថាជារបស់ខ្លួន ហើយដែលខ្លួនដឹងថាមិនមែនជាកម្មសិទ្ធិរបស់ខ្លួន ឬក៏បង្ហាញថាអចលនវត្ថុមួយដែលទំនេរ និងរួចផុតពីសិទ្ធិភណ្ឌិកគ្រប់ប្រភេទ ហើយដែលខ្លួនដឹងថា អចលនវត្ថុនេះមានជាប់បន្ទុកផ្សេងៗ ឬមានជាប់ប្រាតិភោគភណ្ឌិក»។ លើសពីនេះទៅទៀត **មាត្រា២១៦ នៃក្រមឆ្នាំ១៩៥៥** បានចែងអំពីការលួចពិសេសមួយគឺការលួចទ្រព្យសម្បត្តិសាសនា ដោយបានឱ្យនិយមន័យនិគ្រោះចំពោះការលួចនេះដូចគ្នាទៅនឹងការលួចនៃនីតិរួមដែរ។

**បទប្បញ្ញត្តិអន្តរកាល**ទាំងឡាយ នៅក្នុងសម័យអ៊ុនតាក់បានចែងទុកនៅក្នុង**មាត្រា ៣៤**[12] នូវបញ្ញត្តិស្តីពីការលួចដោយមានស្ថានទម្ងន់ទោស ដែលមានចរិតលក្ខណៈគតិយុត្ត ជាបទឧក្រិដ្ឋ និងនៅក្នុង **មាត្រា៤៣** ស្តីពីការលួចធម្មតា[13]។

## ២. អំពើលួច

អំពើលួច ត្រូវបានកំណត់ក្នុង**ក្រមព្រហ្មទណ្ឌ**យ៉ាងច្បាស់ត្រង់ **ផ្នែកទី១ ការលួច នៃជំពូកទី១ ការលួច និងបទល្មើសប្រហាក់ប្រហែល ក្នុងមាតិកាទី១ ការយកទ្រព្យសម្បត្តិ អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយទុច្ចរិត** របស់**គន្ថីទី៣ បទល្មើសប្រឆាំងទ្រព្យសម្បត្តិ** ចាប់ពីមាត្រា **៣៥៣** រហូតដល់មាត្រា **៣៦២** និងនៅក្នុងមាត្រា **៥០៩** នៃ

[10] និគ្រោះ មានន័យថា ការបង្ក្រាប , repression réprimer ។ តុលាការនិគ្រោះ គឺតុលាការ ដែលមានភារៈខាងអនុវត្តទោស tribunal repressif ។ ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមព្រហ្មទណ្ឌ របស់ អេង សុត គ.ស.១៩៦៤ សទ្ទានុក្រម ទំព័រ ៣៤៥។

[11] សូមមើល ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមព្រហ្មទណ្ឌ របស់ អេង សុត គ.ស.១៩៦៤ ទំព័រ២៩១ ដល់ ២៩៣ មាត្រា៥១៥។

[12] សូមមើល មគ្គុទ្ទេសក៍ ស្តីពីនីតិវិធីព្រហ្មទណ្ឌខ្មែរ ការស៊ើបអង្កេត និងការស៊ើបសួរត្រៀម បោះផ្សាយ ឆ្នាំ២០០៥ ទំព័រ ៥៥ មាត្រា ៣៤។

[13] សូមមើល មគ្គុទ្ទេសក៍ ស្តីពីនីតិវិធីព្រហ្មទណ្ឌខ្មែរ ការស៊ើបអង្កេត និងការស៊ើបសួរត្រៀម បោះផ្សាយ ឆ្នាំ២០០៥ ទំព័រ ៥៨ មាត្រា ៤៣។

**ផ្នែកទី១ បទល្មើសប៉ះពាល់ដល់ព្រះពុទ្ធសាសនា ជំពូកទី៥ ការប៉ះពាល់ដល់សាសនារបស់រដ្ឋ ក្នុង គន្លឹទី៤ បទល្មើសប្រឆាំងនឹងជាតិ។**[14]

## ២.១. ធាតុផ្សំនៃអំពើលួច

តាមគោលការណ៍នៃនីតិព្រហ្មទណ្ឌ ដើម្បីចាត់ទុកថាអំពើណាមួយជាបទល្មើសបានតម្រូវឱ្យមានការបំពេញនូវធាតុផ្សំទាំងបីធំៗ គឺ **ធាតុនីត្យានុកូល** ឬ**ធាតុច្បាប់**, **ធាតុសត្យានុម័ត** ឬ**ធាតុសម្ភារៈ**, និង **ធាតុអត្តនោម័ត** ឬ**ធាតុផ្លូវចិត្ត** យ៉ាងដាច់ខាត ពោលគឺក្នុងបណ្ដាធាតុផ្សំទាំង ៣ នេះ បើមានបាត់វត្តមាននូវធាតុណាមួយនោះ គេពុំអាចចោទប្រកាន់នូវបទល្មើសព្រហ្មទណ្ឌនោះបានឡើយ។[15] ធាតុផ្សំទាំង៣នេះ ត្រូវបាននីតិនិពន្ធ បញ្ចូល និងបន្សំ ទៅក្នុងការចងក្រងនូវមាត្រាស្ដីពីបទល្មើសព្រហ្មទណ្ឌទាំងពួង ដែលធ្វើឱ្យពាក្យពេចន៍ទាំងឡាយនៅក្នុងមាត្រាច្បាប់ទាំងនោះ អាចឱ្យយើងទាញយកមក និងបំបែកវាជាធាតុទាំង៣បាន។ដូចច្នេះ ការសិក្សាលើអំពើលួចនេះ ក៏ធ្វើឡើងតាមរបៀបវែកញែកនូវធាតុទាំង៣នេះដូចគ្នា។

### ២.១.១. ធាតុនីត្យានុកូល

ដូចបានអធិប្បាយនៅខាងលើនេះរួចហើយថា អំពើលួច ត្រូវបាន**ច្បាប់ព្រហ្មទណ្ឌ**ចែងកំណត់យ៉ាងច្បាស់ក្នុង**មាត្រា ៣៥៣** រហូតដល់ **មាត្រា ៣៦២** និងនៅក្នុង**មាត្រា ៥០៩** ផងដែរ។[16] ការចែងកំណត់ដោយច្បាប់ ដែលមាននីត្យានុកូលានុភាព[17] ក្នុងពេលបច្ចុប្បន្ននេះ បានផ្ដល់ឱ្យអំពើលួច នូវគតិយុត្តភាព ដែលអាចអនុវត្តក្នុងគោលការណ៍នៃនីតិវិជ្ជមានលើវិស័យព្រហ្មទណ្ឌ ហើយដែលនេះក៏ជាធាតុផ្សំនីត្យានុកូលនៃបទល្មើសលួចនេះផងដែរ។

### ២.១.២. ធាតុសត្យានុម័ត

**ធាតុសត្យានុម័ត** ឬហៅថាជា**ធាតុសម្ភារៈ**គឺជាអំពើ ឬដំណើរនៃការប្រព្រឹត្តបទល្មើស ដែលស្ដែងចេញមកខាងក្រៅរបស់ចារី ឬអាចកំណត់ថាជាធាតុនៃបទល្មើសជ ដែលយើងអាចមើលឃើញខាងក្រៅបាន។ ធាតុនេះជាធាតុផ្សំមួយ ដែលបង្កើតឱ្យមានជាភស្តុតាង ជាប្រយោជន៍ក្នុងការដាក់បន្ទុក។ ជាងនេះទៀត ធាតុនេះក៏ជាធាតុមួយដែលជាបច្ច័យជួយញ៉ាំងឱ្យគេអាចកំណត់បាននូវធាតុខាងក្នុង ដែលយើងស្គាល់បានថាជា**ធាតុអត្តនោម័ត** នោះផងដែរ។ ដើម្បីអាចបំពេញនូវធាតុសត្យានុម័តនេះ គឺតម្រូវឱ្យបំពេញនូវធាតុសំខាន់តូចៗ ៣ ទៀតគឺ ១.**ហេតុ** គឺហេតុដែលនាំឱ្យមានព្យសនកម្មគឺជាបទល្មើស, ២.**ព្យសនកម្ម** គឺផលវិបាកនានាដែលកើតមានដោយសារបទល្មើស, និង៣.**ទំនាក់ទំនងហេតុ និងផល** គឺតម្រូវឱ្យបទល្មើសជាហេតុដែលនាំឱ្យមានព្យសនកម្ម ហើយព្យសនកម្ម ដាច់ខាតជា

[14] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ១១៦ ដល់ ១១៨ មាត្រា ៣៥៣ ដល់ មាត្រា ៣៦២ និងទំព័រ ១៦៩ មាត្រា ៥០៩។

[15] https://www.pheakdeylaw.com/kh/publication/45 ។

[16] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ១១៦ ដល់ ១១៨ មាត្រា ៣៥៣ ដល់ មាត្រា ៣៦២ និងទំព័រ ១៦៩ មាត្រា ៥០៩។

[17] នីត្យានុកូលានុភាព (នីត្យានុកូល+អានុភាព) មានន័យថា អានុភាពដែលកើតចេញមកពីច្បាប់ ឬដែលច្បាប់គាត់តែង។

វិបាកដែលកើតមានដោយសារបទល្មើសនោះ។ ធាតុតូចៗទាំង ៣ នេះ បើមានអវត្តមាននូវធាតុណាមួយ នាំឱ្យធាតុសត្យានុម័តពុំបំពេញឡើយ ហើយនាំឱ្យបទល្មើសខ្វះធាតុផ្សំ ពុំអាចចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌនោះបានឡើយ។ [18]

បើយើងពិនិត្យទៅលើមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ យើងអាចសិក្សាដោយលម្អិតលើធាតុផ្សំសត្យានុម័តនៃអំពើលួចនេះជាចំណុចៗ ដូចមានអធិប្បាយតទៅនេះ។

### ២.១.២.១. អំពើដកហូតដោយទុច្ចរិត

#### ក. និយមន័យនៃការដកហូតដោយទុច្ចរិត

តាមការឱ្យនិយមន័យ នៃវាក្យសព្ទសាមញ្ញ **ដកហូត** បានមកពីពាក្យ ដក ផ្សំនឹង ពាក្យ ហូត។ **ដក** មានន័យថា ធ្វើឱ្យរដក, ធ្វើឱ្យឃ្លាតចេញ, ធ្វើឱ្យផុត។[19] ឯពាក្យ **ហូត** បាន សេចក្តីថា ទាញដកយកឱ្យរបូតចេញពីក្នុងទីដែលធ្លុះ។[20] ហេតុដូច្នេះ សាមញ្ញន័យនៃពាក្យ **ដកហូតដោយទុច្ចរិត** មានន័យថា ការដកយកអ្វីមួយឱ្យឃ្លាតចាកអំពីទីដែលរបស់នោះតាំងនៅ ហើយដែលសកម្មភាពដកយកនេះប្រព្រឹត្តឡើងដោយទុច្ចរិត។

ដោយឡែកនៅក្នុងវិស័យនីតិសាស្ត្រ **ការដកហូតដោយទុច្ចរិត** ត្រូវបានឱ្យនូវន័យ យ៉ាងលម្អិតដោយឡែកបន្ថែមពីនេះទៀត។ **ដកហូតដោយទុច្ចរិត** នីតិសាស្ត្របានសម្តៅ ដល់ការធ្វើឱ្យមានបម្លាស់ទីនៃវត្ថុ ឬទ្រព្យសម្បត្តិ ពីម្ចាស់របស់ដោយទុច្ចរិត ហើយម្ចាស់របស់នោះពុំបានប្រគល់ ឬលះបង់នូវទ្រព្យសម្បត្តិនោះទេ។ ន័យនេះ ជាសំយោគកម្មចេញអំពីសេចក្តីបកស្រាយនៅខាងក្រោម។ ហេតុនេះ ការបកស្រាយលម្អិតនឹងមានដូចខាងក្រោមតទៅ។

#### ក.១. បម្លាស់ទីវត្ថុ ឬទ្រព្យសម្បត្តិ

បម្លាស់ទីវត្ថុ ឬទ្រព្យសម្បត្តិ គឺជាសកម្មភាពជាសច្ចានុម័ត ដែលញ៉ាំងឱ្យទ្រព្យសម្បត្តិ ឬវត្ថុនោះផ្លាស់ទី ដូចជាការយកលុយចេញពីហោប៉ៅខោរបស់ជនរងគ្រោះជាដើម។[21]

#### ក.២. ទុច្ចរិតភាពនៃបម្លាស់ទី

ការធ្វើឱ្យផ្លាស់ទីនោះ ជាទង្វើទុច្ចរិត ពោលគឺមានន័យថា ជនល្មើសបានធ្វើឱ្យទ្រព្យ ឬវត្ថុផ្លាស់ទីចេញពីម្ចាស់ទាំងដែលខ្លួនគ្មានសិទ្ធិ ឬគ្មាននីតិសម្បទា[22] ក្នុងការធ្វើនូវសកម្មភាពនោះ។ ដូចនេះ បើសិនណាជាការដកហូត(ការធ្វើឱ្យផ្លាស់ទីនូវវត្ថុ ឬទ្រព្យសម្បត្តិនោះ) ជាការ**ដកហូតដោយសុចរិត** ដូចជា អ្នកយាមបានផ្លាស់ម៉ូតូពីទីតាំងដែលម្ចាស់ម៉ូតូ

---

[18] https://www.pheakdeylaw.com/kh/publication/45 ។

[19] វចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ គ.ស. ១៩៦៧ ទំព័រ ២២២។

[20] វចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ គ.ស. ១៩៦៧ ទំព័រ ១១៥០។

[21] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១៣-២០១៤ ១០.អំពើលួច។

[22] នីតិសម្បទា មានន័យថា :

-សមត្ថភាព ដែលច្បាប់បានបើកឱ្យជនម្នាក់ៗ ធ្វើកិច្ចអ្វីមួយ។

-លក្ខណៈនៃបុគ្គល ដែលអាចធ្វើអ្វីមួយបាន។

-សិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់។ (សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកក្រមព្រហ្មទណ្ឌ បោះពុម្ព ផ្សាយដោយ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ ទំព័រ១៧ លេខ៦០)។

បានចត ដើម្បីយកទៅទុកនៅកន្លែងត្រឹមត្រូវ ឬការរឹបអូសនូវទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃបទល្មើសព្រហ្មទណ្ឌ ដែលអនុវត្តដោយមន្ត្រីមានសមត្ថកិច្ច[23] ឬការអនុវត្តដោយបង្ខំដោយ អាជ្ញាសាលា[24] ជាអាទិ៍ ពុំអាចជាការដកហូត ដែលជាធាតុផ្សំនៃអំពើលួចឡើយ។

**ក.៣. អវត្តមាននៃការប្រគល់ ឬលះបង់**

អវត្តមាននៃការប្រគល់ ឬលះបង់ពីសំណាក់ម្ចាស់ទ្រព្យ ឬវត្ថុ មានន័យថា ការដកហូត ដែលជាសត្យានុម័តកម្ម[25]នៃអំពើលួច គឺបានសម្តៅផងដែរទៅលើការមិនយល់ព្រមរបស់ជនរងគ្រោះ ក្នុងការលះបង់ ឬប្រគល់នូវវត្ថុ ឬទ្រព្យសម្បត្តិនោះទៅឱ្យជនល្មើស ពោលគឺជនរងគ្រោះ មិនបានប្រគល់ឱ្យជនល្មើសនូវវត្ថុ ឬទ្រព្យសម្បត្តិរបស់ខ្លួនទេ ហើយថែមទាំងមិនមានឆន្ទៈក្នុងការប្រគល់ទៀតផង។[26] ឧទាហរណ៍ ជនរងគ្រោះ មិនបានប្រគល់ និងមិនមានឆន្ទៈក្នុងការប្រគល់លុយទៅឱ្យជនល្មើសទេ តែជនល្មើសទៅលួចយកលុយពីកាបូបជនរងគ្រោះមក។ ផ្ទុយមកវិញ ក្នុងករណីដែលទ្រព្យសម្បត្តិ ឬវត្ថុនោះ ផ្លាស់ទីចេញពីម្ចាស់ ដោយការប្រគល់របស់ម្ចាស់នោះ ដោយមានឆន្ទៈចង់ឱ្យទ្រព្យបានដល់ជនល្មើស ពុំមែនជាការដកហូតក្នុងអំពើលួចឡើយ។ ដូចជាក្នុងករណីដែល ម្ចាស់ប្រាក់ បានផ្ញើប្រាក់ច្រលំទៅឱ្យបុគ្គលម្នាក់ ហើយនៅពេលគាត់ដឹងថាផ្ញើប្រាក់ទៅច្រលំគណនី គាត់ក៏បានទាមទារឱ្យបុគ្គលនោះសងប្រាក់មកគាត់វិញ តែបុគ្គលនោះពុំព្រមសង។ នៅក្នុងបញ្ហានេះ ពុំមែនជាសកម្មភាពសត្យានុម័តនៃការដកហូតក្នុងអំពើលួចទេ ព្រោះថាទ្រព្យត្រូវបានផ្ញើ ចេញទៅឱ្យ(ប្រគល់ទៅឱ្យ)បុគ្គលម្នាក់ទៀតនោះ ដោយម្ចាស់ទ្រព្យផ្ទាល់ ហើយគាត់ក៏មានឆន្ទៈចង់ឱ្យទ្រព្យនោះបានដល់បុគ្គលនោះដែរ ប៉ុន្តែឆន្ទៈរបស់គាត់មានវិការៈ ដោយសារការ ភ័ន្តច្រឡំ។ ដោយករណីនេះមិនមែនជារឿងព្រហ្មទណ្ឌ ច្បាប់ស៊ីវិលក៏បានផ្តល់មកឱ្យនូវការសង្គ្រោះក្នុងករណីនេះផងដែរ គឺតាមរយៈបទប្បញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ[27]។

**ខ. រូបភាពនៃការដកហូតដោយទុច្ចរិត**

ការដកហូតដោយទុច្ចរិត អាចធ្វើទៅបានតាមពីរវិធីគឺ **ការដកហូតមានលក្ខណៈទុច្ចរិតដោយផ្ទាល់** និង**ការដកហូតមានលក្ខណៈទុច្ចរិតដោយប្រយោល**។

**ខ.១.ការដកហូតមានលក្ខណៈទុច្ចរិតដោយផ្ទាល់**

---

[23] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ១៧ មាត្រា ៦២។

[24] សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១២ ទំព័រ ១៥៨ ដល់ ១៦០ មាត្រា ៣៨៤ មាត្រា ៣៨៥ និងទំព័រ ២៣២ ដល់ ២៣៤ មាត្រា ៥២៤ មាត្រា ៥២៥។

[25] សត្យានុម័តកម្ម (សត្យានុម័ត+កម្ម) មានន័យថា អំពើសត្យានុម័ត។

[26] សូមមើលនីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១៣-២០១៤ ១០.អំពើលួច។

[27] សូមមើលបទប្បញ្ញត្តិ ដែលទាក់ទងនឹងសេចក្តីចម្រើនដោយឥតហេតុ ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១២ ទំព័រ ២៦០ ដល់ ២៦២។

**ការដកហូតមានលក្ខណៈទុច្ចរិតដោយផ្ទាល់** គឺការណ៍ដែលជនល្មើសបានធ្វើឱ្យវត្ថុ ឬទ្រព្យសម្បត្តិនោះផ្លាស់ទីចេញពីទីកន្លែង ឬស្ថានភាពដែលទ្រព្យនោះ ស្ថិតនៅជាប្រក្រតី តាមរយៈអំពើទុច្ចរិតដោយផ្ទាល់របស់ជនល្មើសនោះក្នុងស្ថានភាពអវត្តមាននូវការប្រគល់ ឬ ការលះបង់។

**ឧទាហរណ៍១.** ចោរម្នាក់ បានទៅលួចយកកង់ពីបុរសម្នាក់ដែលកំពុងបណ្តើរកង់លេង តាមសួន ។ ក្នុងករណីបែបនេះ ចោរនោះជាអ្នកដកហូតដោយផ្ទាល់នូវកង់របស់បុរស ដែលជាម្ចាស់កង់ដោយទុច្ចរិត ពោលគឺចោរនោះគាត់បានដឹងច្បាស់ថាកង់នោះមិនមែនជារបស់ខ្លួន ហើយម្ចាស់កង់ក៏ពុំបានប្រគល់ ឬ លះបង់កង់នោះមកឱ្យខ្លួន(ចោរ)ទេ តែខ្លួន(ចោរ) នៅតែលួចយកកង់នោះចេញពីម្ចាស់កង់ទៀត។

**ឧទាហរណ៍២.** បុរស ក បានជ្រុះចិញ្ចៀននៅតាមផ្លូវ ហើយត្រូវបុរស ខ រើសបានតែពេល ក ទៅទារចិញ្ចៀននោះពី ខ វិញ ខ បែរជាមិនឱ្យ។ ក្នុងករណីនេះ ខ បានផ្លាស់ទីវត្ថុដែលមិនមែនជារបស់ខ្លួន ពីកន្លែងដែលវត្ថុនោះស្ថិតនៅទាំងដែលម្ចាស់គេពុំប្រគល់វត្ថុនោះឱ្យខ្លួន ព្រមទាំងបដិសេធមិនប្រគល់ចិញ្ចៀននោះទៅឱ្យម្ចាស់គេវិញទៀត ដែលនេះបានបញ្ជាក់ថាទង្វើរបស់ ខ មិនមែនជាការរើសវត្ថុបាត់ទេ តែជាការចង់យកវត្ថុបាត់នោះមក ជារបស់ខ្លួនដោយទុច្ចរិត។ ទង្វើរបស់បុរស ខ នៅក្នុងករណីយ៉ាងនេះ គឺជាអំពើលួច។

### ខ.២. ការដកហូតមានលក្ខណៈទុច្ចរិតដោយប្រយោល

**ការដកហូតមានលក្ខណៈទុច្ចរិតដោយប្រយោល** គឺពេលខ្លះពាក្យថាអំពើដកហូត ដោយទុច្ចរិតនេះ មិនសំដៅទៅលើការធ្វើឱ្យមានការផ្លាស់ទីតាំងវត្ថុដោយជនល្មើសទេ។[28]

**ឧទាហរណ៍** បុរស **ក** បានអះអាងថាខ្លួនជាម្ចាស់កង់ ដែលគេដាក់ចោលនៅលើផ្លូវ ហើយលក់កង់នោះទៅឱ្យបុរស **ខ** ដែលនឹងយកកង់ចេញពីកន្លែងដើមរបស់វា។ ក្នុងសម្មតិកម្មនេះ គេអាចចោទ **ក** ពីបទលួចបាន។[29]

### ២.១.២.២. ស្ថានភាពនៃទ្រព្យសម្បត្តិ ឬវត្ថុ ដែលត្រូវបានលួច

### ក. ទ្រព្យសម្បត្តិ ឬវត្ថុ របស់អ្នកដទៃ

ទ្រព្យសម្បត្តិ ឬវត្ថុ ដែលជាកម្មវត្ថុនៃអំពើលួច គឺតម្រូវទាល់តែទ្រព្យសម្បត្តិ ឬវត្ថុនោះ ជារបស់ដែលមានម្ចាស់ ឬមានភាពជាម្ចាស់(សិទ្ធិកម្មសិទ្ធិ) ជាប់នៅលើរបស់នោះ។

ទ្រព្យសម្បត្តិ ឬវត្ថុនោះ អាចជាទ្រព្យសម្បត្តិ ឬវត្ថុរបស់បុគ្គលឯកជន និងអាចជាប្រភេទទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។

ក្នុងបញ្ហាពាក្យពេចន៍នេះ ភាពមានម្ចាស់ ឬមានភាពជាម្ចាស់ភ្ជាប់ជាមួយ មិនចាំបាច់ទាល់តែម្ចាស់នោះស្ថិតនៅជាមួយទ្រព្យនោះទេ ពោលគឺទោះបីជាម្ចាស់មិននៅជាមួយ ទ្រព្យសម្បត្តិ ឬវត្ថុនោះក៏ដោយ ឱ្យតែទ្រព្យសម្បត្តិ ឬវត្ថុ

[28] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១៣-២០១៤ ១០.អំពើលួច។
[29] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១៣-២០១៤ ១០.អំពើលួច។

នោះស្ថិតក្នុងភាពជាទ្រព្យសម្បត្តិ ឬវត្ថុ ដែលមានម្ចាស់ ការដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុប្រភេទនោះ គឺជាអំពើលួចនៃបទល្មើសព្រហ្មទណ្ឌ។

**ឧទាហរណ៍** នាយ **ក** បានលួចយកម៉ូតូ ដែលគេចតចោលនៅក្បែររបងផ្ទះ។ ករណីនេះ ទោះបីជាម្ចាស់ម៉ូតូមិននៅជាមួយម៉ូតូក៏ដោយ តែម៉ូតូនោះជាទ្រព្យសម្បត្តិ ឬជាចលនវត្ថុ ដែលមានម្ចាស់ត្រឹមត្រូវ។ ហេតុដូច្នេះ ការដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិប្រភេទនោះ គឺជាសកម្មនៃអំពើលួច។

ទន្ទឹមនេះដែរ គេអាចទាញបានថា ការលួចទ្រព្យសម្បត្តិរបស់ខ្លួនឯង មិនមែនជាការលួចទេ។ **ឧទាហរណ៍** ម្ចាស់បំណុល(ម្ចាស់ទ្រព្យ) ទៅរឹបអូសយកទ្រព្យរបស់គាត់ ដែលគាត់បានឱ្យគេខ្ចី គឺមិនអាចចាត់ទុកថាជាការលួចឡើយ។[30]

ម៉្យាងវិញទៀត ការដកហូតយករបស់ដែលគ្មានម្ចាស់ ឬគ្មានភាពជាម្ចាស់ភ្ជាប់ជាមួយ មិនមែនជា អំពើលួចទេ។ ទ្រព្យសម្បត្តិ ឬវត្ថុ ដែលគ្មានម្ចាស់មានស្ថានភាព២ យ៉ាង គឺៈ

- វត្ថុគ្មានម្ចាស់ទូទៅ ជាវត្ថុ ដែលមិនមានម្ចាស់ពីធម្មជាតិមក(ធនធានធម្មជាតិ) ឬត្រូវបានម្ចាស់បោះចោលលែងត្រូវការជារៀងរហូត។

**ឧទាហរណ៍** ទឹកសមុទ្ទ ខ្យល់ ធូលីដី មិនអាចក្លាយជាកម្មវត្ថុនៃអំពើលួចបានឡើយ។

- ទ្រព្យសម្បត្តិគ្មានម្ចាស់ក្នុងខណៈ ជាទ្រព្យសម្បត្តិ ដែលដំបូងឡើយម្ចាស់បានបោះបង់ ប៉ុន្តែក្រោយមកម្ចាស់បានប្តូរឆន្ទៈលែងបោះបង់ ហើយត្រឡប់ទៅយកវិញ។ ដូច្នេះបើសិនជាអ្នកដកហូត ដឹងច្បាស់ពីការបោះបង់នោះ ហើយទៅដកហូតយករបស់នោះមកនៅក្នុងខណៈពេលដែលវាស្ថិតជាទ្រព្យគ្មានម្ចាស់នោះ សកម្មភាពនោះមិនមែនជាអំពើលួចទេ។

**ឧទាហរណ៍** អ្នកអនាម័យម្នាក់បានឃើញនារី **ក** បោះចិញ្ចៀនចោលទៅក្នុងធុងសំរាម បន្ទាប់ពីឈ្លោះគ្នាជាមួយស្វាមីនាងរួច។ អ្នកអនាម័យនោះ បានបញ្ជាក់ នាង **ក** ទៀតថា «នាង!ចិញ្ចៀននៅក្នុងធុងសំរាម» នាង **ក** បានឮ តែមិនខ្វល់។ ក្រោយមកអ្នកអនាម័យនោះ ក៏រើសយកចិញ្ចៀននោះទៅផ្ទះគាត់ទៅ។ក្រោយពីត្រូវគ្នាជាមួយប្តីនាងវិញ នាង ក បានទៅរកចិញ្ចៀននោះវិញ ហើយបានទាមទារចិញ្ចៀននោះពីអ្នកអនាម័យនោះវិញ ហើយថែមទាំងប្តឹងអ្នកអនាម័យនោះលើអំពើលួចទៀត។ នៅក្នុងករណីនេះ ទង្វើរបស់អ្នកអនាម័យ មិនមែនជាអំពើលួចឡើយ ហើយបើទោះបីជាអ្នកអនាម័យមិនប្រគល់ចិញ្ចៀននោះឱ្យនាង **ក** វិញ ក៏ទង្វើនេះ នៅតែមិនមែនជាអំពើលួចដដែល។

**ខ. លក្ខណៈនៃទ្រព្យសម្បត្តិ ឬវត្ថុ**

[30] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១៣-២០១៤ ១០.អំពើលួច។

ដូចបានបកស្រាយនៅខាងលើមកហើយ អំពើលួច គឺជាការដកហូតឬការផ្លាស់ទីដោយទុច្ចរិត។ ដូច្នេះ ទ្រព្យសម្បត្តិ ឬវត្ថុ ដែលអាចក្លាយជាកម្មវត្ថុនៃអំពើលួចបាន គឺទាល់តែវត្ថុ ឬទ្រព្យសម្បត្តិនោះអាចផ្លាស់ទីបាន។ ហេតុនេះទ្រព្យ ដែលជាកម្មវត្ថុនៃអំពើលួចត្រូវតែជា **ចលនវត្ថុ**[31] ។

តាមន័យខាងលើគេទាញបានថា **អចលនវត្ថុ**[32] មិនអាចជាកម្មវត្ថុនៃអំពើលួចទេ ហើយអចលនវត្ថុនោះជាប្រភេទ **អចលនវត្ថុពីកំណើត**។ អចលនវត្ថុពីកំណើត គឺជាដី ធ្លី គេហដ្ឋាន ដែលសង់គ្រឹះ ឬសង់ដោយបាយអ និងឥដ្ឋ សំណង់ទាំងឡាយ បើរុះរើទៅនោះ នាំឱ្យបាត់បង់តម្លៃជាសារធាតុ។ អចលនវត្ថុពីកំណើតមានដីធម្មជាតិ ដូចជា ដីព្រៃឈើ ដីដាំដុះ ដីទុកទំនេរ ឬមិនអាចដាំដុះ ដីលិចទឹកនៅនឹង ឬទឹកហូរ និងសំណង់ ឬការរៀបចំទាំងឡាយ ដែលស្ថិតនៅជាប់មួយកន្លែង កើតឡើងដោយអំពើរបស់មនុស្ស ហើយមិនអាចរំកិល ឬផ្លាស់ប្តូរកន្លែងបាន ។[33]

**ឧទាហរណ៍** ដីធ្លី មិនអាចជាកម្មវត្ថុនៃអំពើលួចក្នុង **មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ** នោះទេ។ ប៉ុន្តែទាក់ទងនឹងការលួច ដែលមានកម្មវត្ថុពាក់ព័ន្ធ នឹងដីធ្លី ឬអចលនទ្រព្យនេះ មានបញ្ញត្តិដោយឡែកទៀត ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងអំពើលួចដែរ។

ប៉ុន្តែអចលនវត្ថុខ្លះអាចក្លាយជាកម្មវត្ថុនៃអំពើលួចបាន ព្រោះអចលនវត្ថុទាំងនោះអាចផ្លាស់ទីបាន ឬមានលក្ខណៈសម្បទាអាចចល័តបានដូចចលនវត្ថុដែរ ដូចជា**អចលនវត្ថុតាមភព្វវាសនា** និង **អចលនវត្ថុតាមការកំណត់របស់ច្បាប់**។

- អចលនវត្ថុតាមភ័ព្វវាសនានេះ មានឥរិយាបថជាចលនវត្ថុ ប៉ុន្តែត្រូវចាត់ទុកដូចជាអចលនវត្ថុដែរ ពីព្រោះវាត្រូវភ្ជាប់ខ្លួនជាបរិវារនៃអចលនវត្ថុតាំងពីកំណើត ដែលគ្រាន់តែជាបន្ទាប់បន្សំប៉ុណ្ណោះ ប៉ុន្តែត្រូវចាត់ទុកជាអចលនវត្ថុ។[34]

**ឧទាហរណ៍** ត្រាក់ទ័រមួយគ្រឿង (ចលនវត្ថុ) ត្រូវបានយកមកដើម្បីរាស់ដីតែមួយកន្លែង (អចលនវត្ថុពីកំណើត) ដើម្បីប្រកបអាជីវកម្មក្នុងកសិដ្ឋានមួយ។[35] ហេតុនេះត្រាក់ទ័រនោះ ជាអចលនវត្ថុតាមភ័ព្វវាសនា។ ក្នុងករណី ដែលមានចោរលួចចូលមកក្នុងកសិដ្ឋាននោះ ហើយបានបើកយកត្រាក់ទ័រនោះចេញទៅ អំពើនេះក៏ជាអំពើលួចផងដែរ។

---

[31] ចលនវត្ថុ មានន័យថា វត្ថុ ឬទ្រព្យរបស់ ដែលកម្រើកបាន, ដែលលើកដាក់ ឬដឹកនាំពីកន្លែងមួយទៅកាន់កន្លែងមួយទៀតបាន។ (វចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយពុទ្ធសាសនាបណ្ឌិត្យ គ.ស. ១៩៦៧ ទំព័រ១៤០)។

[32] អចលនវត្ថុ មានន័យថា ដីធ្លី និងវត្ថុជាប់នៅនឹងដី ហើយមិនអាចផ្លាស់ប្តូរ ទីកន្លែងបានដូចអគារ សំណង់ ដំណាំរុក្ខ-ជាតិ។ល។ (សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី បោះផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧ ទំព័រ លេខ១៧៦)។

[33] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១ បោះពុម្ពផ្សាយឆ្នាំ២០១៣ ទំព័រ៣៤។

[34] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១ បោះពុម្ពផ្សាយឆ្នាំ២០១៣ ទំព័រ៣៤។

[35] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១ បោះពុម្ពផ្សាយឆ្នាំ២០១៣ ទំព័រ៣៤។

▪ អចលនវត្ថុតាមការកំណត់របស់ច្បាប់ មានសិទ្ធិភណ្ឌិក[36] ទាំងឡាយនៅលើអចលនវត្ថុ និងចលនវត្ថុទាំងឡាយ ដែលបានកំណត់ដោយច្បាប់ជាអចលនវត្ថុ។[37] ដូច្នេះ អាចចាត់ទុកជាអចលនវត្ថុតាមការសន្មតរបស់ច្បាប់ផងដែរ ចំពោះចលនវត្ថុ ដែលច្បាប់តម្កល់ឱ្យនៅក្នុងរបៀបជាអចលនវត្ថុពីកំណើត ថ្វីបើជាវត្ថុនោះអាចដឹកនាំបាន។[38] នៅក្នុង **ច្បាប់ភូមិបាលឆ្នាំ ១៩៩២** ដែលត្រូវបាននិរាករណ៍ហើយនោះ បានកំណត់នូវវត្ថុមួយចំនួនជាអចលនវត្ថុទាំងដែលវាអាចផ្លាស់ទីបាន។ ដូចបានកំណត់នៅក្នុង**មាត្រា៩ វាក្យខណ្ឌទី២**ថា អចលនវត្ថុទាំងឡាយគឺ ទូក ដែលមានចំណុះ ៣០តោនឡើងទៅ ផ្ទះដែលមានចំណុះដូចគ្នា និងសិទ្ធិប្រត្យក្សលើអចលនវត្ថុ។[39] ដូច្នេះ ក្នុងករណីដែលមានចោរលួចទូក ដែលមានទម្ងន់៣០តោន បើកចេញទៅ ទង្វើនេះក៏ជាអំពើលួចដែរ។

ជាងនេះទៅទៀត វត្ថុ ឬទ្រព្យសម្បត្តិនោះ មាន**លក្ខណៈទូទៅ** ពោលគឺទោះទ្រព្យនោះ ជាទ្រព្យសុចរិតក្តី ទុច្ចរិតក្តី ក៏អាចទៅជាកម្មវត្ថុនៃអំពើលួចបានដែរ។ តួយ៉ាង ទ្រព្យដែលច្បាប់ហាមឃាត់ពាណិជ្ជកម្មដូចជា គ្រឿងញៀនជាដើម ក៏អាចក្លាយជាកម្មវត្ថុនៃការលួចបាន។[40]

**ឧទាហរណ៍** ចោរម្នាក់ បានទៅលួចយកទូរស័ព្ទគេចពន្ធ ពីកន្លែងលក់ទូរស័ព្ទមួយព្រោះចោរនោះយល់ថា បើលួចទូរស័ព្ទគេចពន្ធ ម្ចាស់ហាងមិនហ៊ានប្តឹងប៉ូលីសទេ ដោយហេតុថាកម្មវត្ថុ ដែលខ្លួនលួចនោះជារបស់ខុសច្បាប់។ ប៉ុន្តែចៃដន្យ ពេលកំពុងលួចយកចេញទៅ មានអ្នកជិតខាងបានឃើញ ហើយប្តឹងទៅសមត្ថកិច្ច។ ក្នុងករណីនេះ ទោះបីទ្រព្យសម្បត្តិ ដែលចោរដកហូតដោយទុច្ចរិតនោះជាទំនិញខុសច្បាប់ក៏ដោយ ក៏ទង្វើរបស់ចោរនោះ ជាប្រត្យក្សភាព[41] នៃអំពើលួចដែរ។

ទ្រព្យសម្បត្តិ ឬវត្ថុ ដែលជាកម្មវត្ថុនៃអំពើលួច មាន ២ ទម្រង់ធំៗគឺ៖ **ទម្រង់រូបី** និង**ទម្រង់អរូបី** ។

**ខ.១. ទម្រង់រូបី**

***រូបី*** មានន័យថា ដែលមានរូប។[42] ដូច្នេះ ទ្រព្យសម្បត្តិ ឬវត្ថុ ដែលមានរូបអាចឱ្យយើងមើលឃើញនឹងភ្នែកដោយប្រចក្ស និងអាចចាប់កាន់បាន អាចក្លាយជារបស់ ដែលត្រូវបានលួចដោយអំពើលួចផងដែរ។ ទ្រព្យសម្បត្តិ ឬវត្ថុរូបីទាំងនោះមានដូចជា **ទ្រព្យសម្បត្តិ ឬវត្ថុរូបីសាមញ្ញ** និង**ទ្រព្យសម្បត្តិ ឬវត្ថុរូបីពិសេស ។**

---

[36] សិទ្ធិប្រត្យក្ស ឬសិទ្ធិភណ្ឌិក មានន័យថា សិទ្ធិគ្រប់គ្រងដោយចំពោះលើវត្ថុ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន។ (សទ្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធិរដ្ឋប្បវេណី បោះផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧ ទំព័រ២៣ លេខ១៥៨)។

[37] ច្បាប់ភូមិបាល ឆ្នាំទី៩ លេខ៣២ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១ រាជកិច្ច ទំព័រ២៣០៥ មាត្រា២ កថាខណ្ឌទី៥។

[38] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១ បោះពុម្ពផ្សាយឆ្នាំ២០១៣ ទំពី៣៤។

[39] ច្បាប់ភូមិបាល ឆ្នាំ១៩៩២ ទំព័រ២ មាត្រា៩ សូមមើលតំណភ្ជាប់ខាងក្រោមនេះ៖ https://lsknan.files.wordpress.com/2012/10/e19e85e19f92e19e94e19eb6e19e94e19f8be19e97e19ebce19e98e19eb7e19e94e19eb6e19e9b-1992.pdf ។

[40] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១៣-២០១៤ ១០.អំពើលួច។

[41] ប្រត្យក្សភាព មានន័យថា ភាពជាក់លាក់ ច្បាស់លាស់។

[42] វចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ គ.ស. ១៩៦៧ ទំព័រ៧៨៤។

**ខ.១.១. ទ្រព្យសម្បត្តិ ឬវត្ថុរូបីសាមញ្ញ**

ទ្រព្យសម្បត្តិ ឬវត្ថុរូបីសាមញ្ញ គឺជាទ្រព្យសម្បត្តិ ឬវត្ថុ មានរូបរាងអាចមើលឃើញ អាចចាប់កាន់បាន ដែលធម្មតា និងជាកម្មសិទ្ធិរបស់មនុស្សទូទៅ។

**ឧទាហរណ៍** មាស ពេជ្រ លុយ គ្រឿងអលង្ការ ម៉ូតូ រថយន្ត ជាដើម ជាទ្រព្យសម្បត្តិ ឬវត្ថុរូបីសាមញ្ញ។ អំពើលួចទទ្រព្យសម្បត្តិប្រភេទខាងលើនេះ ចូលក្នុងនិយមន័យនៃអំពើលួច ក្នុង**មាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩**។

**ខ.១.២. ទ្រព្យសម្បត្តិ ឬវត្ថុរូបីពិសេស**

ទ្រព្យសម្បត្តិ ឬវត្ថុរូបីពិសេស គឺជាទ្រព្យសម្បត្តិ ឬវត្ថុ មានរូបរាងអាចមើលឃើញនឹងភ្នែកបាន ហើយក៏អាចចាប់កាន់ ដែលមានតម្លៃដោយឡែកជាពិសេស និងជាកម្មវត្ថុនៃកម្មសិទ្ធិពិសេស។

**ឧទាហរណ៍** បូជនីយវត្ថុ[43] ក្នុងព្រះពុទ្ធសាសនា មានដូចជា ព្រះពុទ្ធបដិមា ព្រះសារីរិកធាតុជាដើម សុទ្ធតែជាទ្រព្យសម្បត្តិ ឬវត្ថុរូបីពិសេស ដែលមានតម្លៃអត្តភាពពិសេស និងជាកម្មវត្ថុនៃកម្មសិទ្ធិពិសេសរបស់សាសនា។ ការលួចនូវទ្រព្យសម្បត្តិ ឬវត្ថុរូបីប្រភេទនេះ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានកំណត់ក្នុង**មាត្រា ៥០៩ នៃក្រមព្រហ្មទណ្ឌ ២០០៩** ដូចបានចែងថា៖ ***ដោយមិនទាន់គិតដល់ទោសធ្ងន់ជាងគេ ដែលមានចែងក្នុងក្រមនេះការលួចបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា ដែលប្រព្រឹត្តនៅក្នុងបូជនីយដ្ឋាន[44] សាសនាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យប្រាក់ពី ៤.០០០.០០០(បួនលាន) រៀល ទៅ ១០.០០០.០០០(ដប់លាន) រៀល***[45]។ មានន័យថាការលួចនូវវត្ថុ ដែលគេបូជាក្នុងព្រះពុទ្ធសាសនា ហើយដែលការលួចនោះធ្វើឡើងក្នុងទីបូជានៃសាសនា ដូចជាវត្តអារាម ធម្មសាលា កន្លែង ដែលតម្កល់បូជនីយវត្ថុទុកសម្រាប់ឱ្យបូជា ជាបទលួចបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា។ ទោះបីថាការលួចនូវបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា ត្រូវបានកំណត់ក្នុងមាត្រាដោយឡែក មិនស្ថិតនៅក្រោម**គន្លឹះទី៣ បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ មាតិកាទី១ ការយកទ្រព្យសម្បត្តិអ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយទុច្ចរិត ជំពូកទី១ ការលួច និងបទល្មើសប្រហាក់ប្រហែល ផ្នែកទី១ ការលួច** ក៏ដោយក្តី ក៏បទល្មើសនេះជាអំពើលួចផងដែរ និងអាចអនុវត្តនូវស្ថានភាពដូចជាស្ថានទម្ងន់ទោស ដែលបានបញ្ញត្តក្នុង**ក្រមព្រហ្មទណ្ឌ ២០០៩** ចាប់ពី **មាត្រា ៣៥៧** ដល់ **មាត្រា ៣៦០** ផងដែរ។[46]

**ខ.២. ទម្រង់អរូបី**

[43] បូជនីយវត្ថុ មានន័យថា វត្ថុ ដែលគេបូជា គោរព។

[44] បូជនីយដ្ឋាន មានន័យថា កន្លែង ដែលគេបូជា គោរព។

[45] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១៦៩ មាត្រា៥០៩។

[46] សូមអានករណីក្នុងតំណភ្ជាប់ខាងក្រោម៖
http://m.freshnewsasia.com/index.php/en/9039-2015-08-27-04-58-22.html ។

**អរូបី** ឬ**អរូប** មានន័យថា ដែលឥតរូប។[47] ក្រៅពីទ្រព្យសម្បត្តិ ឬវត្ថុ ដែលមើលឃើញ និងចាប់បាន ទ្រព្យសម្បត្តិ ឬវត្ថុ ដែលគ្មានរូប មិនអាចមើលឃើញ ក៏អាចជាកម្មវត្ថុនៃអំពើលួចផងដែរ។ ទោះបីជារបស់ទាំងនោះគ្មានរូបរាងក៏ដោយពិត ប៉ុន្តែវាអាចឱ្យគេប្រើប្រាស់និងគ្រប់គ្រងបាន។ ដូច្នេះ គេក៏ចាត់ទុករបស់គ្មានរូបប្រភេទនោះជាទ្រព្យសម្បត្តិអរូបី ដែលមានដូចជា ថាមពល មានជាអាទិ៍អគ្គិសនី។ ហេតុនេះហើយ បានជានីតិនិពន្ធខ្មែរ បានកំណត់នៅក្នុង **មាត្រា ៣៥៤** នៃក្រមព្រហ្មទណ្ឌថា៖ ***ត្រូវចាត់ទុកជាអំពើលួច អំពើប្រើប្រាស់ដោយទុច្ចរិតនូវថាមពល[48] ដែលនាំឱ្យខូចប្រយោជន៍អ្នកដទៃ***។នៅក្នុងបញ្ញត្តិនេះ ការលួចស្ថិតក្នុងរូបភាពនៃការប្រើប្រាស់ដោយទុច្ចរិត ពោលគឺចារីគ្មានសិទ្ធិក្នុងការប្រើទេ តែចារីបែរជាលួចប្រើនូវថាមពលនោះដោយបំពាន និងគ្មានការអនុញ្ញាតពីម្ចាស់គេ ហើយការប្រើនូវថាមពលនេះ ធ្វើឱ្យម្ចាស់នៃទ្រព្យអរូបី គឺថាមពលនោះខូចប្រយោជន៍។ អំពើលួចនូវទ្រព្យសម្បត្តិ ឬវត្ថុអរូបីនេះ ផ្អែកតាមបញ្ញត្តិខាងលើ ការផ្តន្ទាទោសក្នុងបទល្មើសនេះ មិនខុសពីការផ្តន្ទាទោសចំពោះអំពើលួច ដែលមានកម្មវត្ថុជាទ្រព្យសម្បត្តិ ឬវត្ថុរូបីនោះទេ។ ជាងនេះទៅទៀត ការលួចថាមពលអាចយកទៅអនុវត្តចំពោះ នីតិបុគ្គលបានដែរ[49]។

**ឧទាហរណ៍** បុរស ក ដែលនៅក្បែរផ្ទះបុរស ខ បានតបំបែកភ្លើងដោយបំពានពីផ្ទះបុរស ខ ដើម្បីយកមកប្រើ។ ទង្វើរបស់បុរស ក នេះជាអំពើលួចថាមពល។

**២.១.២.៣. មធ្យោបាយនៃការប្រព្រឹត្តអំពើលួច**

នៅក្នុង**ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា៣៥៣** បានបញ្ញត្តយ៉ាងទូលាយអំពីបញ្ហាមធ្យោបាយនៃការប្រព្រឹត្តអំពើលួចថា៖ ***អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន***។[50] មានន័យថា មធ្យោបាយក្នុងការប្រព្រឹត្តអំពើលួចអាចធ្វើឡើងបានគ្រប់រូបភាព ឱ្យតែជាការដកហូតដោយទុច្ចរិត នូវទ្រព្យសម្បត្តិអ្នកដទៃ និងមានចរិតយកមកធ្វើជារបស់ខ្លួន ពោលគឺមិនថាការដកហូតនោះ ប្រើប្រាស់មធ្យោបាយដោយផ្ទាល់ ឬប្រយោល ជាការបន្លំយក ឬយកវត្ថុដែលខ្លួនគ្មានសិទ្ធិទាំងដែលម្ចាស់គេមិនបានប្រគល់ឱ្យ ហើយមិនប្រគល់ទៅឱ្យម្ចាស់គេវិញជាដើមនោះ សុទ្ធតែអាចជាមធ្យោបាយនៃការប្រព្រឹត្តអំពើលួច។ ការកំណត់របស់**ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩**បែបនេះ ដោយសារតែនីតិនិពន្ធបានយល់ថា ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌរបស់ជនល្មើសនីមួយៗ ប្រើប្រាស់នូវវិធីសាស្ត្រ ឬមធ្យោបាយសម្រាប់ការប្រព្រឹត្តបទល្មើសដោយឡែកៗពីគ្នា ទៅតាមស្ថានភាពនៃកាលៈទេសៈ ឬខណៈនៃព្រឹត្តិការណ៍ ទៅតាមស្ថានភាព

[47] វចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ គ.ស.១៩៦៧ ទំព័រ១២៧៥។

[48] ពាក្យថា ថាមពល មិនមែនកំណត់ត្រឹមតែ ថាមពលអគ្គិសនីទេ ពោលគឺមានវិសាលភាពនៃការបកស្រាយបានទូលាយ ប៉ុន្តែ ពុំទាន់មានបទដ្ឋានគតិយុត្តណាកំណត់ពីដែននៃការបកស្រាយអំពីបញ្ញត្តិ(Concept) ថាមពល នេះឱ្យជាក់លាក់ទេ។ ហេតុនេះ ត្រូវពឹងផ្អែកលើការបកស្រាយនៃវិស័យច្បាប់ក្នុងពេលអនាគត។

[49] សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី វិភាគទានចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ បោះពុម្ពផ្សាយ ឆ្នាំ២០០៥ ទំព័រ៣០០ មាត្រា កម ៣១១-២ ការលួចថាមពល។

[50] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១១៦ មាត្រា ៣៥៣។

ឆន្ទៈនៃចារីនីមួយៗ ទៅតាមស្ថានភាពលទ្ធភាពនៃចារី ទៅតាមស្ថានភាពនៃកម្រិតចំណេះដឹងរបស់ចារី និងទៅតាមស្ថានភាពនៃទំនាក់ទំនងអមិត្តរវាងចារី និងជនរងគ្រោះ ជាដើម។ ដូច្នេះ ការកំណត់ថា អំពើលួចអាចធ្វើឡើងតាមគ្រប់មធ្យោបាយ គឺដើម្បីតម្រូវទៅតាមបម្រែបម្រួលនៃមធ្យោបាយដែលចារីផ្សេងៗគ្នាប្រព្រឹត្តបទល្មើសនេះ។

ជាងនេះទៅទៀត មធ្យោបាយពិសេសមួយចំនួន ដែលចារីប្រព្រឹត្តរួមជាមួយអំពើលួចដូចជា ហិង្សា ការកាប់គាស់ទម្លុះទម្លាយ ការកាត់អវយវៈ ឬធ្វើឱ្យពិការជាអចិន្ត្រៃយ៍ ការធ្វើទារុណកម្ម ឬអំពើឃោរឃៅ ជាដើម អាចជាស្ថានភាព ដែលញ៉ាំងឱ្យផ្តន្ទាទោសនូវអំពើលួចក្នុងស្ថានទម្ងន់ទោសបានផងដែរ។[51]

### **២.១.៣. ធាតុអត្តនោម័ត**

ធាតុអត្តនោម័ត គឺជាផ្នែកខាងក្នុងនៃបទល្មើស ដែលផ្ទុយទៅនឹងធាតុសត្យានុម័ត ដែលជាផ្នែកខាងក្រៅនៃបទល្មើស។ បើវិភាគតាមដំណាក់កាលនៃបទល្មើស យើងឃើញថាធាតុអត្តនោម័ត កើតមានមុនធាតុសត្យានុម័ត។ ប៉ុន្តែដោយសារនៅក្នុងដំណើរការស៊ើបអង្កេត គេអាចស្វែងយល់ពីធាតុអត្តនោម័ត តាមរយៈធាតុសត្យានុម័ត ទើបនាំឱ្យរៀងលំដាប់នៃធាតុផ្សំអត្តនោម័តបន្ទាប់ពីសត្យានុម័ត។ **ធាតុអត្តនោម័ត** គឺជាកិរិយាផ្លូវចិត្តរបស់ជនល្មើសចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គមដែលគេបានប្រព្រឹត្ត និងចំពោះបច្ច័យដែលកើតឡើងពីអំពើនោះ។[52] ធាតុផ្សំអត្តនោម័តនៃបទល្មើស គឺ កំហុសៈ

- **កំហុស**: អាចជាកំហុសដែលកើតឡើងពីចេតនា ឬអចេតនា ដែលចារីបានប្រព្រឹត្ត ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។

ចំណុច ២ ទៀត ដែលគួរពិចារណាផងដែរទាក់ទងនឹងដំណើរនៃផ្លូវចិត្តរបស់ចារីនៃបទល្មើសនេះគឺ គំនិតផ្តួចផ្តើមក្នុងការប្រព្រឹត្តបទល្មើស និងកម្មវត្ថុនៃការប្រព្រឹត្តបទល្មើស។

- **គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើស**[53]: គឺជាមូលហេតុនៃការប្រព្រឹត្តបទល្មើស និងជាកត្តា ផ្លូវចិត្ត ដែលជំរុញឱ្យបុគ្គលណាម្នាក់ប្រព្រឹត្តបទល្មើស។[...] មូលហេតុនៃការប្រព្រឹត្តបទល្មើសរមែងប្រែប្រួលទៅតាមចារីម្នាក់ៗដូចជា: តម្រូវការផ្នែកសម្ភារៈ មានគំនុំគុំកួន សងសឹក មានការប្រចណ្ឌ មានកំហឹង មានការអាក់អន់ចិត្ត និងមានសេចក្តីលោភលន់ ជាដើម ។[54]
- **កម្មវត្ថុបទល្មើស**: គឺជាមុខព្រួញ ឬទិសដៅ ដែលប្រធាននៃបទល្មើស គឺជនល្មើស ចង់បង្កព្យសនកម្មលើ។ កម្មវត្ថុនៃបទល្មើសមាន **២** តាមទស្សនៈដែលបានលើកឡើង **គឺទី១ កម្មវត្ថុនៃបទល្មើស គឺជាច្បាប់ព្រហ្មទណ្ឌ**

---

[51] សូមមើលក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១១៦ ដល់១១៧ មាត្រា៣៥៧ ដល់មាត្រា៣៦០។

[52] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២ ទំព័រ១៩៣។

[53] គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើស មានន័យដូចគ្នានឹង មូលហេតុនៃការប្រព្រឹត្តបទល្មើស។

[54] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២ ទំព័រ ២០៤ ដល់២០៥។

(ជនល្មើសចង់បំពានច្បាប់ព្រហ្មទណ្ឌ) និង**ទី២ កម្មវត្ថុនៃបទល្មើស គឺជាអ្វីដែលច្បាប់ការពារ** (**ឧទាហរណ៍** ជនល្មើសសម្លាប់មនុស្ស ដែលជីវិតមនុស្ស គឺជាកម្មវត្ថុដែលច្បាប់ការពារដូចបានកំណត់ថា ពលរដ្ឋគ្រប់រូបមានសិទ្ធិរស់រានមានជីវិត ជាដើម)។[55]

**២.១.៣.១. កំហុសក្នុងអំពើលួច**

អំពើលួច ជាបទល្មើសព្រហ្មទណ្ឌមួយ ដែលកើតឡើងដោយកំហុសចេតនាយ៉ាងដាច់ខាត ព្រោះថា មុននឹងឈានទៅដល់ការប្រព្រឹត្តសកម្មភាពនៃអំពើលួចបាន ចារីត្រូវតែកំណត់នូវមុខសញ្ញាលួច ដែលការកំណត់មុខសញ្ញានោះអាចធ្វើឡើងជាយូរ ប្រកបដោយគម្រោង ឬឃើញភ្លាមកំណត់មុខសញ្ញា ហើយក៏ចូលទៅលួចតែម្តង។ ការលួចមិនអាចគ្មានមុខសញ្ញានោះទេ បើសិនជាអំពើលួចគ្មានមុខសញ្ញា នោះអំពើលួចក៏មិនទាន់លេចជារូបរាង និងឈានដល់ការប្រព្រឹត្តដែរ។ ជាងនេះទៀត ការលួច ឬអំពើលួច មុននឹងចារីប្រព្រឹត្តបទល្មើសនេះ គឺចារីត្រូវមានចិត្តចង់ដកយកទ្រព្យរបស់អ្នកដទៃ ដោយទុច្ចរិត ឬក៏ត្រូវមានថេយ្យចិត្ត ដើម្បីអាចទៅប្រព្រឹត្តបទល្មើសបាន។ លើសពីនេះទៅទៀត ការធ្វើអំពើលួចនេះគឺចារីមានបំណងចង់យកទ្រព្យសម្បត្តិ ឬវត្ថុរបស់អ្នកដទៃ មកធ្វើជារបស់ខ្លួនថែមទៀតផង។[56] ដូច្នេះហើយ ការមានមុខសញ្ញាជាមុន ថេយ្យចិត្តនៃចារី និងការចង់យកមកធ្វើជារបស់ខ្លួននេះ បានធ្វើឱ្យបទល្មើសនេះ ត្រូវតែជាកំហុសចេតនាយ៉ាងដាច់ខាត។ យើងក៏អាចទាញបានថា គ្មានការលួចណា កើតចេញពីកំហុសអចេតនានោះទេ។

**ឧទាហរណ៍** ចោរ ដើម្បីលួចនរណាម្នាក់ ត្រូវមើលរកមុខសញ្ញា ដែលជាជនរងគ្រោះ ឬជាទ្រព្យសម្បត្តិ ឬវត្ថុដែលចោរចង់បាន សម្រាប់ឱ្យចោរចូលទៅលួច។ នៅពេលកំណត់មុខសញ្ញា និងកម្មវត្ថុនៃបទល្មើសហើយ ទើបចោរចាប់ប្រព្រឹត្តបទល្មើសបាន។

បើយើងវិភាគឱ្យស៊ីជម្រៅនៅក្នុងកំហុសចេតនា ក្នុងការប្រព្រឹត្តអំពើលួចនោះយើងអាចញែកជា ៤ចំណុចធំៗ ដូចជា **ចេតនាទុច្ចរិតទូទៅ, ចេតនាទុច្ចរិតពិសេស, ចេតនាទុច្ចរិតច្បាស់លាស់ និងចេតនាទុច្ចរិតមិនច្បាស់លាស់**, ក៏ដូចជា **ចេតនាទុច្ចរិតចំពោះ និង ចេតនាទុច្ចរិតមិនចំពោះ**។

**ក. ចេតនាទុច្ចរិតទូទៅ**

ចេតនាទុច្ចរិតទូទៅនៃការប្រព្រឹត្តបទល្មើសអំពើលួចនេះ ក៏មិនខុសពីចេតនាទុច្ចរិតទូទៅនៃការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនានាដែរ គឺចារីមានចេតនាប្រព្រឹត្តអំពើដែលខ្លួនបានដឹងថាច្បាប់ព្រហ្មទណ្ឌបានហាមឃាត់។ ចារីមិនអាចលើកឡើងថាខ្លួនមិនបានដឹងថាអំពើលួចនូវទ្រព្យសម្បត្តិ ឬវត្ថុអ្នកដទៃនេះ ត្រូវបានហាមឃាត់ដោយច្បាប់នោះទេ ព្រោះតាមគោលការណ៍ គ្មាននរណាដែលមិនស្គាល់ ឬមិនយល់ដឹងពីច្បាប់ឡើយ។[57] ពិតណាស់ ជនល្មើស

---

[55] មេរៀននីតិព្រហ្មទណ្ឌទូទៅ ឯកឧត្តម ហ៊ី សោភា មេរៀនទី៤ ទំព័រ៥។

[56] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១១៦ មាត្រា៣៥៣។

[57] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២។

នៃបទល្មើសលួច បានដឹងច្បាស់ថាវត្ថុ ដែលខ្លួនយកមកនោះមិនមែនជារបស់ខ្លួនឡើយ ហើយមានចេតនាដកហូតយកទ្រព្យនោះ។ ហេតុនេះ ជនម្នាក់ដែលច្រឡំស្មានថាជាទ្រព្យរបស់ខ្លួន ហើយក៏យកទ្រព្យនោះមកទុក មិនអាចចាត់ទុកថាបានប្រព្រឹត្តអំពើលួចឡើយ។[58]

**ខ.ចេតនាទុច្ចរិតពិសេស**

ទន្ទឹមនឹងការមានចេតនាដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុរបស់អ្នកដទៃហើយនោះ ក្នុងការប្រព្រឹត្តអំពើលួចក៏មានកំណត់នូវចេតនាពិសេសមួយបន្ថែមទៀត ដែលជាផ្នែកមួយនៃធាតុផ្សំនៃបទល្មើសផងដែរ។ ចេតនាទុច្ចរិតពិសេសនៃអំពើលួចគឺបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដូចជាដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន ដើម្បីយកទៅធ្វើជាអំណោយឱ្យជនណាម្នាក់ ដើម្បីយកទៅលក់ឱ្យអ្នកដទៃ ដើម្បីយកទៅចាត់ចែងតាមបំណងប្រាថ្នារបស់ខ្លួនដូចជាទុកចោល ឬយកទៅបោះបង់ចោល ជាដើម។ការទាមទារថ្នូរដើម្បីប្រគល់វត្ថុក៏ជាករណីលួចផងដែរ។[59]

**គ.ចេតនាទុច្ចរិតច្បាស់លាស់ និងចេតនាទុច្ចរិតមិនច្បាស់លាស់**

ការធ្វើនូវអំពើលួចនេះ ចារីមានចេតនាទុច្ចរិតច្បាស់លាស់ណាស់ ព្រោះដូចបានបកស្រាយខាងលើមកហើយថា ចារីនៃអំពើលួច បានកំណត់នូវមុខសញ្ញានៃការប្រព្រឹត្តបទល្មើស ក៏ដូចជាកំណត់នូវ លទ្ធផលដែលខ្លួនចង់បាន(ជនរងគ្រោះ និងទ្រព្យរបស់ជនរងគ្រោះ) ប្រកបដោយឆន្ទៈ ដែលលេចឡើងជាចេតនកម្មក្នុងការប្រព្រឹត្តបទល្មើសលួចនេះ។ ដូចនេះ ចេតនាទុច្ចរិតនៃការប្រព្រឹត្តអំពើលួច គឺជាចេតនាទុច្ចរិតដែលមានលក្ខណៈច្បាស់លាស់។

ប៉ុន្តែក្នុងករណីមួយចំនួន ការប្រព្រឹត្តអំពើលួច ក៏អាចមានលក្ខណៈមិនច្បាស់លាស់ផងដែរ នៅពេលដែលជនល្មើសបានលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ហើយខ្លួនបានប្រើហិង្សាលើជនរងគ្រោះ (អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា[60])។[61]

**ឃ. ចេតនាទុច្ចរិតចំពោះ និងចេតនាទុច្ចរិតមិនចំពោះ**

ការប្រព្រឹត្តអំពើលួច ជាធម្មតាវាជាប្រភេទបទល្មើស ដែលចារីមានចេតនាទុច្ចរិតយ៉ាងចំពោះ ពោលគឺចារីបានដឹងថា ការដកហូតយកទ្រព្យសម្បត្តិ ឬវត្ថុរបស់អ្នកដទៃដោយទុច្ចរិតនេះ នឹងធ្វើឱ្យទ្រព្យសម្បត្តិ ឬវត្ថុនោះផ្លាស់ទីពីម្ចាស់របស់វា ឬនិយាយបានថា នឹងធ្វើឱ្យម្ចាស់នៃទ្រព្យសម្បត្តិ ឬវត្ថុនោះ បាត់បង់នូវទ្រព្យសម្បត្តិ ឬវត្ថុរបស់ខ្លួនទៅ ក៏

[58] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១៣-២០១៤ ១០.អំពើលួច។

[59] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១៣-២០១៤ ១០.អំពើលួច។

[60] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១១៦ ដល់១១៧ មាត្រា ៣៥៧។

[61] សូមមើលនីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២ ទំព័រ២០០ ដល់២០២ ចេតនាទុច្ចរិតច្បាស់លាស់ និងចេតនាទុច្ចរិតមិនច្បាស់លាស់។

ដូចជាធ្វើឱ្យខូចខាតដល់សណ្តាប់ធ្នាប់សាធារណៈ។ ប៉ុន្តែចារីនៅតែប្រព្រឹត្តទៀត។ ត្រង់នេះ សបញ្ជាក់យ៉ាងច្បាស់ថា អំពើលួច ជាអំពើទុច្ចរិត ដែលមានចេតនាទុច្ចរិតយ៉ាងចំពោះ។

ដោយឡែក ក្នុងករណីខ្លះ អំពើលួចក៏អាចក្លាយជាអំពើ ដែលមានចេតនាទុច្ចរិតមិនចំពោះផងដែរ ពោលគឺ ក្នុងករណី ដែលចារីបានធ្វើឱ្យកើតមាននូវបច្ច័យផ្សេងទៀត ដោយមិនប៉ងប្រាថ្នាឱ្យបច្ច័យនោះកើតឡើងទេ។[62] តួយ៉ាងដូចជាករណីអំពើលួច ដែលមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ។[63]

**២.១.៣.២. គំនិតផ្តួចផ្តើមក្នុងការប្រព្រឹត្តអំពើលួច**

បទល្មើសកើតឡើងបាន រមែងមានគំនិតផ្តួចផ្តើម ដែលជាកត្តាញ៉ាំងឱ្យចារីប្រព្រឹត្តបទល្មើសនោះឡើង ដែលកត្តាទាំងនោះយើងអាចធ្វើការបែងចែកជា ២ ធំៗគឺ៖ **កត្តាចារីផ្ទាល់** និង **កត្តាខាងក្រៅ**។

**ក. កត្តាចារីផ្ទាល់**

ចំពោះករណីនេះ គំនិតផ្តួចផ្តើម ដែលជំរុញឱ្យចារីចាប់ប្រព្រឹត្តបទល្មើស គឺកើតឡើងក្នុងឆន្ទៈរបស់ចារីផ្ទាល់ ពោលគឺឥតមានឥទ្ធិលខាងក្រៅឯណា ជាអ្នកផ្តួចផ្តើមនូវគំនិតក្នុងការប្រព្រឹត្តបទល្មើសនោះឡើយ។ គំនិតផ្តួចផ្តើមក្នុងការប្រព្រឹត្តបទល្មើសលួច ដែលកើតក្នុងឆន្ទៈនៃចារីផ្ទាល់នេះ បានពន្លេចឱ្យចេញស្ថានភាព ២ យ៉ាងគឺ៖ **ករណីដែលចារីត្រូវ ទទួលខុសត្រូវព្រហ្មទណ្ឌ** និង**ករណី ដែលចារីមិនទទួលខុសត្រូវព្រហ្មទណ្ឌ**។

**ក.១. ករណី ដែលចារីត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ**

ក្នុងករណី ដែលចារីជាអ្នកញ៉ាំងនូវគំនិតក្នុងការប្រព្រឹត្តបទល្មើសនោះ ពោលគឺចារី ជាអ្នកគិតនូវគំនិតក្នុងការប្រព្រឹត្តនូវអំពើលួច ព្រមទាំងចេញប្រព្រឹត្តសកម្មភាពក្នុងការលួច នោះដោយខ្លួនចារីផ្ទាល់ ចារីដាច់ខាតត្រូវតែទទួលខុសត្រូវនូវទណ្ឌកម្មព្រហ្មទណ្ឌ និងរ៉ាប់រងរាល់ព្យសនកម្ម ដែលកើតឡើងពីសកម្មភាពរបស់ខ្លួន ដោយមិនអាចគេចវេះបានឡើយ។

**ឧទាហរណ៍** ចោរម្នាក់ បានចាយលុយ ដែលខ្លួនបានពីការលក់របស់ ដែលខ្លួនលួចបានពីមុនអស់ទៅ ក៏កើតមានគំនិតចង់ចេញធ្វើសកម្មភាពលួចម្តងទៀត។ បន្ទាប់ពីនោះមក ចោរនោះក៏បានចេញប្រព្រឹត្តអំពើលួចនៅចំណុចផ្សារមួយកន្លែង។ សកម្មភាព នៃអំពើលួចនេះ ចារី ដែលជាចោរនោះជាអ្នកគិតដោយខ្លួនឯង ហើយថែមទាំងចេញប្រព្រឹត្តបទល្មើសដោយខ្លួនឯងទៀតផង។

ករណីមួយទៀត គឺចារី ជាអ្នកផ្តួចផ្តើមនូវគំនិតនៃការប្រព្រឹត្តអំពើលួច ប៉ុន្តែចារីពុំមែនជាអ្នកចេញ ប្រព្រឹត្តបទល្មើសលួចនោះដោយផ្ទាល់នោះទេ ពោលគឺចារីជាចារីគំនិត នៃបទល្មើសលួចរបស់ចារីអំពើ(ចារីដែលប្រព្រឹត្តសកម្មភាពបទល្មើស)ផ្សេងទៀត។ ទោះបីជាចារីបានប្រព្រឹត្តបទល្មើសនេះត្រឹមតែជាគំនិតក៏ដោយក្តី ក៏ចារីត្រូវផ្តន្ទា

[62] សូមមើលនីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២ ទំព័រ២០២ ដល់២០៤ ចេតនាទុច្ចរិតមិនចំពោះ និងចេតនាទុច្ចរិតមិនចំពោះ។

[63] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១១៧ មាត្រា៣៦០។

ទោសចំពោះអំពើលួចនេះផងដែរ ប៉ុន្តែការដែលអាចផ្តន្ទាទោសចារីនៃ អំពើលួច ដែលស្ថិតក្នុងឋានៈត្រឹមតែជាចារីគំនិតនេះ គឺអាចធ្វើឡើងបានដោយពុំងករាជ្យប៉ុណ្ណោះ ពោលគឺត្រូវចំណុះឱ្យការផ្តន្ទាទោសចំពោះអំពើលួចនៃចារីអំពើ។[64]

**ឧទាហរណ៍** មេចោរឈ្មោះ ក បានបញ្ជាឱ្យកូនចៅរបស់ខ្លួនឈ្មោះ ខ ចេញទៅលួចនៅក្នុងទីតាំងផ្ទះមួយកន្លែង នៅម៉ោងពេល ដែលខ្លួនបានកំណត់ក៏ដូចជាផៀបផែនការ។ ដូច្នេះ នៅពេលដែលចោរ ឈ្មោះ ខ ត្រូវបានចាប់ខ្លួន ហើយផ្តន្ទាទោសចំពោះអំពើលួចនោះ មេចោរឈ្មោះ ក ក៏ត្រូវផ្តន្ទាទោសពី អំពើលួចដូចគ្នា។

**ក.២. ករណី ដែលចារីមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

ផ្ទុយពីករណីខាងលើ ទោះបីជាគំនិតផ្តួចផ្តើមក្នុងការលួចកើតមានពីក្នុងឆន្ទៈនៃចារីក៏ដោយពិត ប៉ុន្តែកាលណាចារីនៃអំពើលួចប្រព្រឹត្តបទល្មើសឡើងមកដោយសារស្ថានភាពចាំបាច់ នោះចារីនៃអំពើលួចនោះមិនតម្រូវឱ្យទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ បញ្ហានេះ នឹងមានបង្ហាញយ៉ាងច្បាស់ក្នុង**មាត្រា ៣៩** នៃ**ក្រមព្រហ្មទណ្ឌ** ដែលបានចែងថា៖

*បុគ្គល ដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។*

*ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមៈ*

- *បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង*
- *គ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់។*

ដោយយោងទៅលើមាត្រាច្បាប់ខាងលើ កាលបើចារីនៃអំពើលួចប្រព្រឹត្តបទល្មើសក្នុងស្ថានភាពមួយ ដែលចាត់ទុកថាត្រឹមត្រូវ ដើម្បីការពារខ្លួន និងប្រឆាំងនឹងគ្រោះថ្នាក់ ដែលកើតមាន ឬដែលនឹងកើតមាន ហើយថែមទាំងមានសមាមាត្ររវាងការប្រព្រឹត្ត និងស្ថានភាពចាំបាច់ទៀតនោះ ការលួចដែលចារីប្រព្រឹត្ត នឹងមិននាំឱ្យចារីទទួលខុសត្រូវព្រហ្មទណ្ឌទេ។

**ឧទាហរណ៍** បុរស **ក** ដោយក្រីក្រគ្មានប្រាក់ ហើយដើម្បីកុំឱ្យខ្លួនឃ្លានស្លាប់ គាត់បានទៅលួចបាយពីផ្ទះជិតខាង។ ករណីនេះ បុរស **ក** ប្រព្រឹត្តឡើងក្នុងស្ថានភាពចាំបាច់ ដើម្បីបញ្ចៀសគ្រោះថ្នាក់មកលើជីវិតខ្លួន ហើយទង្វើនេះមានសមាមាត្រជាមួយនឹងស្ថានភាពចាំបាច់ (លួចត្រឹមសម្រាប់ទទួលទាន) ដូច្នេះច្បាប់បានផ្តល់នូវយុត្តិកម្ម[65]នៃបទល្មើសដល់ករណីនេះ។

[64] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ៧ មាត្រា២៨។

[65]យុត្តិកម្មនៃបទល្មើស គឺជាអំពើដែលច្បាប់ព្រហ្មទណ្ឌចាត់ទុកថាជាបទល្មើស ប៉ុន្តែច្បាប់មិនតម្រូវឱ្យផ្តន្ទាទោសទេ ដោយសារតែការប្រព្រឹត្តបទល្មើសនោះធ្វើឡើងដោយត្រឹមត្រូវ។(នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោក ស្រីសាស្ត្រា ចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២ ទំព័រ២៤២ Footnote ១)។

**ខ. កត្តាខាងក្រៅ**

រីឯខាងករណីនេះវិញ គំនិតផ្តួចផ្តើម ដែលជំរុញឱ្យចារីទៅប្រព្រឹត្តបទល្មើសលួចនេះ មិនមែនកើតឡើងដោយសារចារីនោះទេ តែជាឥទ្ធិពលពីខាងក្រៅខ្លួនចារីទៅវិញ ដែលជំរុញឱ្យចារីប្រព្រឹត្តបទល្មើសលួចនេះចេញមក។ បញ្ហានេះយើងនឹងបែងចែកជា ២ ចំណុច ធំៗគឺ៖ **ករណី ដែលចារីត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ** និង**ករណី ដែលចារីមិនទទួលខុសត្រូវ ព្រហ្មទណ្ឌ**។

**ខ.១. ករណី ដែលចារីត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ**

ចារី បានប្រព្រឹត្តនូវអំពើលួចនោះ ដោយសារតែការផ្តួចផ្តើមរបស់**អ្នកផ្តើមគំនិត** ដែល អ្នកផ្តើមគំនិត គឺជាបុគ្គលណា ដែល៖

១-ជំរុញឱ្យប្រព្រឹត្តអំពើលួច តាមការណែនាំ ឬការបញ្ជា។

២-បង្កឱ្យមានអំពើលួច ដោយផ្តល់អំណោយ ដោយការសន្យា ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។[66]

ទោះបីជាទង្វើរបស់ចារីធ្វើឡើងក្រោមគំនិតផ្តួចផ្តើមពីអ្នកផ្តើមគំនិត ដែលជាអ្នកក្រៅ ក៏ដោយក្តី ក៏ចារីត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌនូវទង្វើទុច្ចរិតរបស់ខ្លួនដែរ ព្រោះចារីគ្មានហេតុផលស្របច្បាប់ណាដើម្បីលើកឡើង សម្រាប់ការមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ហើយទង្វើរបស់ចារីទៀតសោត ក៏សឹងមាននូវចរិតគ្រោះថ្នាក់ដល់សង្គមសាធារណៈផងដែរ។ ជាងនេះទៅទៀត អ្នកផ្តើមគំនិតនោះ ក៏ត្រូវទទួលខុសត្រូវដូចទៅនឹងចារី ដែលប្រព្រឹត្តបទល្មើសលួចនោះផងដែរ។[67]

**ឧទាហរណ៍** ចោរម្នាក់ តាមការបញ្ជារបស់នាយ **ក** បានចូលទៅលួចយកត្រា និង ឯកសារសំខាន់របស់ក្រុមហ៊ុន X ជាថ្នូរនឹងប្រាក់ ១០ ០០០(មួយម៉ឺន) ដុល្លារ។ អំពើលួច របស់ចោរ តាមការបញ្ជារបស់អ្នកផ្តើមគំនិត **ក** ជាបទល្មើសព្រហ្មទណ្ឌ ដែលកំហិតឱ្យមាន ការទទួលខុសត្រូវព្រហ្មទណ្ឌ។

**ខ.២. ករណី ដែលចារីមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

សម្រាប់ករណីនេះ ចារីនៃអំពើលួចបានប្រព្រឹត្តនូវបទល្មើសក្រោមការផ្តួចផ្តើមពីខាង ក្រៅក៏ពិតមែន ប៉ុន្តែចារីមិនតម្រូវឱ្យទទួលខុសត្រូវព្រហ្មទណ្ឌដូចករណីខាងលើនោះទេ។ ករណីនេះ មាន **២** គឺ៖ **ការប្រព្រឹត្តក្រោមអានុភាព ឬកម្លាំងបង្ខំ** និង**ការប្រព្រឹត្តក្នុងស្ថាន ភាពចាំបាច់**។

**ខ.២.១. ការប្រព្រឹត្តក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ**

កាលណាចារីនៃអំពើលួច ប្រព្រឹត្តបទល្មើសនោះឡើង ដោយសារមានអានុភាពនៃ កម្លាំង ឬការបង្ខំ ពីសំណាក់ឥទ្ធិពលខាងក្រៅមក ការប្រព្រឹត្តបទល្មើសក្នុងករណីនេះ មិនតម្រូវឱ្យចារីទទួលខុសត្រូវលើបទល្មើសនៃអំពើ

[66] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ៧ មាត្រា២៨។
[67] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ៧ មាត្រា២៨។

លួចទេ មានន័យថាករណីនេះ បទល្មើសលួច ដែលចារីប្រព្រឹត្តទៅហើយនោះ នៅតែជាបទល្មើសដដែល ប៉ុន្តែច្បាប់ព្រហ្មទណ្ឌមិនផ្តន្ទាទោសឱ្យចារីនោះទទួលខុសត្រូវទណ្ឌកម្មព្រហ្មទណ្ឌឡើយ។[68] បញ្ហានេះ បានកំណត់នៅក្នុងស្មារតីនៃ**មាត្រា ៣៦** នៃ**ក្រមព្រហ្មទណ្ឌ**ថា៖

*បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ ដែលបុគ្គលនេះមិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។*

*កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន។*[69]

ដោយផ្អែកលើកថាខណ្ឌទី២ នៃមាត្រាច្បាប់ខាងលើយើងអាចទាញបានថា អំពើលួច ដែលចារីប្រព្រឹត្តតាមឆន្ទៈផ្តួចផ្តើមពីខាងក្រៅ តម្រូវឱ្យបំពេញនូវលក្ខខណ្ឌ **២** ដើម្បីឱ្យ ទទួលបាននូវការសង្គ្រោះពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ **ទី១** គឺចារីត្រូវតែមិនអាចដឹង ឬមើលឃើញជាមុនពីអានុភាពនៃកម្លាំង ឬការបង្ខំ ដែលនឹងកើតមានមកលើខ្លួន និង**ទី២** គឺចារីមិនអាចជៀសវាងបាន ហើយត្រូវតែធ្វើ ឬប្រព្រឹត្តបទល្មើសលួចតាមកម្លាំងបង្ខំនោះ។

**ឧទាហរណ៍** គណនេយ្យករម្នាក់ ត្រូវបានខ្មាន់កាំភ្លើងភ្ជង់ឱ្យប្រគល់ប្រាក់ ដែលខ្លួនកំពុងកាន់កាប់ឱ្យទៅខ្មាន់កាំភ្លើង។ ក្នុងករណីដូច្នេះ គណនេយ្យកររូបនេះ មិនអាចត្រូវផ្តន្ទា ទោសពីការចូលរួមលួចទ្រព្យសម្បត្តិបានឡើយ[70] ដោយសារតែករណីនេះ គណនេយ្យករ ត្រូវបានរងការបង្ខំពីខ្មាន់កាំភ្លើង (ក្រៅឆន្ទៈ) គណនេយ្យករ គាត់ក៏មិនអាចដឹងថាថ្ងៃនោះមានខ្មាន់កាំភ្លើងចូលមកដែរ(មិនអាចមើលឃើញជាមុន) ហើយដូចគ្នានេះដែរ គណនេយ្យករក៏មិនអាចប្រឆាំងនឹងខ្មាន់កាំភ្លើងបានទៀត(មិនអាចជៀសវាងបាន)។

### ខ.២.២. ការប្រព្រឹត្តក្រោមស្ថានភាពចាំបាច់

ដូចទៅនឹងការបកស្រាយខាងលើដែរ កាលណាចារីនៃអំពើលួច ប្រព្រឹត្តបទល្មើសឡើងមកដោយសារស្ថានភាពចាំបាច់នោះ ចារីនៃអំពើលួចនោះមិនតម្រូវឱ្យទទួល ខុសត្រូវព្រហ្មទណ្ឌឡើយ។

ដោយយោងទៅលើ**មាត្រា៣៥ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ**[71] យើងទាញបានថា កាលបើចារី នៃអំពើលួចប្រព្រឹត្តបទល្មើស ក្នុងស្ថានភាពមួយ ដែលចាត់ទុកថាត្រឹមត្រូវ ដើម្បីការពារអ្នកដទៃ និងប្រឆាំងនឹងគ្រោះថ្នាក់ដែលកើតមាន ឬដែលនឹងកើតមាន ហើយថែមទាំងមានសមាមាត្ររវាងការប្រព្រឹត្ត និងស្ថានភាពចាំបាច់ទៀតនោះ ការលួច ដែលចារីប្រព្រឹត្ត នឹងមិននាំឱ្យចារីទទួលខុសត្រូវព្រហ្មទណ្ឌទេ។[72]

[68] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១០ មាត្រា៣៧។

[69] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១០ មាត្រា៣៦។

[70] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២ ទំព័រ២៤៥ ១.២.ការ បង្ខំផ្លូវចិត្ត ឧទាហរណ៍។

[71] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១០ មាត្រា៣៥។

[72] ស្ថានភាពចាំបាច់ចារី អាចជ្រើសរើសរវាងប្រព្រឹត្ត និងមិនប្រព្រឹត្តបទល្មើស រីឯអានុភាពនៃកម្លាំង ឬការបង្ខំ ចារីមិនមានជម្រើសផ្សេងក្រៅពីការប្រព្រឹត្តបទល្មើសនោះទេ។ ម៉្យាងវិញទៀត ស្ថានភាពចាំបាច់ជា យុត្តិកម្មនៃបទល្មើស ឯអានុភាពនៃកម្លាំង ឬការបង្ខំ ជាអត្តនោម័តនៃការមិនទទួល

**ឧទាហរណ៍** ដើម្បីកុំឱ្យកូនរបស់ខ្លួនអត់អាហារបរិភោគ ហើយអាចនឹងស្លាប់បាត់បង់ជីវិត ស្ត្រីជាម្តាយបានសម្រេចចិត្តទៅលួចអង្ករបស់គេយកមកចម្អិនដើម្បីចិញ្ចឹមកូន។ នេះគឺជាការបញ្ចៀសពីគ្រោះថ្នាក់ដល់អាយុជីវិតកូនរបស់ចារី ដែលបានប្រព្រឹត្តអំពើលួច។ ហេតុដូច្នេះ ចារីមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

**២.១.៣.៣. កម្មវត្ថុនៃអំពើលួច**

ការប្រព្រឹត្តអំពើលួចនេះ យើងឃើញថាចារី ដែលប្រព្រឹត្តបទល្មើសនេះ បានកំណត់នូវកម្មវត្ថុយ៉ាងច្បាស់លាស់ ដែលកម្មវត្ថុនេះយើងនឹងសិក្សាក្នុងបរិបទនៃទស្សនៈទាំងពីរ ដែលនីតិករខ្មែរធ្លាប់វែកញែកមក។

**ក. តាមទស្សនៈទី១**

កម្មវត្ថុនៃអំពើលួចនេះ គឺជនល្មើស មានចេតនាបំពាននូវច្បាប់ព្រហ្មទណ្ឌ ដែលបានកំណត់ទុកថាទង្វើនេះជាបទល្មើស ហើយជនឯណា ដែលប្រព្រឹត្តបំពាននឹងមានទោសទណ្ឌ។ ទោះបីជាបានដឹងថា ទង្វើបែបនេះត្រូវបានហាមប្រាមដោយច្បាប់ក៏ដោយក្តី ក៏ជនល្មើសមានចេតនាក្នុងការប្រព្រឹត្តផ្ទុយ ដើម្បីឱ្យខូចខាតដល់សណ្តាប់ធ្នាប់ដែលបានចងក្រងក្នុងច្បាប់នោះទៀត ពោលគឺច្បាប់ព្រហ្មទណ្ឌ គឺជាមុខសញ្ញា ដែលចារីចង់បង្កឱ្យមានព្យសនកម្មកើតឡើង។

**ខ. តាមទស្សនៈទី២**

ដូចបានបរិយាយនៅក្នុងសេចក្តីផ្តើមខាងលើអំពីបទដ្ឋានគតិយុត្តនានា ដែលបញ្ញត្តឡើងដើម្បីការពារនូវសិទ្ធិជាម្ចាស់កម្មសិទ្ធិលើទ្រព្យឯកជន ក៏ដូចជាសិទ្ធិខាងសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋមកហើយនោះ យើងឃើញថាការប្រព្រឹត្តនូវអំពើលួច គឺចារីមានចេតនកម្មក្នុងការបង្កឱ្យកើតមាននូវព្យសនកម្មលើកម្មវត្ថុ ដែលបញ្ញត្តិទាំងនោះបានការពារ ពោលគឺចារី មានចេតនាធ្វើឱ្យទ្រព្យសម្បត្តិ ឬវត្ថុ ផ្លាស់ទីចេញពីម្ចាស់របស់វាដោយទុច្ចរិត និងមានចរិតលក្ខណៈដកហូតនូវសិទ្ធិកម្មសិទ្ធិ ហើយថែមទាំងធ្វើឱ្យអ្នកដែលជាម្ចាស់ទ្រព្យនោះបាត់បង់នូវទ្រព្យសម្បត្តិ ឬវត្ថុរបស់ពួកគេ។ ដូច្នេះ តាមទស្សនៈទី២នេះ កម្មវត្ថុនៃបទល្មើស ដែលកើតឡើងដោយសារអំពើលួចនេះ គឺ**ទ្រព្យសម្បត្តិ ឬវត្ថុឯកជន** និង**ម្ចាស់នៃទ្រព្យសម្បត្តិ ឬវត្ថុឯកជននោះ** ដែលទាំងពីរយ៉ាងនេះ ជាមុខសញ្ញា ដែលចារីចង់បង្កឱ្យកើតមានព្យសនកម្ម។ ក្រៅពីអ្នកដែលជាម្ចាស់នៃទ្រព្យសម្បត្តិ ឬវត្ថុឯកជននោះទៅ ជនរងគ្រោះ ក៏អាចជាអ្នកកាន់កាប់ស្របច្បាប់ ឬអ្នកមានសិទ្ធិអាស្រ័យផលលើវត្ថុនោះជាដើម។[73]

## ២.២. ទោស និង អញ្ញត្រកម្មនៃទោស

ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ចារីត្រូវតែទទួលទោសទណ្ឌពីទង្វើទុច្ចរិត ដែលខ្លួនបានធ្វើ ប៉ុន្តែក្នុងករណីខ្លះក៏មានការលើកលែងមិនឱ្យទទួលទោសទណ្ឌផងដែរ ដែលការលើកលែងនេះតម្រូវឱ្យមានការកំណត់យ៉ាង

ខុសត្រូវព្រហ្មទណ្ឌ។ដើម្បីឱ្យយល់ច្បាស់សូមអាននៅក្នុង នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រី សាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១២ ទំព័រ២៣៨ ដល់២៧៥ ផ្នែកទី២ មូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬយុត្តិកម្មនៃបទល្មើស។

[73] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១៣-២០១៤ ១០.អំពើលួច។

ច្បាស់លាស់ក្នុងនីតិព្រហ្មទណ្ឌជានីតិវិជ្ជមាន។តួយ៉ាង ចារីនៃអំពើលួចនេះតម្រូវឱ្យទទួលទោសព្រហ្មទណ្ឌ ដូចដែលកំណត់ចាប់ពី **មាត្រា ៣៥៦** ដល់**មាត្រា៣៦០** ហើយក៏អាចឱ្យទទួលទោសបន្ថែមក្នុង**មាត្រា៣៦២** បានផងដែរ និង **មាត្រា៥០៩** ព្រមទាំងទោសបន្ថែមក្នុង**មាត្រា៥១២**ផង។ ប៉ុន្តែ នៅក្នុង**មាត្រា៣៥៥** នៃ**ក្រមព្រហ្មទណ្ឌ** ក៏មានចែងនូវអញ្ញត្រកម្មនៃទោសចំពោះអំពើលួចនេះផងដែរ។[74]

**២.២.១. ទោស**

**២.២.១.១. មូលទោស**

**ក. អំពើលួច ដែលជាបទមជ្ឈិម**

**បទមជ្ឈិម** គឺជាបទល្មើស ដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះ មានរយៈពេលលើសពី៦ថ្ងៃ និងក្រោម ឬ ស្មើ៥ ឆ្នាំ ហើយទោសដាក់ពន្ធនាគារ ក៏អាចបន្ថែមនូវទោសពិន័យជាប្រាក់បានផងដែរ។[75] ចំពោះអំពើលួច ដែលជាប្រភេទបទល្មើសមជ្ឈិមនោះ គឺមានចែងកំណត់ក្នុង**មាត្រា៣៥៦** និង**មាត្រា៥០៩** នៃ**ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩**។

**ក.១. អំពើលួចទ្រព្យសម្បត្តិសាមញ្ញ**

អំពើលួចទ្រព្យសាមញ្ញ ទាំងទ្រព្យរូបី និងអរូបី ដែលមិនមែនជាកម្មវត្ថុនៃស្ថានទម្ងន់ទោសនៃអំពើលួច ត្រូវផ្តន្ទាទោសតាម**មាត្រា៣៥៦** នៃ**ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩** ដែលមាន សេចក្តីចែងថា៖ *អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល*។[76]

**ក.២. អំពើលួចទ្រព្យសម្បត្តិ ឬវត្ថុរូបីពិសេស**

អំពើលួចនូវទ្រព្យសម្បត្តិ ឬវត្ថុរូបីពិសេស តួយ៉ាងបូជនីយវត្ថុព្រះពុទ្ធសាសនា គឺត្រូវ ផ្តន្ទាទោសតាម**មាត្រា ៥០៩** នៃ**ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩** ដែលចែងថា៖ *ដោយមិនទាន់គិត ដល់ទោសធ្ងន់ជាងគេ ដែលមានចែងក្នុងក្រមនេះ ការលួចបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា ដែលប្រព្រឹត្តនៅក្នុងបូជនីយដ្ឋានសាសនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់ លាន) រៀល*។

**ខ. អំពើលួច ដែលជាបទឧក្រិដ្ឋ**

បទឧក្រិដ្ឋ គឺជាបទល្មើស ដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវ៖

---

[74] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១១៦ ដល់១១៨ មាត្រា ៣៥៥ ដល់មាត្រា៣៦២ និងទំព័រ១៦៩ មាត្រា៥០៩ និងទំព័រ១៧០ មាត្រា៥១២។

[75] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១៣ មាត្រា៤៧។

[76] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១១៦ មាត្រា៣៥៦។

១-ជាទោសដាក់ពន្ធនាគារអស់មួយជីវិត។

២-ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមទោសពិន័យជាប្រាក់ផងដែរ។[77]

ដូច្នេះ អំពើលួចដែលជាបទឧក្រិដ្ឋមានចែងក្នុងមាត្រាដូចជា៖ **៣៥៧ ស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា, ៣៥៨ ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព, ៣៥៩ ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅ, ៣៦០ ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។[78]

**ខ.១. អំពើលួចដោយមានការប្រព្រឹត្តអំពើហិង្សា**

**មាត្រា ៣៥៧** នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា៖ ***អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ក្នុងករណី***

***១-អំពើលួច ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា។***

***២-អំពើលួចនេះ ប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយ។***[79]

មានន័យថា ទោះបីចោរីលួចយកទ្រព្យសម្បត្តិ ឬវត្ថុរបស់ជនរងគ្រោះនោះ មុនពេល ដែលចោរីប្រើហិង្សាលើជនរងគ្រោះ ឬលួចយកទ្រព្យសម្បត្តិ ឬវត្ថុនៅក្នុងខណៈពេល ដែលចោរីកំពុងប្រើហិង្សាលើជនរងគ្រោះ ឬម្យ៉ាងទៀត ចោរីប្រព្រឹត្តសកម្មភាពលួច នៅក្រោយពេល ដែលចោរីប្រើហិង្សាលើជនរងគ្រោះក៏ដោយ ការប្រព្រឹត្ត ដែលប្រកបដោយសកម្មភាពទុច្ចរិតធ្ងន់ធ្ងរនេះ នាំឱ្យសកម្មភាពរបស់ចោរី ជាអំពើលួច ដែលមានស្ថានទម្ងន់ទោស ព្រមទាំងជាបទល្មើសឧក្រិដ្ឋថែមទៀតផង។

ដូចទៅនឹងការប្រើហិង្សាដែរ កាលណាចោរីនៃអំពើលួច បានកាប់គាស់ទម្លុះទម្លាយដើម្បីចូលទៅលួច ទង្វើបែបនេះ នាំឱ្យចោរីនឹងទទួលនូវការផ្តន្ទាទោសបទល្មើសឧក្រិដ្ឋ ដែលកើតពីអំពើលួច ដែលមានស្ថានទម្ងន់ទោស។ ការកាប់គាស់ទម្លុះទម្លាយ ត្រូវបានកំណត់នូវនិយមន័យយ៉ាងច្បាស់ផងដែរ នៅក្នុង**ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា ៧៩** ដោយសេចក្តីថា៖ ***ការកាប់គាស់ទម្លុះទម្លាយ គឺជាអំពើបង្ខំធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញ គ្រឿងបិទទ្វារ ឬរបងទោះបីមានប្រភេទយ៉ាងណាក៏ដោយ។***

*ត្រូវចាត់ទុកដូចជាការកាប់គាស់ទម្លុះទម្លាយៈ*

*១-ការប្រើកូនសោក្លែង។*

[77] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១២ ដល់១៣ មាត្រា៤៦។

[78] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១១៦ ដល់១១៧ មាត្រា ៣៥៧ ដល់មាត្រា៣៦០។

[79] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១១៦ ដល់១១៧ មាត្រា៣៥៧។

*២-ការប្រើប្រាស់កូនសោ ដែលបានមកដោយឧបាយកលទុច្ចរិត។*

*៣-ការប្រើប្រាស់ឧបករណ៍ ដើម្បីធ្វើឱ្យគ្រឿងបិទមានដំណើរការដោយគ្មានការបង្ខំ ការខូចខាត ឬការបំផ្លិចបំផ្លាញទេ។* [80]

**ខ.២. អំពើលួចដោយមានការកាត់អវយវៈ ឬពិការភាព**

មាត្រា ៣៥៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា៖ *អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា ដែលនាំឱ្យមានការកាត់កាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍។*[81]

មានន័យថា កាលបើចារី បានប្រព្រឹត្តអំពើលួចមុនពេល ឬក្នុងពេល ឬក៏ក្រោយពេល ដែលចារីនោះប្រើហិង្សាលើជនរងគ្រោះ ដែលហិង្សានោះ គឺជាការកាត់នូវអវយវៈរបស់ជនរងគ្រោះ ឬហិង្សា ដែលចារីប្រព្រឹត្តលើជនរងគ្រោះនោះ នាំឱ្យជនរងគ្រោះពិការ ដែលការពិការនោះ ជាពិការភាពអចិន្ត្រៃយ៍ ពោលគឺអស់មួយជីវិត មិនអាចព្យាបាលឱ្យដូចដើមបាន ចារីនៃអំពើលួចក្នុងស្ថានភាពបែបនេះ ត្រូវទទួលទោសទៅតាមស្ថានទម្ងន់ទោសនៃមាត្រាច្បាប់ខាងលើ។

នៅក្នុងបញ្ហានេះ ទស្សនទានមួយចំនួនចំនួនចំពោះនិយមន័យនៃពាក្យ **អវយវៈ** និងពាក្យ **ពិការភាព** គួរតែបានយកមកពិនិត្យផងដែរ។

ពាក្យថា អវយវៈ ត្រូវបានផ្តល់នូវនិយមន័យតាម**វចនានុក្រមខ្មែរ**ថា *អង្គ, រូបអង្គ, រូបរាង, សព៌ាង្គ, រាងកាយខ្លួនប្រាណ, ចំណែក, ប៉ែក ឬចំណែកតូចធំនៃរូបរាងកាយ: អវយវៈតូចធំ សព៌ាង្គកាយ មានដៃជើងជាដើម។*[82] ដូចនេះ តាមន័យនេះ អវយវៈ ហាក់មានវិសាលភាពនៃការបកស្រាយទូលាយរហូត ដល់មិនមែនត្រឹមតែដៃនិងជើងប៉ុណ្ណោះទេ ពោលគឺជាផ្នែកនៃរាងកាយនានា។ ដើម្បីកំណត់ថាជាស្ថានទម្ងន់ទោសនេះ គឺត្រូវផ្អែកលើសភាពធ្ងន់ធ្ងរនៃការខូចខាតរបស់ជនរងគ្រោះ[...]។ ចៅក្រមត្រូវគិតគូរអំពីអន្តរាយ ដែលកើតឡើងទៅអនាគតផងដែរ ហើយនឹងត្រូវអនុវត្តស្ថានទម្ងន់ទោស តែនៅពេលដែលមានពិការភាព ព្រមទាំងសភាពកាន់តែធ្ងន់ធ្ងរនៃអន្តរាយតែប៉ុណ្ណោះ។[83] ដូចនេះ ផ្នែកនៃរាងកាយ ដែលត្រូវកាត់ផ្តាច់ ហើយត្រូវនិគ្រោះដោយបញ្ញត្តិនៃស្ថានទម្ងន់ទោសនេះ ត្រូវតែជាផ្នែកនៃរាងកាយដែលមានលក្ខណៈសំខាន់ ហើយការកាត់ផ្តាច់នូវផ្នែកនៃរាងកាយនោះ នាំមកនូវអន្តរាយយ៉ាងធ្ងន់ធ្ងរ ហើយនឹងអាចបង្កជាផលវិបាកដល់ថ្ងៃអនាគតផងដែរ។ តួយ៉ាងការកាត់ ដៃ ជើង ម្រាមដៃ ម្រាមជើង ត្រចៀក ច្រមុះ ជាដើម។ ដោយ

[80] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ២១ ដល់២២ មាត្រា៧៩។

[81] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១១៧ មាត្រា៣៥៨។

[82] វចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ គ.ស. ១៩៦៧ ទំព័រ ១២៧៩។

[83] សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី វិភាគទានចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ បោះពុម្ពផ្សាយ ឆ្នាំ២០០៥ ទំព័រ១៩៦ មាត្រា កម ២២២២-៧ ស្ថានទម្ងន់ទោសដែលបណ្តាលមកពីមានការកាត់ផ្តាច់អវយវៈ និងពិការភាព។

ឡែក ការកាត់សក់ ឬដកធ្មេញ មិនអាចជាការកាត់អវយវៈនោះទេ ព្រោះវាមិនមែនជាផ្នែក ដែលមានភាពសំខាន់ខ្លាំង ហើយអន្តរាយ ដែលកើតចេញពីទង្វើនេះមិនធ្ងន់ធ្ងរនោះទេ ពោលគឺងាយនឹងជួសជុលការខូចខាត ព្រោះសក់ក៏អាចដុះវិញ ធ្មេញក៏អាចដាក់បាន ដោយមិនពិបាកដូចនឹងការកាត់អវយវៈដូចជា ដៃ ជើង ម្រាមដៃ ម្រាមជើង ជាដើម ដែលមិនងាយនឹងជួសជុលការខូចខាត ឬករណីខ្លះមិនអាចតភ្ជាប់ឱ្យដូចដើមវិញផង។

ចំណែកឯពាក្យ ពិការភាព ដោយផ្អែកតាម**ប្រកាសអន្តរក្រសួងស្តីពី ការកំណត់លក្ខណវិនិច្ឆ័យប្រភេទ និងកម្រិតពិការភាព របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រសួងសុខាភិបាល លេខ ២៤៩២ សអយ/បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១** បានផ្តល់និយមន័យតាមរយៈពាក្យថា ជនពិការ ថា *ជាជនទាំងឡាយណា ដែលខ្វះខាត បាត់បង់ ខូចខាតសរីរាង្គណាមួយ ឬសតិបញ្ញា បណ្តាលឱ្យមានការរំខានដល់ជីវភាពរស់នៅ ឬសកម្មភាពនានាប្រចាំថ្ងៃ ដូចជា ជនពិការរាងកាយ ពិការភ្នែក ពិការក្នុងការស្តាប់ ពិការសតិបញ្ញា មនសិការវិកល និងប្រភេទពិការផ្សេងៗទៀត ដែលនាំឱ្យមានលក្ខណៈមិនប្រក្រតី*។[84] ដូចនេះពិការភាព មិនមែនត្រឹមតែពិការកាយសម្បទានោះទេ ពោលគឺមានវិសាលភាពហូតដល់ពិការសតិបញ្ញា មនសិការវិកល ជាដើមទៀតផង។ ការបកស្រាយលម្អិតមានកំណត់ក្នុងសេចក្តីប្រកាសនេះត្រង់**ប្រការ៤ ប្រការ៥ និងប្រការ៦** ដែលមានក្នុងឧបសម្ព័ន្ធ។

**ខ.៣. អំពើលួចដោយមានការធ្វើទារុណកម្ម ឬអំពើឃោរឃៅ**

**មាត្រា ៣៥៩** នៃ**ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩** បានបញ្ញត្តថា៖ *អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្ត មុនពេល ក្នុងពេល ឬក្រោយពេលប្រើទារុណកម្ម ឬអំពើឃោរឃៅ។*[85]

មិនខុសពីមាត្រាមុនៗ បើសិនជាអំពើលួច ដែលចារីប្រព្រឹត្ត បានធ្វើឡើងមុនពេល ឬក្នុងពេល ឬក៏ក្រោយពេល ដែលចារីបានធ្វើទារុណកម្មលើជនរងគ្រោះ ឬធ្វើបាបជនរង គ្រោះដោយអំពើឃោរឃៅនោះ សកម្មភាពនេះជាអំពើលួច ដែលមានស្ថានទម្ងន់ទោស ដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅ។

ដើម្បីឱ្យកាន់តែច្បាស់លាស់ យើងក៏គួរស្វែងយល់ពីន័យនៃពាក្យទារុណកម្ម និងអំពើឃោរឃៅផងដែរ។ នៅក្នុង**អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប** បានកំណត់អំពីនិយមន័យនៃពាក្យ ទារុណកម្ម តាមរយៈមាត្រា១ ថា៖ *អំពើទាំងឡាយណា ដែលនាំឱ្យមានការឈឺចាប់ ឬរងទុក្ខយ៉ាងខ្លាំង ទោះផ្លូវកាយ ឬផ្លូវចិត្ត ដែលបង្កឡើងដោយចេតនាទៅលើជនណាម្នាក់ ក្នុងគោលបំណងទាំងឡាយដូចជា ការទាញយកពត៌មាន ឬចម្លើយសារភាពពីជននោះ ឬតតិយជនណាម្នាក់ ដាក់ទណ្ឌកម្មជននោះចំពោះអំពើណាមួយ ដែលជននោះ ឬតតិយជនណាម្នាក់បានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬបំភិតបំភ័យ*

[84] ប្រកាសអន្តរក្រសួង ស្តីពីការកំណត់លក្ខណវិនិច្ឆ័យប្រភេទ និងកម្រិតពិការភាព លេខ២៤៩២ សអយ/បក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១។
[85] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១១៧ មាត្រា៣៥៩។

*ឬបង្ខិតបង្ខំជននោះ ឬគតិយជនណាម្នាក់ ឬដោយមូលហេតុផ្សេងទៀត ដែលផ្អែកលើការរើសអើងណាមួយ បើការឈឺចាប់ ឬការរងទុក្ខដោយសារតែតាមការញុះញង់ ឬការព្រមព្រៀង ឬការផ្តើមគំនិត របស់មន្ត្រីសាធារណៈ ឬជនផ្សេងទៀត ដែលបំពេញតួនាទីជាផ្លូវការ។*

មិនមែនរាល់ការឈឺចាប់ ឬការរងទុក្ខ សុទ្ធតែត្រូវបានចាត់ទុកថាជាការធ្វើទារុណកម្ម នោះទេ បើតាមគោលបំណងនៃអនុសញ្ញានេះ គឺតម្រូវឱ្យមានធាតុផ្សំសំខាន់ៗ មួយចំនួន ដូចខាងក្រោមនេះ :

- ការឈឺចាប់ ឬការរងទុក្ខ ត្រូវតែបានបង្កឡើងដោយចេតនា ឬជាប្រព័ន្ធ មិនមែនដោយសារតែឧប្បត្តិហេតុ និងមិនមែនបណ្តាលមកពីការដាក់ទណ្ឌកម្មតាមផ្លូវច្បាប់នោះឡើយ។
- ការឈឺចាប់ ឬការរងទុក្ខ ត្រូវតែបានបង្កឡើងដោយមន្ត្រីសាធារណៈណាម្នាក់ ដូចជានគរបាល មន្ត្រីពន្ធនាគារ ឬមន្ត្រីយោធា ឬដោយមានការព្រមព្រៀង ឬតាមការញុះញង់ពីមន្ត្រីទាំងនោះ។
- ការឈឺចាប់ ឬការរងទុក្ខ ត្រូវតែដើម្បីទាញយកពត៌មាន ឬបង្ខំឱ្យឆ្លើយសារភាព ដោយធ្វើទណ្ឌកម្ម បំភិតបំភ័យ ឬដើម្បីហេតុផលណាមួយ ដោយផ្អែកលើការរើសអើងណាមួយ។[86]

រីឯ **អំពើឃោរឃៅ** ហាក់មានលក្ខណៈទូលាយក្នុងការបកស្រាយ ព្រោះពុំមានច្បាប់ជាវិជ្ជមានណាកំរិតនូវវិសាលភាពនៃន័យរបស់ពាក្យ អំពើឃោរឃៅ នោះទេ។ ប៉ុន្តែ បើតាម **វចនានុក្រមខ្មែរ** ឃោរឃៅ មានថ្នាក់ពាក្យជាគុណនាម ដែលមានន័យថា ខ្លាំងក្រៃ, ពន្លឹកគួរ ឱ្យខ្លាច, ហៅហាន, មោះមុត, កាចខ្លាំងឥតមេត្តាប្រណី។[87] ដូច្នេះ បើនិយាយឱ្យងាយ អំពើឃោរឃៅ គឺជាអំពើ ដែលកាចមោះមុតខ្លាំងក្រៃឥតមេត្តាប្រណី ពោលគឺអំពើ ដែលសាហាវព្រៃផ្សៃ។ ហេតុនេះ ចារីនៃអំពើឃោរឃៅ មិនតម្រូវតែជាមន្ត្រីសាធារណៈដូចទារុណកម្មនោះទេ ពោលគឺចារីនៃអំពើឃោរឃៅ អាចជាសាមញ្ញជនធម្មតា ដែលធ្វើបាបលើជនរងគ្រោះយ៉ាងសាហាវឃោរឃៅយង់ឃ្នង។

### ខ.៤. អំពើលួចក្នុងស្ថានភាព ដែលជនរងគ្រោះបាត់បង់ជីវិត

មាត្រា ៣៦០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា៖ *អំពើលួចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា ដែលបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់។*[88]

---

[86] អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោក បន្ទាប និងពិធីសារបន្ថែម អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ បកប្រែ ក្រៅផ្លូវការដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា សូមមើលក្នុង តំណភ្ជាប់នេះ៖ https://cambodia.ohchr.org/sites/default/files/Treaty/CAT-KH.pdf ។

[87] វចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ គ.ស. ១៩៦៧ ទំព័រ ១១៨។

[88] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១១៧ មាត្រា៣៦០។

ក្នុងករណីនេះ បើសិនជាចារីនៃអំពើលួច បានប្រព្រឹត្តសកម្មភាពលួច មុនពេល ក្នុងពេល ឬក្រោយពេល ដែលចារីបានប្រើហិង្សាលើជនរងគ្រោះ រហូតជ្រុលដៃធ្វើឱ្យជនរងគ្រោះស្លាប់ដោយអចេតនានោះ ចារីនៃអំពើលួចនេះ ត្រូវផ្តន្ទាទោសក្នុងស្ថានភាពនៃស្ថានទម្ងន់ទោសតាមបញ្ញត្តិខាងលើ។

**២.២.១.២. ទោសបន្ថែម**

**ក.ទោសបន្ថែមចំពោះអំពើលួចទ្រព្យសម្បត្តិ ឬវត្ថុសាមញ្ញ**

ចំពោះទោសបន្ថែម ដែលអាចប្រកាសបន្ថែមនៅក្នុងករណីនៃអំពើលួចទ្រព្យសម្បត្តិ ឬវត្ថុសាមញ្ញ មានបញ្ញត្តក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៣៦២ ថា៖ *ចំពោះបទល្មើស ដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែម ដូចតទៅនេះ អាចត្រូវប្រកាស:*

*១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។*

*២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។*

*៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។*

*៤-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម។*

*៥-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។*

*៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។*

*៧-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។*

*៨-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស។*

*៩-ការរឹបអូសឧបភោគភណ្ឌ*[89] *សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែង ដែលបទល្មើស នោះបានប្រព្រឹត្ត។*

*១០-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង។*

*១១-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។*

---

[89] ឧបភោគភណ្ឌ មានន័យថា ឧបករណ៍ប្រើប្រាស់ប្រចាំជីវភាពធម្មតា របស់ ឬអីវ៉ាន់សម្រាប់ប្រើប្រាស់ជិតៗខ្លួន។ (សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកក្រមព្រហ្មទណ្ឌ បោះពុម្ពផ្សាយដោយ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ ទំព័រ៧៥ លេខ២២៥០)។

*១២-ការបិទគ្រឹះស្ថាន ដែលប្រើប្រាស់សម្រាប់ត្រៀម ឬប្រព្រឹត្តបទល្មើសជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។*

*១៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។*

*១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែយ៉ាងច្រើន។*

*១៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារពត៌មាន។*

*១៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន។*[90]

**ខ. ទោសបន្ថែមចំពោះអំពើលួចបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា**

ចំពោះអំពើលួចបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា ទោសបន្ថែម ដែលអាចប្រកាស បន្ថែមមានចែងក្នុង**មាត្រា ៥១២** នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ថា៖ *ចំពោះបទល្មើស ដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែម ដូចតទៅនេះ អាចត្រូវប្រកាសៈ*

*១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។*

*២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។*

*៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។*

*៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន។*

*៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារពត៌មាន។*

*៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន។*[91]

**២.២.២. អញ្ញត្រកម្មនៃទោស**

[90] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១១៧ ដល់១១៨ មាត្រា៣៦២។

[91] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១៧០ មាត្រា៥១២។

ទោះបីអំពើលួច ត្រូវបានច្បាប់ចាត់ទុកថាជាបទល្មើសក៏ពិតមែន ប៉ុន្តែច្បាប់ក៏មាន ចែងនូវអញ្ញត្រកម្ម[92]ផងដែរ ពោលគឺកាលណាចារីនៃអំពើលួច បានលួចនូវទ្រព្យសម្បត្តិ ឬវត្ថុ ដែលជារបស់បុព្វញាតិ បច្ឆាញាតិ ឬសហព័ទ្ធ ការលួចនេះ មិនអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាននោះទេ។[93] តើអ្វីទៅជាបុព្វញាតិ បច្ឆាញាតិ និងសហព័ទ្ធ?

បុព្វញាតិ តាមន័យទូទៅ មានន័យដូចបុព្វជន។ តាមក្រមរដ្ឋប្បវេណី មានន័យថា ជន ដែលស្ថិតក្នុងថ្នាក់ញាតិខ្ពស់ជាងខ្លួន។ **ឧទាហរណ៍** ជីដូន ជីតា ឪពុក ម្តាយ មា មីង ជា បុព្វញាតិរបស់ ចៅ កូន ក្មួយ...។[94] ដូច្នេះ ការលួចនូវទ្រព្យសម្បត្តិរបស់បុគ្គល ដូចដែលបាន ពណ៌នានេះ ពុំអាចផ្តន្ទាទោសព្រហ្មទណ្ឌបានឡើយ។

បច្ឆាញាតិ ឬបច្ឆាជន មានន័យថា ជន ឬពួកជន ដែលកើតពីជនមួយពួកទៀត។ ឧទាហរណ៍ កូន ជាបច្ឆាញាតិរបស់ឪពុកម្តាយ។ ចៅ ជាបច្ឆាញាតិរបស់ជីដូនជីតា។[95] អាច និយាយឱ្យងាយយល់ថាជា ញាតិជំនាន់ក្រោយ ដែលកើតក្រោយខ្លួន។ ត្រង់នេះ ការលួច នូវទ្រព្យសម្បត្តិរបស់បុគ្គលដូចដែលបានពណ៌នានេះ ពុំអាចផ្តន្ទាទោសព្រហ្មទណ្ឌបានឡើយ។

ចំណុចរួមនៃបុព្វញាតិ ឬបច្ឆាញាតិ ត្រូវតែជាញាតិលោហិត ឬញាតិ ដែលឆ្លងកាត់ ស្មុំកូនតាមច្បាប់។ បើសិនជាញាតិ ដែលរាប់អាន ដូចជាមិត្តភក្តិ បងប្អូនធម៌ ពុំស្ថិតនៅក្នុងដែននៃការបកស្រាយនៃអញ្ញត្រកម្មនេះឡើយ ពោលគឺ បើសិនជាទៅលួច ទ្រព្យរបស់បងប្អូនធម៌ ឬមិត្តភក្តិ ចារីនៃអំពើលួចនោះត្រូវទទួលការផ្តន្ទាទោសព្រហ្មទណ្ឌដដែល។

ផ្ទុយមកវិញ ការលួចទ្រព្យសម្បត្តិ ឬវត្ថុរបស់ញាតិពន្ធ[96] ចារីត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមរយៈការផ្តន្ទាទោសលើបទល្មើស ដែលខ្លួនបានប្រព្រឹត្ត។

សហព័ទ្ធ មានន័យថា ប្តី ឬប្រពន្ធ ឬទាំងប្តី ទាំងប្រពន្ធ ដែលទទួលបានឋានៈជា សហព័ទ្ធនេះ ក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។[97] ក្នុងករណីនេះ ជនរងគ្រោះនៃអំពើលួច ត្រូវតែជាសហព័ទ្ធពេញច្បាប់ ពោលគឺចំណងអាពាហ៍ពិពាហ៍តាមច្បាប់នៅគង់វង្សនៅឡើយ ទើបចារីមិនត្រូវផ្តន្ទាទោសព្រហ្មទណ្ឌពីអំពើលួចដែលខ្លួនបានប្រព្រឹត្ត។ ផ្ទុយពីនេះ បើសិនជាទំនាក់ទំនងនៃអាពាហ៍ពិពាហ៍តាមច្បាប់ត្រូវរលត់តាមការលែងលះ ការ

[92] អញ្ញត្រកម្ម មានន័យថា ដោយឡែក លើកលែង ករណីពិសេស។

[93] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១១៦ មាត្រា៣៥៥។

[94] សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី បោះពុម្ពផ្សាយដោយ ទីស្តីការ គណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ ទំព័រ ១៣ លេខ៩៣។

[95] សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកក្រមព្រហ្មទណ្ឌ បោះពុម្ពផ្សាយដោយ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ ទំព័រ៥៩ លេខ១៩០។

[96] ញាតិពន្ធ ជាចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង និងញាតិលោហិត របស់សហព័ទ្ធម្ខាងទៀត(សាច់ថ្លៃ)។(សទ្ទានុក្រម ពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី បោះពុម្ពផ្សាយដោយ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ ទំព័រ៦ លេខ៤១)។

[97] សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី បោះពុម្ពផ្សាយដោយ ទីស្តីការ គណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ ទំព័រ ២២ លេខ១៥០។

លួចនូវទ្រព្យរបស់អតីតសហព័ទ្ធ ចារីនឹងត្រូវផ្តន្ទាទោស ហើយដូចគ្នានេះដែរ បើសិនចារី លួចនូវទ្រព្យវត្ថុរបស់បុរស ឬនារីឯណា ដែលខ្លួនចាត់ទុកបីដូចជាប្តីប្រពន្ធ តែពុំទាន់បង្កើតឱ្យមាននូវគតិយុត្តភាពនៃទំនាក់ទំនងនេះ ឬហៅថា អនីតិសង្វាសជន[98] ចារី ក៏ត្រូវផ្តន្ទាទោសទៅតាមច្បាប់ព្រហ្មទណ្ឌចំពោះទង្វើលួចរបស់ខ្លួនផងដែរ។

[98] សូមមើលសទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកក្រមព្រហ្មទណ្ឌ បោះពុម្ពផ្សាយដោយ ទីស្តីការគណៈ រដ្ឋមន្ត្រី ឆ្នាំ២០១១ ទំព័រ៦៩ លេខ២៣១។

# ជំពូកទី២
# បទល្មើស ដែលស្រដៀងទៅនឹងអំពើលួចក្នុងក្រមព្រហ្មទណ្ឌ

បទល្មើសមួយចំនួន ដែលមាននៅក្នុងច្បាប់ដោយឡែកផ្សេងៗទៀត ក៏ដូចជាក្នុងក្រមព្រហ្មទណ្ឌផងនោះ មានបទល្មើសខ្លះហាក់ដូចជាស្រដៀងទៅនឹងអំពើលួច ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌផងដែរ។ ដូច្នេះដើម្បីឱ្យការសិក្សាលើអំពើលួច កាន់តែច្បាស់លាស់នោះ យើងក៏គប្បីរើកញែកនូវបទល្មើស ដែលស្រដៀងទៅនឹងអំពើលួចនេះដែរ។

## ១. បទល្មើសលួចក្នុងបញ្ញត្តិច្បាប់ផ្សេងទៀត

### ១.១. ការលួចទ្រព្យសម្បត្តិវប្បធម៌

ការលួចវត្ថុបុរាណ គឺជាបទល្មើសមួយ ដែលធ្លាប់មាននៅក្នុងបញ្ញត្តិព្រហ្មទណ្ឌពីអតីតកាលរបស់កម្ពុជា គឺច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល **មាត្រា ៤៤ កថាខណ្ឌទី១** ដោយ មានសេចក្ដីថា៖ *១-គ្រប់ជន ដែលលួច ឬប៉ុនប៉ងលួចទ្រព្យសម្បត្តិវប្បធម៌ ដែលជារបស់រដ្ឋ ឬរបស់ឯកជនជារូបវន្តបុគ្គល ឬនីតិបុគ្គល ហើយសម្បត្តិវប្បធម៌នោះចូលជាបេតិកភណ្ឌជាតិកម្ពុជា ត្រូវផ្ដន្ទាទោសដាក់គុកពី ៦ខែ ទៅ ១០ឆ្នាំ។ ជនណា ដែលនាំចេញ ឬប៉ុនប៉ងនាំចេញ ឬផ្ទេរកម្មសិទ្ធិសម្បត្តិវប្បធម៌ដោយខុសច្បាប់ ត្រូវមានទោសដូចគ្នា។*[99]

ចំណុចសំខាន់របស់កថាខណ្ឌទី១ នៃមាត្រាខាងលើ ការលួចនោះ គឺជាការលួចទ្រព្យ សម្បត្តិវប្បធម៌ ហើយទ្រព្យសម្បត្តិវប្បធម៌នោះទៀតសោត ត្រូវតែចូលជាបេតិកភណ្ឌជាតិកម្ពុជា។ តើអ្វីទៅជា **ទ្រព្យសម្បត្តិវប្បធម៌** ហើយអ្វីទៅជា **បេតិកភណ្ឌជាតិកម្ពុជា**?

នៅក្នុង**កថាខណ្ឌទី២** នៃមាត្រាដដែល បានបញ្ញត្តថា៖ *២-តាមគោលបំណងនៃ បទប្បញ្ញត្តិនេះ សម្បត្តិវប្បធម៌ គឺជាសម្បត្តិទាំងឡាយ ដែលកំណត់ដោយអនុសញ្ញារបស់ អ៊ុយណេស្កូ ស្ដីពីវិធានការដែលត្រូវចាត់ ដើម្បីហាមឃាត់ និងរារាំងនូវការនាំចូល ការនាំចេញ និងការផ្ទេរកម្មសិទ្ធិសម្បត្តិវប្បធម៌ដោយខុសច្បាប់ ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ១៩៧០ ដែលប្រទេសកម្ពុជាបានឱ្យសច្ចានុម័តនៅថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ១៩៧២។ដែលសន្មតថា ជាបេតិកភណ្ឌជាតិកម្ពុជា គឺជាសម្បត្តិវប្បធម៌ទាំងអស់ ដែលមិនទាន់ទទួលការអនុញ្ញាតពីក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ឬអង្គការចាត់តាំងដើម្បីគោលបំណងនេះ ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់នេះឱ្យផ្ទេរ ឬនាំចេញ។*[100] **អនុសញ្ញារបស់អ៊ុយណេស្កូ ស្ដីពីវិធានការ ដែលត្រូវចាត់ ដើម្បីហាមឃាត់ និងរារាំងនូវការនាំចូល ការនាំចេញ និងការផ្ទេរកម្មសិទ្ធិសម្បត្តិវប្បធម៌ដោយខុសច្បាប់ ឆ្នាំ១៩៧០ មាត្រា១** បានបញ្ញត្តិថា៖

---

[99] មគ្គុទ្ទេសក៍ ស្ដីពីនីតិវិធីព្រហ្មទណ្ឌខ្មែរ ការស៊ើបអង្កេត និងការស៊ើបសួរត្រៀម បោះផ្សាយ ឆ្នាំ២០០៥ ទំព័រ៥៨ មាត្រា៤៤ កថាខណ្ឌទី១។

[100] មគ្គុទ្ទេសក៍ ស្ដីពីនីតិវិធីព្រហ្មទណ្ឌខ្មែរ ការស៊ើបអង្កេត និងការស៊ើបសួរត្រៀម បោះផ្សាយ ឆ្នាំ២០០៥ ទំព័រ៥៨ មាត្រា៤៤ កថាខណ្ឌទី២។

*For the purposes of this Convention, the term `cultural property' means property which, on religious or secular grounds, is specifically designated by each State as being of importance for archaeology, prehistory, history, literature, art or science and which belongs to the following categories:*

*(a) Rare collections and specimens of fauna, flora, minerals and anatomy, and objects of palaeontological interest;*

*(b) property relating to history, including the history of science and technology and military and social history, to the life of national leaders, thinkers, scientists and artist and to events of national importance;*

*(c) products of archaeological excavations (including regular and clandestine) or of archaeological discoveries;*

*(d) elements of artistic or historical monuments or archaeological sites which have been dismembered;*

*(e) antiquities more than one hundred years old, such as inscriptions, coins and engraved seals;*

*(f) objects of ethnological interest;*

*(g) property of artistic interest, such as:*

*(i) pictures, paintings and drawings produced entirely by hand on any support and in any material (excluding industrial designs and manu-factured articles decorated by hand);*

*(ii) original works of statuary art and sculpture in any material;*

*(iii) original engravings, prints and lithographs;*

*(iv) original artistic assemblages and montages in any material;*

*(h) rare manuscripts and incunabula, old books, documents and publications of special interest (historical, artistic, scientific, literary, etc.) singly or in collections;*

*(i) postage, revenue and similar stamps, singly or in collections;*

*(j) archives, including sound, photographic and cinematographic archives;*

*(k) articles of furniture more than one hundred years old and old musical instruments.*[101]

មានកំណត់ប្រែក្រៅផ្លូវការជាភាសាខ្មែរថា ៖

សម្រាប់គោលបំណងនៃអនុសញ្ញានេះ ពាក្យ `**សម្បត្តិវប្បធម៌**' មានន័យថា ទ្រព្យសម្បត្តិ ដែលផ្តោតលើ សាសនា ឬឫសគល់នៃប្រវត្តិសាស្ត្រ ដែលត្រូវបានកំណត់ជាពិសេសដោយរដ្ឋនីមួយៗ វាមានសារៈសំខាន់សម្រាប់ បុរាណវិទ្យា បុរេប្រវត្តិ ប្រវត្តិសាស្ត្រ អក្សរសិល្ប៍ សិល្បៈ ឬវិទ្យាសាស្ត្រ ដែលពាក់ព័ន្ធជាមួយប្រភេទខាងក្រោម៖

(a) ការប្រមូលនូវវត្ថុកម្រ និងសំណាកនៃពពួកសត្វរុក្ខជាតិ សារធាតុរ៉ែ កាយវិភាគសាស្ត្រ និងវត្ថុដែល ទាក់ទងខាងបុរាណវិទ្យា។

(b) ទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រវត្តិសាស្ត្រ រួមទាំងប្រវត្តិនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា ប្រវត្តិសាស្ត្រយោធា សង្គម និងជីវប្រវត្តិនៃមេដឹកនាំថ្នាក់ជាតិ អ្នកប្រាជ្ញ អ្នកវិទ្យាសាស្ត្រ សិល្បករ និងព្រឹត្តិការណ៍សំខាន់ៗរបស់ជាតិ។

(c) សមិទ្ធផលនៃការជីកកកាយបុរាណវិទ្យា (រួមមានការជីកកកាយនៅទីតាំងបើកចំហ និងកន្លែងអាថ៌កំបាំង) ឬការរុករកឃើញនៃបុរាណវិទ្យា។

(d) ធាតុនៃសិល្បៈ ឬទីតាំងនៃប្រវត្តិសាស្ត្រ ឬក៏បុរាណដ្ឋាន ដែលត្រូវបានរុះរើ

(e) វត្ថុបុរាណដែលមានអាយុលើសពីមួយរយឆ្នាំដូចជាសិលាចារឹក កាក់ និងត្រាឆ្លាក់។

(f) វត្ថុដែលទាក់ទងនឹងជាតិពន្ធុវិទ្យា;

(g) ទ្រព្យសម្បត្តិដែលទាក់ទងនឹងសិល្បៈដូចជា៖

(I) រូបភាព គំនូរលាបពណ៌ និងគំនូរដែលត្រូវបានបង្កើតឡើងដោយដៃ និងមានរួមបញ្ចូលនូវឧបករណ៍ជំនួយ ហើយនិងវត្ថុធាតុដើមផ្សេងៗ (ដែលមិនរួមបញ្ចូលការរចនាបែបឧស្សាហកម្ម និងការតុបតែងជាលក្ខណៈផលិត ដោយដៃ);

(II) ស្នាដៃដើមនៃសិល្បៈរូបសំណាក និងចម្លាក់ ដែលផលិតឡើងដោយគ្រប់រូបធាតុ;

(III) ចម្លាក់ដើម ការថតចម្លង និងការបោះពុម្ពដោយប្រើពុម្ពថ្ម

(IV) បង្គុំសិល្បៈដើម និងរូបភាពកាត់តតាមគ្រប់រូបធាតុទាំងអស់

(h) សាស្ត្រាស្លឹករឹត និង Incunabula[102] ដ៏កម្រ សៀវភៅចាស់ៗ ឯកសារចាស់ៗ និងការបោះពុម្ពផ្សាយ ដែលទាក់ទងទៅនឹង (ប្រវត្តិសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ។ល។) ទោល ឬបណ្តុំ។

(i) តែមប្រៃសណីយ៍ តែមពន្ធ និងត្រាស្រដៀងគ្នា ទោល ឬបណ្តុំ។

(j) បណ្ណសារ រួមទាំងឯកសារសំឡេង រូបថត និងភាពយន្ត។

---

[101] សូមមើលក្នុងតំណភ្ជាប់ខាងក្រោម៖
http://portal.unesco.org/en/ev.php-URL_ID=13039&URL_DO=DO_TOPIC&URL_SECTION=201.html ។

[102] Incunabula ឬ Incunable ជាសៀវភៅបុរាណ ដែលធ្វើពីស្បែកសត្វ។

(k) គ្រឿងសង្ហារិម ដែលមានអាយុកាលលើសពីមួយរយឆ្នាំ និងឧបករណ៍ភ្លេងចាស់ៗ។

ប៉ុន្តែ**ច្បាប់ឆ្នាំ១៩៩៦ស្តីពីកិច្ចការការពារបេតិកភណ្ឌវប្បធម៌** ធ្វើឱ្យ**មាត្រា៤៤**លែងមានប្រសិទ្ធភាព។[103] ពោលគឺនៅក្នុងច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌មានកំណត់តែពីបទល្មើស ដែលទាក់ទងទៅនឹងការលួចលក់ ទិញ នាំចេញ នាំចូល ផ្លាស់ទី នូវសម្បត្តិវប្បធម៌ជាអាទិ៍ ដោយមិនមានចែងពីបទល្មើសលួចយកនូវសម្បត្តិវប្បធម៌នោះទេ។ រីឯ**ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩**យើងវិញ មានតែសម្បត្តិវប្បធម៌ ដែលជាបូជនីយវត្ថុនៃ ព្រះពុទ្ធសាសនាប៉ុណ្ណោះ ដែលត្រូវបានកំណត់ពី**បទល្មើសលួចបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា**។

### ១.២. ការលួចទាក់ទងនឹងអចលនវត្ថុ

ដូចបានបកស្រាយនៅក្នុងជំពូកទីមួយរួចមក អំពើលួច ដែលមានបញ្ញត្តនៅក្នុង**ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩** គឺកម្មវត្ថុនៃបទល្មើសដាច់ខាតត្រូវតែជាចលនវត្ថុ ឬអចលនវត្ថុ ដែលមានចរិតលក្ខណៈជាចលនវត្ថុ។ ប៉ុន្តែសម្រាប់អចលនវត្ថុ ការលួចអាចកើតឡើងបានក្នុងរូបភាពជាការលួចលក់ ឬលួចបញ្ចាំ។ ដូចមាននៅក្នុង**មាត្រា ២៥៥** នៃ**ច្បាប់ភូមិបាល ឆ្នាំ២០០១** ចែងថា៖ ***ជនណា ដែលលួចលក់ ឬលួចបញ្ចាំអចលនវត្ថុ ដែលមិនមែនជារបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ៣ (បី) ឆ្នាំ ដោយមិនគិតដល់ព្យសនកម្ម ដែលបណ្តាលមកពីអំពើរបស់ខ្លួន។***[104] ក្នុងមាត្រានេះ ការលួច មិនមែនជាការដកហូតធ្វើឱ្យទ្រព្យផ្លាស់ទីចេញពីម្ចាស់នោះទេ ដោយហេតុថាទ្រព្យ ដែលជាកម្មវត្ថុនៃ ការលួចនេះ ជាប្រភេទអចលនទ្រព្យ ឬអាចហៅបានថា ជាអចលនវត្ថុពីកំណើត ពោលគឺ មិនអាចផ្លាស់ទីបានទេ។ ប៉ុន្តែការលួចក្នុងមាត្រានេះ ជាការចាត់ចែងលក់ ឬយកទៅបញ្ចាំ ទាំងដែលចោរដឹងថាអចលនវត្ថុនោះមិនមែនជារបស់ខ្លួន ហើយខ្លួនមិនមានសិទ្ធិក្នុងការធ្វើដូច្នេះ។ ការប្រព្រឹត្តបទល្មើសក្នុងមាត្រានេះ ពុំគិតពីព្យសនកម្ម ថាតើទង្វើ ដែលចោរ ធ្វើនោះបង្កឱ្យមានការខូចខាត ឬមិនខូចខាតនោះទេ ពោលគឺឱ្យតែចោរបានយកអចលនវត្ថុទៅលក់ ឬបញ្ចាំដោយគ្មានសិទ្ធិ ទង្វើចោរត្រូវតែជាបទល្មើស ដែលអាចនាំឱ្យមាននូវការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ។

ដោយឡែក ក្នុងករណី ដែលអចលនទ្រព្យនោះ ជាទ្រព្យសម្បត្តិសាធារណៈ ការលួច លក់អចលនទ្រព្យប្រភេទនោះ ចោរត្រូវផ្តន្ទាទោសតាម**មាត្រា ២៥៩** នៃ**ច្បាប់ភូមិបាលឆ្នាំ២០០១** ដូចមានបញ្ញត្តក្នុង**កថាខណ្ឌទី១** ថា៖ ***ការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិ សាធារណៈត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ដល់ ៥០ ០០០ ០០០ (ហាសិបលាន) រៀល ឬ/និង ផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ។***

### ១.៣. ការលួចស្លាដៃ

[103] សូមមើលក្នុងតំណភ្ជាប់នេះ៖http://vh.dccam.org/ការថែរក្សាសម្បត្តិបេតិ/ ។

[104] ច្បាប់ភូមិបាល ឆ្នាំ២០០១ ទំព័រ ១៤៧២ មាត្រា ២៥៥។

ការចម្លងស្នាដៃនិពន្ធ របស់**អ្នកនិពន្ធ**[105]ណាមួយ **ផលិតករហ្វូណូក្រាម**[106] ឬ **អ្នកសម្តែង**[107] ដោយបំពាន ដែលយើងហៅថា **ការលួចស្នាដៃនោះ** យោងតាមបញ្ញត្តិ**ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល** ចាត់ទុកថាទង្វើបែបនេះ គឺជាការបំពានមកលើអ្នកនិពន្ធ នូវសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធនោះ ក៏ដូចជាការបំពាននូវសិទ្ធិផ្តាច់មុខរបស់អ្នកដែលជាផលិតករហ្វូណូក្រាម និងអ្នកសម្តែង ។

ស្នាដៃទាំងឡាយ ដែលត្រូវបានច្បាប់ការពារពីការលួចយកដោយចម្លងនេះ ត្រូវបានចែងក្នុង**មាត្រា៧** នៃ**ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល** ដូចជា៖

*ក-សៀវភៅអានគ្រប់ប្រភេទ ឬឯកសារផ្សេងៗទៀតស្តីពីអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ និងការអប់រំ។*

*ខ-អត្ថបទបាឋកថា សង្កថា ធម្មទេសនា ការការពារខ្លួនដោយនិយាយ ឬដោយសរសេរ និងស្នាដៃផ្សេងៗទៀតដែលមានប្រភេទដូចគ្នា។*

*គ-ស្នាដៃនាដកម្ម ឬនាដកម្ម-តូរ្យតន្ត្រី។*

*ឃ-ស្នាដៃរបាំសម័យ ឬយកលំនាំតាមស្នាដៃបុរាណ ឬប្រពៃណី។*

*ង-ការសម្តែងសៀក និងការសម្តែងកាយវិការ។*

*ច-ការតែងបទភ្លេងដោយមាន ឬគ្មានទំនុកច្រៀង។*

*ឆ-ស្នាដៃសោតទស្សន៍។*

*ជ-ស្នាដៃជាផ្ទាំងគំនូរ ផ្ទាំងចម្លាក់ រូបចម្លាក់ ឬស្នាដៃផ្សេងទៀតខាងសិល្បៈសូនរូប ឬសិល្បៈអនុវត្ត។*

*ឈ-ស្នាដៃថតរូប និងស្នាដៃទាំងឡាយ ដែលសម្រេចបានដោយសារមានជំនួយបច្ចេកទេសដូចគ្នានឹងការថតរូប។*

*ញ-ស្នាដៃស្ថាបត្យកម្ម។*

*ដ-ផែនទី ប្លង់ គំនូសវាស ឬស្នាដៃស្តែងចេញជារូប ដែលទាក់ទងនឹងភូមិសាស្ត្រ ឋានលេខា ឬវិទ្យាសាស្ត្រនានា។*

*ឋ-កម្មវិធីកុំព្យូទ័រ និងគម្រោងឯកសារសមោធាន ដែលទាក់ទងនឹងកម្មវិធីទាំងនោះ។*

---

[105] អ្នកនិពន្ធ ជាជន ដែលបង្កើតបានស្នាដៃ។(ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ សិទ្ធិប្រហាក់ប្រហែល ២០០៣ ទំព័រ២៥៨៨ មាត្រា២ ចំណុច ខ)។

[106] ផលិតករហ្វូណូក្រាម ជាជន ដែលផលិតហ្វូណូក្រាម ហើយហ្វូណូក្រាម ជាវត្ថុ ដែលបានថតបញ្ចូលសំឡេងនៃការសម្តែង ឬសំឡេងផ្សេងៗទៀត ឬនិមិត្តសញ្ញានៃសំឡេង ក្រៅពីទម្រង់នៃការថតបញ្ចូលខ្សែភាពយន្ត ឬស្នាដៃសោតទស្សន៍ផ្សេងៗទៀត។(ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ ទំព័រ២៥៨៩ មាត្រា២ ចំណុច ដ ញ)។

[107] អ្នកសម្តែង ជាសិល្បករ អ្នករបាំ តន្ត្រីករ អ្នកចម្រៀង ឬជន ដែលធ្វើការសម្តែង។(ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ ទំព័រ២៥៨៨ មាត្រា២ ចំណុច ង)។

*ឌ-ផលិតផលផ្អែកសិប្បកម្ម តម្បាញ ឬម៉ូតសម្លៀកបំពាក់ផ្សេងៗ។*[108]

សិទ្ធិបេតិកភណ្ឌ នៅក្នុង**មាត្រា ២១ កថាខណ្ឌទី១** នៃ**ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល** បានផ្តល់និយមន័យថា៖ *សិទ្ធិបេតិកភណ្ឌ ជាសិទ្ធិប្រកបអាជីវកម្ម របស់អ្នកនិពន្ធលើទ្រព្យជាស្នាដៃរបស់ខ្លួន តាមរយៈការផលិតឡើងវិញ ការផ្សព្វផ្សាយជាសាធារណៈ និងការបង្កើតស្នាដៃបន្ត។*[109] នៅក្នុងមាត្រា ៤១ នៃច្បាប់ដដែល បានផ្តល់នូវ សិទ្ធិផ្តាច់មុខក្នុងការធ្វើដោយផ្ទាល់ ឬអនុញ្ញាតឱ្យធ្វើនូវសកម្មភាពជាប្រយោជន៍នានាដល់អ្នកសម្តែងក្នុងចំណុច **គ** ថា៖ *គ-ការផលិតឡើងវិញនូវការសម្តែង ដែលបានថតបញ្ចូលជាហ្វូណូក្រាម។*[110] ដូចគ្នានេះ នៅក្នុង**មាត្រា ៤៤** នៃច្បាប់ដដែល ក៏បានផ្តល់នូវ សិទ្ធិផ្តាច់មុខដល់ ផលិតករហ្វូណូក្រាម ថា៖ *ផលិតករហ្វូណូក្រាម មានសិទ្ធិផ្តាច់មុខ ក្នុងការថត ឬការផលិតឡើងវិញ ឬការផ្សព្វផ្សាយជាសាធារណៈនូវហ្វូណូក្រាមរបស់ ខ្លួន។* [111]

នៅក្នុង**មាត្រា ២ ចំណុច ឌ** នៃ**ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល** បានកំណត់ថា៖ *ការផលិតឡើងវិញ ជាការចម្លងទាំងស្រុង ឬភាគខ្លះនៃស្នាដៃ ឬហ្វូណូក្រាម បង្កើតជាផលិតផលចម្លងមួយច្បាប់ ឬច្រើនច្បាប់ តាមមធ្យោបាយ ឬទម្រង់ណាមួយគិតបញ្ចូលទាំងស្នាដៃ ឬហ្វូណូក្រាម ដែលរក្សាទុកជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នតាមទម្រង់អេឡិចត្រូនិច។*[112]

ដោយផ្អែកតាមបញ្ញត្តិទាំងឡាយខាងលើ ការលួចចម្លង ទាំងស្រុង ឬត្រង់ភាគខ្លះនៃ ស្នាដៃអ្នកនិពន្ធ អ្នកសម្តែង ឬផលិតករហ្វូណូក្រាម ដើម្បីបង្កើតជាផលិតផលចម្លងនោះ ជាការបំពាននូវសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ និងសិទ្ធិផ្តាច់មុខរបស់អ្នកសម្តែង និងផលិតករហ្វូណូក្រាម លើការផលិតឡើងវិញ។ការលួចយកស្នាដៃរបស់អ្នកដទៃតាមរយៈការចម្លងនេះ គឺជាទង្វើខុសច្បាប់ ហើយជាបទល្មើសព្រហ្មទណ្ឌ ដែលមានបញ្ញត្តិក្នុង បទប្បញ្ញត្តិនៃច្បាប់ពិសេសដោយឡែក **គឺច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល** ត្រង់**មាត្រា ៦៤** និង**មាត្រា ៦៥**។**មាត្រា ៦៤ (ការបំពានសិទ្ធិអ្នកនិពន្ធ) កថាខណ្ឌ ទី២** បានចែងថា៖ *បទល្មើសនៃការផលិត ឬការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជា ប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ២៥ ០០០ ០០០ (ម្ភៃប្រាំលាន) រៀល ឬ/ និង ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ១២ (ដប់ពីរ) ខែ។ ករណីមិនរាង ចាលត្រូវផ្តន្ទាទោសទ្វេដង។*[113]**មាត្រា ៦៥ (ការបំពានសិទ្ធិផលិតករហ្វូណូក្រាម និងអ្នកសម្តែង) កថាខណ្ឌទី១** បានចែងថា៖ *ការផលិត ឬការផលិតឡើងវិញ*

[108] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ ទំព័រ២៥៩២ ដល់២៥៩៣ មាត្រា៧។
[109] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ ទំព័រ២៥៩៧ មាត្រា២១ កថាខណ្ឌទី១។
[110] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ ទំព័រ២៦០៥ មាត្រា៤១ ចំណុច គ។
[111] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ ទំព័រ២៦០៦ មាត្រា៤៤។
[112] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ ទំព័រ២៥៨៩ មាត្រា២ ចំណុច ឌ។
[113] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ ទំព័រ២៦១៤ មាត្រា៦៤ កថាខណ្ឌទី២។

*ដោយគ្មានការ អនុញ្ញាតពីអ្នកសម្ដែង ឬពីផលិតករហ្វូណូក្រាម ឬពីផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ២៥ ០០០ ០០០ (ម្ភៃប្រាំលាន) រៀល ឬ/ និងត្រូវផ្ដន្ទាទោសជាប់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ១២ (ដប់ពីរ) ខែ។ ករណីមិនរាងចាល ត្រូវផ្ដន្ទាទោសទ្វេដង។*[114]

## ២. បទល្មើសប្រហាក់ប្រហែល និងបទល្មើស ដែលត្រូវបានប្រដូចទៅនឹងអំពើលួច

ក្រៅពីបទល្មើសលួច ដែលត្រូវបានបញ្ញត្តក្នុងច្បាប់ផ្សេងៗទៅនោះ នៅក្នុង**ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩** ក៏មានចែងផងដែរនូវបទល្មើសមួយចំនួន ដែលមានលក្ខណៈប្រហាក់ ប្រហែលទៅនឹងអំពើលួច ក៏ដូចជាប្រដូចនូវស្ថានភាពនៃបទល្មើសទាំងនោះ ទៅនឹងអំពើលួចទៀតផង។ ដើម្បីឱ្យយល់ច្បាស់ពីបញ្ហានេះ ក្នុងទីនេះ យើងនឹងសិក្សាទៅលើ **២** ចំណុចធំៗ គឺ**បទល្មើសប្រហាក់ប្រហែលទៅនឹងអំពើលួច** និង**បទល្មើស ដែលត្រូវបានប្រដូចទៅនឹងអំពើលួច**។

### ២.១. បទល្មើសប្រហាក់ប្រហែលទៅនឹងអំពើលួច

បទល្មើសប្រហាក់ប្រហែលទៅនឹងអំពើលួច គឺសុទ្ធតែជាប្រភេទបទល្មើស ដែលជាការយកទ្រព្យសម្បត្តិគេមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយមធ្យោបាយទុច្ចរិត និងជាបទល្មើស ដែលមានចរិតលក្ខណៈប្រហាក់ប្រហែលទៅនឹងអំពើលួច ហើយសឹងមានចែងកំណត់ក្នុង**ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩**។ ទោះបីជាបទល្មើសទាំងនោះមានលក្ខណៈប្រហាក់ប្រហែលទៅនឹងអំពើលួច ក្នុងការយកទ្រព្យរបស់អ្នកដទៃក៏ដោយក្ដី ក៏បទល្មើសទាំងនោះ មានសញ្ញាណនៃធាតុផ្សំបទល្មើសខុសពីអំពើលួច។ត្រង់នេះហើយ ដែលតម្រូវឱ្យមានការវិភាគ ដើម្បីវែកញែករវាងបទល្មើសប្រហាក់ប្រហែល និងអំពើលួច ដើម្បីជៀសវាងការកំណត់បទល្មើសខុស។

#### ២.១.១. ការកំហែងយក

នីត្យានុកូលភាពនៃការកំហែងយកនេះ ត្រូវបានកំណត់ក្នុង**មាត្រា ៣៦៣** នៃ**ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩** ដោយមានសេចក្ដីថា៖ *អំពើកំហែងយក គឺជាអំពើ ដែលប្រព្រឹត្តដោយការប្រើហិង្សា ការគំរាមកំហែងថានឹងប្រើហិង្សា ឬដោយការបង្ខិតបង្ខំ ដើម្បីទទួលបាននូវ:*

*១-ហត្ថលេខា ឬស្នាមម្រាមដៃ។*

*២-ការសន្យា ឬការបោះបង់ចោលអ្វីមួយ។*

*៣-ការបង្ហាញអាថ៌កំបាំងណាមួយ។*

*៤-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។*[115]

[114] ច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ ទំព័រ២៦១៤ ដល់២៦១៥ មាត្រា៦៥ កថាខណ្ឌទី១។

[115] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១១៩ មាត្រា៣៦៣។

ដោយយោងទៅលើសេចក្តីបញ្ញត្តខាងលើ យើងឃើញថាធាតុផ្សំចម្បងនានានៃបទល្មើសនេះ មានលក្ខណៈខុសគ្នាទៅនឹងអំពើលួច។នៅក្នុងអំពើកំហែងយក ហិង្សា ឬការគំរាមកំហែងថានឹងប្រើហិង្សា និងការបង្ខិតបង្ខំ គឺជាធាតុផ្សំសំខាន់នៃបទល្មើសផង និងជាមធ្យោបាយនៃការប្រព្រឹត្តបទល្មើសផង ដែលវាខុសស្រឡះទៅនឹងអំពើលួចដែលហិង្សា គឺជាស្ថានភាពមួយនៃការប្រព្រឹត្តអំពើលួច ដែលនាំឱ្យមាននូវការផ្តន្ទាទោសនូវស្ថានទម្ងន់ទោស។ ជាងនេះទៀត ធាតុផ្សំ ដែលជាកម្មវត្ថុនៃអំពើកំហែងយក មានច្រើនជាងអំពើលួច ពោលគឺអំពើកំហែងយក អាចជាការកំហែងយកនូវហត្ថលេខា ការសន្យា ឬការបោះបង់ចោល ឬការបង្ហាញអាថ៌កំបាំង ហើយក៏អាចជាការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិផងដែរ។ ប៉ុន្តែអំពើលួច មានកម្មវត្ថុត្រឹមតែជា ទ្រព្យសម្បត្តិ ឬវត្ថុ ហើយជាប្រភេទចលនទ្រព្យ ឬ ចលនវត្ថុ ប៉ុណ្ណោះ។ភាពខុសគ្នាធំបំផុត រវាងអំពើកំហែងយក និងអំពើលួចដោយហិង្សា គឺអំពើកំហែងយកនេះ តម្រូវឱ្យជនរងគ្រោះលះបង់ចោលដោយខ្លួនឯងនូវទ្រព្យសម្បត្តិ ដែលត្រូវបានគេកំហែងយក ដែលជាហេតុបង្កឱ្យ ប៉ះពាល់ដល់បុគ្គលយ៉ាងធ្ងន់ធ្ងរ ជាងការលួចដោយហិង្សា។[116]

ទោះជាយ៉ាងនេះ បទល្មើសទាំងពីរក៏មានលក្ខណៈដូចគ្នាផងដែរ ពោលគឺបទល្មើសទាំងពីរ សុទ្ធតែជាប្រភេទបទល្មើស ដែលកើតឡើងដោយកំហុសចេតនា គឺចារីនៃបទល្មើសមានចេតនាក្នុងការប្រព្រឹត្តបទល្មើស ដែលបទល្មើសនោះ គឺជាការយកទ្រព្យសម្បត្តិអ្នកដទៃមកធ្វើជាកម្មសិទ្ធិដោយទុច្ចរិត។

**ឧទាហរណ៍** ចោរម្នាក់ បានកាន់កាំភ្លើងភ្ជង់ជនរងគ្រោះ ឱ្យជនរងគ្រោះចុះចេញពី រថយន្តរបស់គាត់ ហើយដោះ និងយកគ្រឿងមានតម្លៃទាំងប៉ុន្មាន ទុកក្នុងរថយន្តនោះឱ្យខ្លួន។ ករណីនេះ មិនមែនជាអំពើលួចនោះទេ ប៉ុន្តែវាជាអំពើកំហែងយក។

### ២.១.២. ការគំរាមកំហែងហែកកេរ្តិ៍

ការគំរាមកំហែងហែកកេរ្តិ៍ មានចែងនៅក្នុង**មាត្រា ៣៧២** នៃ**ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩** ថា៖ ***អំពើគំរាមកំហែងហែកកេរ្តិ៍ គឺជាអំពើប្រព្រឹត្តដោយគំរាមកំហែងបើកកកាយ ឬទម្លាក់កំហុសទៅលើអំពើ ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬការរាប់អាន ដើម្បីទទួលបាននូវ :***

*១-ហត្ថលេខា ឬស្នាមម្រាមដៃ។*

*២-ការសន្យា ឬការបោះបង់ចោលអ្វីមួយ។*

*៣-ការបង្ហាញអាថ៌កំបាំងណាមួយ។*

*៤-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។*[117]

[116] សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី វិភាគទានចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ បោះពុម្ពផ្សាយ ឆ្នាំ ២០០៥ ទំព័រ៣០៩ មាត្រា កម ៣១១២-១ ធាតុផ្សំនៃការកំហែងយក។

[117] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១២១ មាត្រា៣៧២។

ដោយផ្អែកទៅលើមាត្រាខាងលើ ធាតុផ្សំនៃអំពើគំរាមកំហែងហែកកេរ្តិ៍ ក៏មានលក្ខណៈខុសគ្នាពីអំពើលួចផងដែរ។ អំពើគំរាមកំហែងហែកកេរ្តិ៍នេះ គឺត្រូវធ្វើឡើងដោយ មធ្យោបាយដូចជាការគំរាមកំហែងបើកកកាយ ឬទម្លាក់កំហុស ទោះបីរឿងនោះជារឿងពិត ឬមិនពិតក៏ដោយ[118] គឺឱ្យតែប៉ះពាល់ដល់កិត្តិយស ឬការរាប់អានរបស់ជនរងគ្រោះនឹងមជ្ឈដ្ឋានជុំវិញ ដែលការគំរាមនេះធ្វើឡើងក្នុងកម្មវត្ថុដូចគ្នានឹងអំពើកំហែងយកដែរ ពោលគឺដើម្បីឱ្យជនរងគ្រោះផ្តល់ហត្ថលេខា ឬស្នាមមេដៃ ការសន្យា ឬការលះបង់ ការបង្ហាញអាថ៌កំបាំង និងការប្រគល់មូលនិធិ តម្លៃ ទ្រព្យសម្បត្តិអ្វីមួយ។ ដូចគ្នានេះដែរ ភាពខុសគ្នារវាងអំពើគំរាមកំហែងហែកកេរ្តិ៍ ដែលមានកម្មវត្ថុឱ្យមានការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយខុសពីអំពើលួចនៅត្រង់ចំណុចនៃការលះបង់ ដោយជនរងគ្រោះជាអ្នកលះបង់មូលនិធិ ឬទ្រព្យសម្បត្តិនោះទៅឱ្យចារីនៃបទល្មើស ពោលគឺចារី មិនបានធ្វើការដកហូតទ្រព្យនោះពីជនរងគ្រោះឡើយ ប៉ុន្តែការណ៍ដែលជាជនរងគ្រោះប្រគល់ទ្រព្យសម្បត្តិមកឱ្យចារី ក៏ព្រោះតែស្ថានភាព ដែលកើតឡើងពីទង្វើទុច្ចរិតរបស់ចារី។

ទោះជាយ៉ាងនេះ បទល្មើសទាំងពីរក៏មានលក្ខណៈដូចគ្នាផងដែរ ពោលគឺបទល្មើសទាំងពីរ សុទ្ធតែជាប្រភេទបទល្មើស ដែលកើតឡើងដោយកំហុសចេតនា គឺចារីនៃបទ ល្មើសមានចេតនាក្នុងការប្រព្រឹត្តបទល្មើស ដែលបទល្មើសនោះ គឺជាការយកទ្រព្យសម្បត្តិអ្នកដទៃមកធ្វើជាកម្មសិទ្ធិដោយទុច្ចរិត។

**ឧទាហរណ៍** ចារី បានគំរាមជនរងគ្រោះ ដែលជាតារាល្បីម្នាក់នៅក្នុងសង្គម ដើម្បីឱ្យតារានោះប្រគល់ឱ្យខ្លួននូវលុយចំនួន ៣០ ០០០ (បីម៉ឺន) ដុល្លារ បើតារានោះមិនប្រគល់តាមសំណើខ្លួនទេ ខ្លួននឹងទម្លាយពីស្ថានភាពសមត្ថភាពផ្លូវភេទ ដែលតារានោះជាជនអសមត្ថភាពផ្លូវភេទ។ ទង្វើ ដែលចារីព្យាយាមយកទ្រព្យរបស់ជនរងគ្រោះដោយទុច្ចរិត (តាមវិធីគំរាមឱ្យជនរងគ្រោះប្រគល់លុយ)នេះ ជាបទល្មើស គំរាមកំហែងហែកកេរ្តិ៍។

### ២.២. បទល្មើស ដែលត្រូវបានប្រដូចនៅនឹងអំពើលួច

បទល្មើសមួយចំនួនត្រូវបាននីតិនិពន្ធខ្មែរ ធ្វើការប្រដូចដើម្បីពង្រីកដែនអនុវត្តនៃការមិនរាងចាលក្នុងបទមជ្ឈិម ចំពោះបទល្មើស ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ក៏ប៉ុន្តែការធ្វើបែបនេះ ពុំមែនជាការបំលែងការមិនរាងចាលនេះឱ្យទៅជាការមិនរាងចាលទូទៅនោះទេ។ តាមពិតគេចាត់ទុកថា មានបទល្មើសមជ្ឈិមមួយចំនួនមានលក្ខណៈស្រដៀងគ្នាខ្លាំងណាស់ ហើយដូច្នេះត្រូវតែប្រដូចគ្នាបាន ជួនកាលតម្លៃផ្នែកសង្គម ដែលត្រូវបានរំលោភបំពានមានលក្ខណៈដូចគ្នា (ការលួច រំលោភលើទំនុកចិត្ត ការឆបោក) ជួនកាលបទល្មើសទាំងពីរដែលប្រដូចគ្នានោះជាប់ទំនាក់ទំនងគ្នា និងបង្ហាញថា ទណ្ឌិតពុំបានលើកយកមកពិចារណានូវការព្រមានជាផ្លូវការលើកទីមួយ ដែលធ្វើឡើងដោយតុលាការតាមរយៈការផ្តន្ទាទោសជាលើកដំបូងទេ (ការទទួលផលចោរកម្ម និងបទល្មើស ដែលជា

[118] សូមអានសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី វិភាគទានចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ បោះពុម្ពផ្សាយ ឆ្នាំ ២០០៥ ទំព័រ៣១៥ មាត្រា កម៣១១៣-១ ធាតុផ្សំនៃការគំរាមកំហែងហែកកេរ្តិ៍។

ប្រភពនៃទ្រព្យផលចោរកម្ម)។[119] ដូច្នេះ កាលបើចារីត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិមណាមួយ ចារីនោះបានប្រព្រឹត្តបទមជ្ឈិមដដែល ឬបទមជ្ឈិម ដែលត្រូវបានប្រដូច ដូចទៅនឹងបទមជ្ឈិមមុននោះនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិមថ្មីត្រូវទ្វេឡើង។[120] ជាងនេះទៅទៀត ការប្រដូចបទល្មើសនេះ អាចប្រដូចបានដរាបណាមានចែងក្នុងច្បាប់វិជ្ជមានយ៉ាងច្បាស់លាស់ប៉ុណ្ណោះ ពោលគឺទោះបីបទល្មើសនោះជាប្រភេទបទល្មើសប្រហាក់ប្រហែលក៏ដោយ ឬមើលទៅហាក់ស្រដៀងគ្នាក៏ដោយ ដរាបណាមិនមានបញ្ញត្តិច្បាប់កំណត់ពីការប្រដូចគ្នាទេនោះ គេមិនអាចបកស្រាយនូវការប្រដូចនេះតាមគំនិតរបស់ខ្លួនឡើយ។

**២.២.១. ការឆបោក**

ការឆបោក គឺជាបទល្មើសព្រហ្មទណ្ឌមួយ ដែលត្រូវបាននីតិនិពន្ធខ្មែរប្រដូចទៅនឹងអំពើលួច ក្នុងករណីដែលចារីនោះប្រព្រឹត្តបទល្មើសក្នុងស្ថានភាពនៃការមិនរាងចាល។ និយមន័យនៃការឆបោក ត្រូវបានកំណត់នៅក្នុង**មាត្រា ៣៧៧** នៃ**ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩** ដោយសេចក្តីថា៖ ***អំពើឆបោក គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ*** *ដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនោះ ដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬតតិយជននូវ :*

*១-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។*

*២-ការផ្គត់ផ្គង់សេវា។*

*៣-ការធ្វើលិខិត ដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច។*[121]

ការឆបោក គឺតម្រូវឱ្យចារីប្រើប្រាស់នូវមធ្យោបាយមួយចំនួន ដោយត្រូវប្រព្រឹត្តក្នុងចេតនាទុច្ចរិត ហើយដោយសារតែមធ្យោបាយទាំងនេះ ចារីបំភាន់បុគ្គលណាម្នាក់ និង ញុំាងឱ្យប្រគល់នូវរបស់អ្វីមួយមកឱ្យខ្លួន។ មធ្យោបាយ ដែលប្រើប្រាស់ចាំបាច់ត្រូវតែមាននៅមុនការប្រគល់ ហើយត្រូវតែញុំាងឱ្យមានការប្រគល់នេះ។ វាហាក់ដូចជាមានសារៈសំខាន់ ដែលត្រូវគូសបញ្ជាក់ថា បុគ្គលដែលអាចត្រូវគេនាំឱ្យមានការភាន់ច្រឡំ គឺអាចជា រូបវន្តបុគ្គល ឬនីតិបុគ្គល។[122]

[119] សូមអានសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី វិភាគទានចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ បោះពុម្ពផ្សាយ ឆ្នាំ ២០០៥ ទំព័រ៩២ មាត្រា កម ១២២១-៧ បទល្មើសប្រដូច ដើម្បីបបង្កើតឱ្យមានការមិនរាងចាល និង សូមមើលក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ២៤ មាត្រា៨៥។

[120] សូមមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ២៤ មាត្រា៨៨។

[121] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១២៤ មាត្រា៣៧៧។

[122] សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី វិភាគទានចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ បោះពុម្ពផ្សាយ ឆ្នាំ ២០០៥ ទំព័រ៣១៩ មាត្រា កម ៣១២១-១ ធាតុផ្សំនៃការឆបោក។

ដោយសារតែការឆបោក ត្រូវបានប្រដូចទៅនឹងអំពើលួច ដូច្នេះការប្រព្រឹត្តនូវការ ឆបោកនេះ ក៏អាចទទួលនូវការផ្តន្ទាទោសក្នុងស្ថានភាពនៃការមិនរាងចាលក្នុងបទមជ្ឈិម បន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិមមុន ដែលជាអំពើលួចផងដែរ។

### ២.២.២. ការរំលោភលើទំនុកចិត្ត

មិនខុសពីបទល្មើសមុនដែរ ការរំលោភលើទំនុកចិត្ត ក៏ត្រូវបាននីតិនិពន្ធខ្មែរ កំណត់ ដោយប្រដូចទៅនឹងអំពើលួចផងដែរ សម្រាប់ពង្រីកដែនអនុវត្តនៃការមិនរាងចាល។ **មាត្រា ៣៩១** នៃ**ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩** បានបញ្ញត្តពីនិយមន័យនៃការរំលោភលើទំនុកចិត្ត ថា៖ ***អំពើរំលោភលើទំនុកចិត្ត គឺជាអំពើគៃបំបាត់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ នាំឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឱ្យបុគ្គលនោះ ហើយបុគ្គលនោះបានយល់ព្រមដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬយកមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់។***[123]

ក្រមនេះ មិននិគ្រោះគ្រប់ការរំលោភសីលធម៌លើទំនុកចិត្តរបស់តតិយជននោះទេ តែ និគ្រោះចំពោះតែការគៃបំបាត់របស់អ្វីមួយ ដែលតតិយជននោះបានប្រគល់ឱ្យ ដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬទៅធ្វើការប្រើប្រាស់ ជាកំណត់មួយប៉ុណ្ណោះ។ចំណុច សំខាន់ៗនៃបទល្មើសនេះ គឺចារីបានទទួលរបស់ដោយរបៀបស្របច្បាប់ ហើយក្រោយមកទើបមានអំពើនៃការរំលោភ ដោយមានចេតនាទុច្ចរិតកើតឡើង ក្នុងទម្រង់ជាអំពើនៃការប្រកាន់កិរិយាជាកម្មសិទ្ធិករ ដោយបដិសេធមិនព្រមប្រគល់សងវិញដោយអំពើនៃការចាយខ្ជះខ្ជាយ ដោយការឃឺតយ៉ាវក្នុងការប្រគល់សងវិញនូវវត្ថុនោះ...។ល។ ជាងនេះទៅ ទៀតអត្ថបទច្បាប់មិនតម្រូវឱ្យការប្រគល់នូវមូលនិធិ ដែលត្រូវបានគៃបំបាត់ ឬត្រូវបានចាយខ្ជះខ្ជាយ នោះមានប្រភពចេញពីកិច្ចសន្យាមួយប្រភេទដ៏ជាក់លាក់នោះទេ ពោលគឺសំដៅទៅលើរាល់កិច្ចសន្យា ដែលបង្កើតកាតព្វកិច្ចណាមួយជាកំណត់ ពោលគឺកិច្ចសន្យាដែលបង្កើតកាតព្វកិច្ចណាមួយជាកំណត់ ដូចជា ភតិសន្យា អាណត្តិការងារ ខ្ចីប្រើ បញ្ញើ ជាដើម។ ដោយឡែក ក្នុងករណី ដែលជាការប្រគល់ ដែលនាំឱ្យអ្នកទទួលចាត់ចែង ឬប្រើប្រាស់ដោយសេរីនូវមូលនិធិ ឬទ្រព្យសម្បត្តិ ពុំអាចជាអំពើរំលោភលើទំនុកចិត្តទេ តួយ៉ាងដូចជាកិច្ចសន្យាខ្ចីបរិភោគ ខ្ចីប្រាក់ ខ្ចីអង្ករ ជាដើម បើសិនជាអ្នកខ្ចីមិនសងត្រឡប់មកវិញ ពុំអាចជាបទល្មើសរំលោភលើទំនុកចិត្តនោះទេ។[124]

[123] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១២៨ ដល់១២៩ មាត្រា៣៩១។

[124] សូមមើលសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី វិភាគទានចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ បោះពុម្ពផ្សាយ ឆ្នាំ ២០០៥ ទំព័រ៣៣០ មាត្រា កម ៣១៣១-១ ធាតុផ្សំនៃការរំលោភលើទំនុកចិត្ត និង នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ នុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១៣-២០១៤ ១២.បទរំលោភលើទំនុកចិត្ត។

ដោយហេតុថាការរំលោភលើទំនុកចិត្ត ត្រូវបានប្រដូចទៅនឹងអំពើលួច ដូច្នេះការប្រព្រឹត្តនូវការរំលោភលើទំនុកចិត្តនេះ ក៏អាចទទួលនូវការផ្តន្ទាទោសក្នុងស្ថានភាពនៃការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិមមុន ដែលជាអំពើលួចផងដែរ។

**២.២.៣. ការទទួលផលចោរកម្ម**

ការទទួលផលចោរកម្ម ក៏ត្រូវបានប្រដូចផងដែរទៅនឹងអំពើលួច។ ការទទួលផលចោរកម្ម ដែលមានកំណត់ក្នុង**មាត្រា ៣៩៩** នៃ**ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩** មានសេចក្តីថា៖ ***អំពើទទួលផលចោរកម្ម គឺជាអំពើទទួលលាក់បំបាំង រក្សាទុក ឬបញ្ជូនវត្ថុអ្វីមួយដោយដឹង ថាវត្ថុនោះបានមកពីបទឧក្រិដ្ឋ ឬបទមជ្ឈិម។***

***ត្រូវចាត់ទុកជាអំពើទទួលផលចោរកម្មផងដែរ :***

***១-អំពើធ្វើជាអន្តរការីដើម្បីបញ្ជូនវត្ថុអ្វីមួយ ដោយដឹងថារបស់នោះបានមកពីបទឧក្រិដ្ឋ ឬបទមជ្ឈិម។***

***២-អំពើដែលបានទទួលផលពីផលនៃបទឧក្រិដ្ឋ ឬមជ្ឈិមដោយបានដឹងហេតុការណ៍ច្បាស់។***[125]

នៅក្នុងមាត្រានេះ បានបង្ហាញឱ្យឃើញថា ការលាក់បំបាំង រក្សាទុក ឬបញ្ជូនវត្ថុអ្វីមួយ ដែលជនអ្នកប្រព្រឹត្តនោះបានដឹងយ៉ាងច្បាស់ថា វត្ថុនោះ ជាវត្ថុ ដែលបានមកពីបទឧក្រិដ្ឋ ឬបទមជ្ឈិម គឺជាអំពើទទួលផលចោរកម្ម។ ក្រៅពីនេះទៅ ការធ្វើជាអន្តរការី[126]ក្នុងការបញ្ជូនវត្ថុ ដែលអន្តរការីនោះ បានដឹងយ៉ាងច្បាស់ថាជាផលនៃបទឧក្រិដ្ឋ ឬមជ្ឈិម និងការទទួលនូវផលពីវត្ថុ ដែលជាផលបទឧក្រិដ្ឋ ឬមជ្ឈិម ទាំងដែលអ្នកទទួលផលនោះបានដឹងថាវាជាផល ដែលបានមកពីផលនៃបទល្មើសដូចបានពោលខាងលើនោះ ទង្វើទាំងនេះក៏ត្រូវបាននីតិនិពន្ធខ្មែរចាត់ទុកជាអំពើទទួលផលចោរកម្មផងដែរ។

ដូច្នេះ ក្នុងករណីវត្ថុ ដែលជាផលនៃបទល្មើសនោះ បានមកពីការប្រព្រឹត្តបទមជ្ឈិម ដែលជាអំពើលួច នោះបទល្មើសទទួលផលចោរកម្ម ដែលចារីប្រព្រឹត្តនោះ ត្រូវប្រដូចទៅនឹងអំពើលួចផងដែរ។ ហេតុនេះព្រោះតែបទល្មើសថ្មីដែលចារីប្រព្រឹត្តមានទំនាក់ទំនងទៅនឹងបទល្មើសចាស់ ដែលចារីធ្លាប់ប្រព្រឹត្ត ព្រមទាំងជាហេតុបង្ហាញថា ចារីពុំបានលើកយកមកពិចារណានូវការពិន័យពីមុនមកលើខ្លួនឡើយ។

**ឧទាហរណ៍** បុគ្គល **ក** បានប្រព្រឹត្តនូវអំពើលួច ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសពន្ធនាគារ ១ឆ្នាំ ៦ខែ ហើយសាលក្រមសម្រេចផ្តន្ទាទោសចូលជាស្ថាពរនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២១។ ក្រោយពីអនុវត្តទោសចប់សព្វគ្រប់ **ក** ត្រូវបានដោះលែងឱ្យមានសេរីភាព។ បន្ទាប់មកនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ **ក** បានប្រព្រឹត្តបទល្មើសទទួល

[125] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ១២៨ ដល់១៣១ ដល់១៣២ មាត្រា ៣៩៩។

[126] អន្តរការី មានន័យថា ភ្នាក់ងារកណ្តាល ឬអ្នកភ្ជាប់ទំនាក់ទំនងរវាងភាគី។(សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកក្រមព្រហ្មទណ្ឌ បោះពុម្ព ផ្សាយដោយ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ ទំព័រ៧១ លេខ២៣២)។

ផលចោរកម្ម ដោយទទួលរក្សាម៉ូតូមួយគ្រឿង ដែលខ្លួនបានដឹងថាវាជាផលនៃអំពើលួចរបស់បុគ្គល **ខ**។ ដូច្នេះទង្វើរបស់ **ក** ជាការប្រព្រឹត្តបទមជ្ឈិមក្នុងស្ថានភាពមិនរាងចាលបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម(អំពើលួច)។

# សេចក្តីសន្និដ្ឋាន

អំពើលួច ដែលមជ្ឈដ្ឋានទូទៅបានដឹង និងស្គាល់ គឺត្រឹមតែជាអំពើមួយ ដែលបុគ្គលម្នាក់ទៅយកទ្រព្យ ឬវត្ថុរបស់អ្នកដទៃ ដែលម្ចាស់គេនោះមិនបានឱ្យមកសោះ។ ការយល់បែបនេះ ក៏ជាការយល់ឃើញត្រឹមត្រូវមួយផ្នែកផងដែរ ប៉ុន្តែខ្លឹមសារប៉ុណ្ណោះ គ្រាន់តែជាផ្នែកមួយនៃនិយមន័យរបស់អំពើលួច ដែលត្រូវបានកំណត់ចែងនៅក្នុងបទប្បញ្ញត្តិច្បាប់ប៉ុណ្ណោះ ពោលគឺ អំពើលួច នៅក្នុងបញ្ញត្តិច្បាប់មាននិយមន័យច្បាស់លាស់ និងមានដែនកំណត់យ៉ាងត្រឹមត្រូវដូចមានបរិយាយនៅក្នុងសារណានេះរួចមកហើយ។

ពិតប្រាកដណាស់ ការស្វែងយល់ពីបទល្មើសនេះឱ្យបានស៊ីជម្រៅ វាមិនត្រឹមតែមានប្រយោជន៍ ដល់ការកំណត់បទល្មើសប៉ុណ្ណោះទេ តែវាក៏ជាប្រយោជន៍ដល់ការណែនាំឱ្យប្រជាពលរដ្ឋទូទៅស្គាល់ច្បាស់ថាអំពើណាជាកម្មវត្ថុនៃអំពើលួច ហើយការស្គាល់នេះបានធ្វើឱ្យពលរដ្ឋយើងអាចរួមចំណែកជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងការបង្ក្រាបតាមរយៈការរាយការណ៍ដល់សមត្ថកិច្ច ក៏ដូចជាចូលរួមបង្ការនូវបទល្មើសនេះ កុំឱ្យកើតឡើងផងដែរ ពោលគឺកាលណាមានគេដឹងឮកាន់តែច្រើន ភ្នែកច្រមុះនៃនិយ័តករគតិយុត្តក៏កាន់តែច្រើនឡើង ហើយអាចក្តាប់ពត៌មានបានកាន់តែប្រសើរ។ រីឯជនល្មើសឯនោះវិញ ក៏រឹតតែក្រែងរអែងច្បាប់ឡើង ព្រមទាំងពុំហ៊ានប្រព្រឹត្តពាសវាលពាសកាលឡើយ។

ទន្ទឹមនឹងមានការសិក្សាស្វែងយល់លម្អិតពី អំពើលួច នេះទៅ បទល្មើស ដែលស្រដៀងទៅនឹងអំពើលួច ក៏ដូចជាបទល្មើសទាក់ទងនឹងការយកទ្រព្យសម្បត្តិអ្នកដទៃ មកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយទុច្ចរិតមួយចំនួន ក៏ត្រូវបានសិក្សាក្នុងសារណានេះផងដែរ ដើម្បីឱ្យយើងអាចបែងចែក ក៏ដូចជាវែកញែកនូវបទល្មើសនេះពីគ្នា ដែលញុាំងឱ្យការសិក្សាស្វែងយល់កាន់តែងាយស្រួលឡើង។

# អនុសាសន៍

ក្រោយពីបានសិក្សាយ៉ាងលម្អិតអំពីអំពើលួចមក យើងឃើញថាចំពោះបញ្ញត្តិច្បាប់ ដែលបានកំណត់អំពីអំពើលួច មានទាំងចំណុចខ្លាំង និងចំណុចដែលជាបញ្ហា ដែលតម្រូវឱ្យមានការពិនិត្យ និងបំពេញបន្ថែម។

## ចំណុចខ្លាំង

បញ្ញត្តិច្បាប់នេះ ជាបញ្ញត្តិ ដែលមានលក្ខណៈជឿនលឿន អាចរាប់ថាជាផ្លែផ្កា ឬលទ្ធផលនៃនីតិទំនើប ទាំងពាក្យពេចន៍នៃការតាក់តែង ទាំងរចនាសម្ពន្ធនៃការចងក្រងក៏មានលំដាប់លំដោយ និងមានទំនាក់ទំនងគ្នាយ៉ាងសម្បូរបែប។ ជាងនេះទៅទៀត សេចក្តីដែលបានបញ្ញត្តមកនេះ សឹងសមស្របទៅតាមបរិបទនៃសង្គមខ្មែរនាពេលបច្ចុប្បន្ន ហើយបើយើងក្រឡេកទៅមើលពីសម័យ ដែលទើបតែតាក់តែងក្រមនេះមករហូតមកដល់ឥឡូវ យើងនឹងអាចឃើញអំពីចក្ខុវិស័យដ៏វែងឆ្ងាយនៃនីតិនិពន្ធខ្មែរយើង។

## បញ្ហាមួយចំនួន

ទោះបីជាបញ្ញត្តិទាំងនេះ ជាបញ្ញត្តិ ដែលវិជ្ជមាន និងមានលក្ខណៈជឿនលឿនក៏ដោយ ក៏មានបញ្ហាមួយចំនួន ដែលអាចកើតជាវិវាទនៃការអនុវត្ត និងបកស្រាយច្បាប់ផងដែរ។ តួយ៉ាងទាក់ទងនឹងបញ្ញត្តិអំពីអំពើលួចវត្ថុបុរាណ ឬបូជនីយវត្ថុ ដែលមិនមែនជាបូជនីយវត្ថុនៃពុទ្ធសាសនា ហាក់ដូចជាមានការនិគ្រោះទោសទូទៅជាងការនិគ្រោះទោសចំពោះបទល្មើស ដែលប្រព្រឹត្តចំពោះបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា។ ដូចគ្នានេះដែរ បទបញ្ញត្តិចំពោះអំពើលួចបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា បានផ្តន្ទាទោសចំពោះតែអំពើលួចបូជនីយវត្ថុណា ដែលធ្វើឡើងក្នុងបូជនីយដ្ឋានសាសនា ដែលការចែងដូចនេះអាចធ្វើឱ្យមានការថយចុះនូវការការពារ ដែលច្បាប់ព្រហ្មទណ្ឌផ្តល់ឱ្យ ប្រសិនបើបូជនីយវត្ថុនោះ ពុំតាំងក្នុងទីបូជនីយដ្ឋានសាសនា។ ទន្ទឹមនឹងនេះដែរ បញ្ញត្តិច្បាប់មួយចំនួនទាក់ទងនឹងស្ថានទម្ងន់ទោសដូចជាពិការភាព យុត្តសាស្ត្រកម្ពុជាហាក់ពុំទាន់សម្បូរបែប និងមានការបកស្រាយនូវវិសាលភាពនៃពាក្យពេចន៍នោះឱ្យជាក់លាក់នៅឡើយទេ ដោយពាក្យ **ពិការភាព** តាម**ប្រកាសរបស់អន្តរក្រសួងស្តីពីការកំណត់លក្ខណវិនិច្ឆ័យប្រភេទ និងកម្រិតពិការភាព** បានកំណត់បែងចែកជា ៤ ប្រភេទ ដូចជាពិការកាយសម្បទា ពិការសតិបញ្ញា ពិការផ្លូវចិត្ត និងពិការផ្សេងៗ។ ប៉ុន្តែ ដែលយុត្តសាស្ត្រកម្ពុជាអនុវត្តបច្ចុប្បន្ន គឺត្រឹមតែពិការកាយសម្បទាប៉ុណ្ណោះ។ មិនខុសគ្នាប៉ុន្មានដែរពីបញ្ហាខាងលើ ពាក្យពេចន៍មួយចំនួន ក៏ពុំទាន់កំណត់វិសាលភាពតាមវិស័យគតិយុត្តឱ្យជាក់លាក់នោះដែរ ដូចជាពាក្យ ថាមពល ជាអាទិ៍។ ដោយបទពិសោធន៍ជាក់ស្តែងយើងអាចយល់ដោយងាយថា ថាមពលគឺចង់សំដៅដល់ ថាមពលអគ្គិសនី តែវិសាលភាពនៃដែនបំណកស្រាយវាក្យសព្ទនេះពុំទាន់បានកំណត់ឱ្យជាក់លាក់ទៅតាមនីតិវិស័យនៅឡើយទេ។ ជាងនេះទៅទៀត បទល្មើសលួចមួយចំនួន ដែលទាក់ទងនឹងវិស័យបច្ចេកវិទ្យា ដូចជាការលួចទិន្នន័យឯកជនក្នុងកុំព្យូទ័រ ឬបណ្តាញសង្គម ដែលប្រើប្រាស់ជាដើម ក៏

ពុំទាន់មានបទដ្ឋានច្បាប់ ដែលមានលក្ខណៈរឹងមាំ សមស្របតាមការវិវត្តន៍ និងរីកចម្រើននៃយុគសម័យបដិវត្ត ឧស្សាហកម្ម៤.0 នេះនៅឡើយ។

**ដំណោះស្រាយ**

ដើម្បីដោះស្រាយនូវបញ្ហាខាងលើតម្រូវឱ្យៈ

- ធ្វើការកំណត់នូវវិសាលភាពនៃការបកស្រាយ ផ្អែកតាមនីតិចក្ខុវិស័យ ចំពោះពាក្យពេចន៍ ដែលហាក់មានលក្ខណៈទូលាយ ដើម្បីស្របតាមវឌ្ឍនភាពនៃសង្គមជាតិ។
- ធ្វើឱ្យមានពិពិធភាពនៃយុត្តសាស្ត្រច្បាប់ សម្រាប់ពង្រីកចំណេះដឹង និងវិធីសាស្ត្រគតិយុត្តវិភាគ
- បង្កើនភាពងាយស្រួល តាមរយៈការបង្កើននូវការផ្សព្វផ្សាយយុត្តសាស្ត្រ និងសេចក្ដីសម្រេចរបស់តុលាការបន្ថែមទៀត
- លើកទឹកចិត្ត និងលើកកម្ពស់ការស្រាវជ្រាវពីបទដ្ឋានគតិយុត្ត និងច្បាប់ ទាំងផ្នែកសារធាតុ និងនីតិវិធី។

# ឯកសារពិគ្រោះ

## ក. រដ្ឋធម្មនុញ្ញ ក្រម និង ច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ បោះពុម្ពឆ្នាំ ២០១៧ ដោយអគ្គលេខាធិការដ្ឋានរដ្ឋសភា
- ច្បាប់ស្តីពីអស្សាមិករណ៍ ដែលប្រកាសឱ្យប្រើដោយប្រមុខរដ្ឋស្តីទី សម្តេច ជា ស៊ីម ក្នុងព្រះបរមនាមនៃព្រះ មហាក្សត្រខ្មែរ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយ ក្រសួងយុត្តិធម៌ ឆ្នាំ២០១១
- ក្រមនីតិវិធិរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ បោះពុម្ពផ្សាយ ដោយក្រសួងយុត្តិធម៌ ឆ្នាំ ២០១២
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បោះពុម្ពផ្សាយដោយ ក្រសួងយុត្តិធម៌ ឆ្នាំ២០១២
- សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី វិភាគទានចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ បោះពុម្ពផ្សាយ ឆ្នាំ ២០០៥
- ច្បាប់ភូមិបាល ឆ្នាំ២០០១
- ច្បាប់ភូមិបាល ឆ្នាំ១៩៩២
- ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣
- អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោក បន្ទាប និងពិធីសារបន្ថែម អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ ១៩៨៤ បកប្រែក្រៅផ្លូវការដោយការិយាល័យឧត្តមស្នងការអង្គការសហ ប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា
- ប្រកាសអន្តរក្រសួងស្តីពី ការកំណត់លក្ខណវិនិច្ឆ័យប្រភេទ និងកម្រិតពិការភាព លេខ២៤៩២ ស អយ/បក ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រសួង សុខាភិបាល

## ខ. សៀវភៅបោះពុម្ព

- នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១៣-២០១៤
- នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០១២
- មេរៀននីតិព្រហ្មទណ្ឌទូទៅ ឯកឧត្តម **ហ៊ី សោភា**
- វចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ គ.ស. ១៩៦៧

- សទ្ទានុក្រមព្រះពុទ្ធសាសនា រៀបរៀង និងប្រែ ដោយ ស៊ីម រតនៈ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ គ.ស. ២០១៣
- សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែកក្រមព្រហ្មទណ្ឌ បោះពុម្ព ផ្សាយដោយ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១
- សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធី រដ្ឋប្បវេណី បោះផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧
- ការសិក្សា ច្បាប់គ្រប់មាត្រា ទាំងអស់ ក្នុង ក្រមព្រហ្មទណ្ឌ របស់ **អេង សុត** គ.ស.១៩៦៤
- មគ្គុទ្ទេសក៍ ស្តីពីនីតិវិធីព្រហ្មទណ្ឌខ្មែរ ការស៊ើបអង្កេត និងការស៊ើបសួរត្រៀម បោះផ្សាយ ឆ្នាំ២០០៥

**គ. គេហទំព័រ និងតំណភ្ជាប់**

- https://www.pheakdeylaw.com/kh/publication/45
- https://lsknan.files.wordpress.com/2012/10/e19e85e19f92e19e94e19eb6e19e94e19f8be19e97e19ebce19e98e19eb7e19e94e19eb6e19e9b-1992.pdf
- http://m.freshnewsasia.com/index.php/en/9039-2015-08-27-04-58-22.html
- https://cambodia.ohchr.org/sites/default/files/Treaty/CAT-KH.pdf
- http://portal.unesco.org/en/ev.php-URL_ID=13039&URL_DO=DO_TOPIC&URL_SECTION=201.html
- http://vh.dccam.org/ការថែរក្សាសម្បត្តិបេតិ/

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** រដ្ឋធម្មនុញ្ញ និង ក្រម

**ឧបសម្ព័ន្ធទី២៖** ច្បាប់ផ្សេងៗ

# ឧបសម្ព័ន្ធទី១៖ រដ្ឋធម្មនុញ្ញ
# និងក្រម

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភា

# អារម្ភកថា

ក្រុមប្រឹក្សាធម្មនុញ្ញគឺជាស្ថាប័នកំពូលមួយ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ព្រមទាំងមានសិទ្ធិពិនិត្យ និងសម្រេច អំពីករណីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ក្រុមប្រឹក្សាធម្មនុញ្ញថ្វាយមតិព្រះមហាក្សត្រ ចំពោះសេចក្តីស្នើសុំវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ។

ដោយយល់ឃើញថា រដ្ឋធម្មនុញ្ញជាច្បាប់កំពូល និង ជាមូលដ្ឋានគតិយុត្តសំខាន់បំផុតសម្រាប់ជាតិ និង ប្រជាពលរដ្ឋខ្មែរ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើការផ្ទៀងផ្ទាត់ និង ចងក្រងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះឡើង ដើម្បីបម្រើសេចក្តីត្រូវការរបស់មន្ត្រីរាជការស៊ីវិល និង យោធិន ជាអ្នកគ្រប់គ្រងរដ្ឋបាលថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ យកទៅគោរពប្រតិបត្តិ ពេលបំពេញការងារតាមវិស័យ ឬ ជំនាញនីមួយៗ ដោយធានាឱ្យស្របតាមរដ្ឋធម្មនុញ្ញ ។

ការរៀបចំចងក្រងរដ្ឋធម្មនុញ្ញនេះ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើការស្រាវជ្រាវរកសំណៅដើមពីមន្ទីររដ្ឋសភា ក្រោយពេលដែលសភាធម្មនុញ្ញបានអនុម័តរួចពីថ្ងៃ អង្គារ ៦ កើត ខែ ភទ្របទ ឆ្នាំរកា បញ្ចស័ក ព.ស ២៥៣៧ ត្រូវនឹងថ្ងៃទី ២១ ខែ កញ្ញា

គ.ស ១៩៩៣ ហើយត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមពីថ្ងៃ សុក្រ ៩ កើត ខែ ភទ្របទ ឆ្នាំរកា ព.ស ២៥៣៧ ត្រូវនឹងថ្ងៃទី ២៤ ខែ កញ្ញា គ.ស ១៩៩៣ ព្រមទាំងរកសំណៅដើមនៃព្រះរាជក្រមទាំងឡាយប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញ ចំនួន ៧ ក្រោយៗមកទៀត ។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញសង្ឃឹមថា ការផ្សព្វផ្សាយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះ ចាត់ទុកជាការរួមចំណែកក្នុងការអនុវត្តនូវយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលអាណត្តិទី៥ នៃរដ្ឋសភា ឱ្យបានជោគជ័យ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥

**អគ្គលេខាធិការ**

**ចាន់ រ៉ាស៊ី**

**មាត្រា ៤៣.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងល័ក្ខខ័ណ្ឌ ដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

**មាត្រា ៤៤.-**

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ស្ថិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌ ។

**មាត្រា ៤៥.-**

ការរើសអើងគ្រប់ប្រភេទ ប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមព្រហ្មទណ្ឌ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា



២០១០

ក្រសួងយុត្តិធម៌

Ministère de la Justice

# ព្រះរាជក្រម

នស/រកម/១១០៩/០២២

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ទោសដែលជាស្ថាពរហើយនោះ ត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។

បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ ។

**មាត្រា ១១.-** សុពលភាពនៃកិច្ចនីតិវិធី

ការអនុវត្តភ្លាមនៃបទប្បញ្ញត្តិថ្មី គ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធី ដែលបានបំពេញស្របតាមបទប្បញ្ញត្តិចាស់ឡើយ ។

## ជំពូកទី ៣
## ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងលំហ
### ផ្នែកទី ១
### បទល្មើសដែលបានប្រព្រឹត្ត ឬ ចាត់ថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១២.-** គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ ដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៣.-** ទីកន្លែងប្រព្រឹត្តបទល្មើស

បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៤.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាដែលមានសញ្ជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ ។

**មាត្រា ១៥.–** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេស

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាបរទេសដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬ ឱ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ ។

**មាត្រា ១៦.–** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងអាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីជាអាកាសយាននោះស្ថិតនៅទីណាក៏ដោយ ។

**មាត្រា ១៧.–** ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះអំពើដែលបានចាប់ផ្ដើមប្រព្រឹត្តនៅកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបដែលជាអ្នកផ្ដើមគំនិត ឬ អ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរវគ្គខាងក្រោមនេះ ត្រូវបានបំពេញ :

-បទល្មើសត្រូវផ្ដន្ទាទោសតាមច្បាប់កម្ពុជា និងតាមច្បាប់បរទេសផង និង

-អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្ដីសម្រេចជាស្ថាពររបស់តុលាការបរទេស ។

**មាត្រា ១៨.–** ការកំណត់បទល្មើសប្រព្រឹត្តដោយនីតិបុគ្គល

ការដាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជា បទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ត្រូវកំណត់ដោយទណ្ឌកម្មដែលទទួលរងដោយរូបវន្តបុគ្គល ។

## ផ្នែកទី ២

## បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១៩.–** បទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ៣៥.—** ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬ ដែលនឹងកើតមាន និង

-គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់ ។

**មាត្រា ៣៦.—** អានុភាពនៃកម្លាំង ឬ ការបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬ ការបង្ខំ ដែលបុគ្គលនេះមិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន ។

**មាត្រា ៣៧.—** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយទេ ។

## ជំពូកទី ៣

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

**មាត្រា ៣៨.—** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។

**មាត្រា ៣៩.—** វិធានការអនុវត្តចំពោះអនីតិជន

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ៥១.–** ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួល ។

**មាត្រា ៥២.–** ផលនៃទោសពិន័យ

ប្រាក់ពិន័យដែលទទួលបាន ត្រូវបង់ចូលថវិការដ្ឋ ។

## ផ្នែកទី ២

## ទោសបន្ថែម

**មាត្រា ៥៣.–** ប្រភេទនៃទោសបន្ថែម

ទោសបន្ថែមរួមមាន :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤-ការល្បូវលិខិតបើកបរ ។

៥-ការហាមឃាត់ចំពោះការស្នាក់នៅ ។

៦-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

៧-ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

៩-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

១០-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

១១-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុ ដែលលំអទីកន្លែងដែល…បទល្មើសត្រូវបានប្រព្រឹត្ត ។

១២-ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

ROYAUME DU CAMBODGE * LE MINISTRE du PALAIS ROYAL *
7/264

១៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

១៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

១៥-ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

១៦-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន ។

១៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

១៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែក អាចបង្កើតទោសបន្ថែមផ្សេងៗទៀត ។

**មាត្រា ៥៤.- លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម**

ទោសបន្ថែម នឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវចោទប្រកាន់ ។

ទោសបន្ថែម អាចប្រកាសក៏បាន មិនប្រកាសក៏បាន ។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់ ។

**មាត្រា ៥៥.- សិទ្ធិពលរដ្ឋដែលអាចដកបាន**

សិទ្ធិពលរដ្ឋដែលអាចដកបានដូចមានចែងក្នុងចំណុច ១ នៃមាត្រា ៥៣(ប្រភេទនៃទោសបន្ថែម) នៃក្រមនេះ រួមមាន :

១-សិទ្ធិបោះឆ្នោត ។

២-សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ។

៣-សិទ្ធិបំពេញការងារជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ ។

៤-សិទ្ធិទទួលការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្តាល ឬជាអាណត្តិគាហករបស់តុលាការ ។

៥-សិទ្ធិទទួល និងពាក់គ្រឿងឥស្សរិយយសទាំងអស់ ។

៦-សិទ្ធិធ្វើជាសាក្សី ដែលទទួលសម្បថនៅមុខតុលាការ ។

នៅក្នុងសិទ្ធិជនរងគ្រោះ ។

### កថាភាគទី ២
### ការស្តីបន្ទោស

**មាត្រា ៧៦.–** របបគតិយុត្តនៃការស្តីបន្ទោស

កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬ ស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌ ទាំងបីដូចតទៅនេះ :

-ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើស បានបញ្ចប់

-ការខូចខាតត្រូវបានជួសជុលរួចហើយ និង

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ ។

## ជំពូកទី ២
## ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស
### ផ្នែកទី ១
### ស្ថានទម្ងន់ទោស
### កថាភាគទី ១
### និយមន័យនៃស្ថានទម្ងន់ទោសដោយឡែកខ្លះៗ

**មាត្រា ៧៧.–** ក្រុមមានការចាត់តាំង

ក្រុមមានការចាត់តាំង គឺជាការប្រមូលផ្តុំដែលបានបង្កើតឡើង ឬ ជាសន្ធិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬ ប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ។

**មាត្រា ៧៨.–** ការគិតទុកជាមុន

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនសកម្មភាពប្រព្រឹត្តបទល្មើស ។

**មាត្រា ៧៩.–** ការបាក់គាស់ទម្លុះទម្លាយ

ការបាក់គាស់ទម្លុះទម្លាយគឺជាអំពើបង្ខំធ្វើឱ្យខូចខាត ឬ បំផ្លិចបំផ្លាញគ្រឿងបិទទ្វារ

ឬ របង ទោះបីមានប្រភេទយ៉ាងណាក៏ដោយ ។

ត្រូវចាត់ទុកដូចជាការកាប់គាស់ទម្លុះទម្លាយ ៖

១-ការប្រើប្រាស់កូនសោក្លែង ។

២-ការប្រើប្រាស់កូនសោដែលបានមកដោយឧបាយកលទុច្ចរិត ។

៣-ការប្រើប្រាស់គ្រប់ឧបករណ៍ ដើម្បីធ្វើឱ្យគ្រឿងបិទមានដំណើរការដោយគ្មានការបង្ខំ ការខូចខាត ឬ ការបំផ្លិចបំផ្លាញទេ ។

**មាត្រា ៨០.-** ការផ្លោះរបងចូល

ការផ្លោះរបងចូល គឺជាអំពើចូលទៅក្នុងទីកន្លែងណាមួយដោយឆ្លងរបង ឬ ដោយចូលតាមទ្វារ ឬ បង្អួច ដែលមិនមែនសម្រាប់ធ្វើជាផ្លូវចូលទេ ។

**មាត្រា ៨១.-** អាវុធ និងវត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ

អាវុធ គឺជាវត្ថុទាំងអស់ដែលធ្វើឡើងដើម្បីសម្លាប់ ឬ ធ្វើឱ្យមានរបួស ។

ត្រូវបានចាត់ទុកដូចជាអាវុធ វត្ថុដទៃទៀត ដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់មនុស្សនៅក្នុងករណីដូចតទៅ ៖

១-វត្ថុត្រូវបានប្រើប្រាស់សម្រាប់សម្លាប់ ធ្វើឱ្យរបួស ឬ គំរាមកំហែង ។

២-វត្ថុមានទីដៅសម្រាប់សម្លាប់ ធ្វើឱ្យមានរបួស ឬ គំរាមកំហែង ។

ការប្រើប្រាស់សត្វដើម្បីសម្លាប់ ធ្វើឱ្យមានរបួស ឬ គំរាមកំហែង ត្រូវចាត់ទុកដូចបានប្រើប្រាស់អាវុធដែរ ។

**មាត្រា ៨២.-** ការពួនស្ទាក់

ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំជនរងគ្រោះនៅទីកន្លែងណាមួយ ក្នុងរយៈពេលមួយរយៈដើម្បីប្រព្រឹត្តបទល្មើស ។

## កថាភាគទី ២

## ការមិនរាងចាល

**មាត្រា ៨៣.-** អានុភាពនៃការមិនរាងចាល

ការមិនរាងចាលមានអានុភាព នាំឱ្យមានការបន្ថែមទម្ងន់អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិម នៅក្នុងលក្ខខណ្ឌដែលមានចែងដោយកថាភាគនេះ ។

តាមអានុភាពនៃការមិនរាងចាល ក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៥ (ប្រាំ) ឆ្នាំ បទល្មើសនៅតែជាបទមជ្ឈិមដដែល ទោះបីជាមានការបន្ថែមទម្ងន់ទោសយ៉ាងណាក៏ដោយ ។

**មាត្រា ៨៧.–** ការមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្ដន្ទាទោសបទមជ្ឈិម

កាលបើបុគ្គលណាមួយ ត្រូវបានផ្ដន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិម ដាក់ពន្ធនាគារស្មើ ឬ លើសពី ៣ (បី) ឆ្នាំ បុគ្គលនេះបានប្រព្រឹត្តបទឧក្រិដ្ឋ នៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ទោសដែលត្រូវផ្ដន្ទាទោសលើបទឧក្រិដ្ឋនេះ ត្រូវបន្ថែមទម្ងន់ ទៅតាមខ្នាតដូចតទៅ :

១-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋមិនលើសពី ២០ (ម្ភៃ) ឆ្នាំ ទេ អតិបរមានេះ ត្រូវទ្វេឡើង ។

២-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋមានរយៈពេល ៣០ (សាមសិប) ឆ្នាំ អតិបរមានៃទោស គឺដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ៨៨.–** ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្ដន្ទាទោសបទមជ្ឈិម

កាលបើបុគ្គលណាមួយ ត្រូវបានផ្ដន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិមណាមួយ បុគ្គលនេះបានប្រព្រឹត្តបទមជ្ឈិមដដែលនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិមថ្មី ត្រូវទ្វេឡើង ។

តាមអានុភាពនៃការមិនរាងចាល ក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៥ (ប្រាំ) ឆ្នាំ បទល្មើសនៅតែជាបទមជ្ឈិមដដែល ទោះបីជាមានការបន្ថែមទម្ងន់ទោសយ៉ាងណាក៏ដោយ ។

**មាត្រា ៨៩.–** ការប្រដូចបទល្មើស ដើម្បីបង្កើតឱ្យមានការមិនរាងចាល

ដើម្បីអនុវត្តបទប្បញ្ញត្តិស្ដីពីការមិនរាងចាល បទលួច បទរំលោភលើទំនុកចិត្ត និងបទឆបោក ត្រូវចាត់ទុកថាជាបទល្មើសដូចគ្នាដដែល ។

បទល្មើសទទួលផលចោរកម្ម ត្រូវប្រដូចជាបទល្មើសដែលជាប្រភពនៃទ្រព្យសម្បត្តិទទួលលាក់បំបាំង ។

បទល្មើសសំអាតប្រាក់ ត្រូវប្រដូចជាបទល្មើសដែលការសំអាតប្រាក់នេះបានសម្រេច ។

ROYAUME DU CAMBODGE
LE MINISTRE du PALAIS ROYAL

**មាត្រា ៩០.–** ការមិនរាងចាល និងកិច្ចនៃការចោទប្រកាន់

ការមិនរាងចាលអាចត្រូវតុលាការជំនុំជម្រះកត់ត្រាទុក និងអាចជាមូលហេតុនៃការបន្ថែមទម្ងន់ទោសដាក់ពន្ធនាគារបាន ប្រសិនបើមានចែងយ៉ាងជាក់លាក់នៅក្នុងលិខិតចោទប្រកាន់ ។

**មាត្រា ៩១.–** ការមិនរាងចាល និងសេចក្តីសម្រេចស្ថាពរ

សេចក្តីសម្រេចត្រូវបានចាត់ទុកថាជាស្ថាពរ កាលណាសេចក្តីសម្រេចនេះ មិនអាចមានផ្លូវតវ៉ាបានទៀតឡើយ ។

ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល ត្រូវគិតគូរតែលើការផ្តន្ទាទោសស្ថាពរខាងបណ្តឹងអាជ្ញាប៉ុណ្ណោះ ។

**មាត្រា ៩២.–** បទប្បញ្ញត្តិដោយឡែក

ការមិនរាងចាលអាចត្រូវកត់ត្រាទុក ទោះបីទោសដែលកើតចេញពីការផ្តន្ទាទោសនោះត្រូវផុតអាជ្ញាយុកាលក៏ដោយ ។

ការមិនរាងចាល មិនអាចត្រូវកត់ត្រាទុកទេ បើទោសដែលកើតចេញពីការផ្តន្ទាទោសស្ថាពរនោះ ត្រូវបានលើកលែងដោយអនុលោមតាមមាត្រា ៩០ ថ្មី (ពីរ) វាក្យខណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២

## ស្ថានសម្រាលទោស

**មាត្រា ៩៣.–** និយមន័យនៃស្ថានសម្រាលទោស

កាលណាកាលៈទេសៈនៃបទល្មើស ឬ បុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ តុលាការអាចសម្រេចឱ្យជនជាប់ចោទបានទទួលនូវស្ថានសម្រាលទោស ។

ស្ថានសម្រាលទោសអាចត្រូវផ្តល់ឱ្យជនជាប់ចោទបានដែរ ទោះបីជាជននោះ ត្រូវបានប្រកាសថា ស្ថិតនៅក្នុងភាពមិនរាងចាលក៏ដោយ ។

**មាត្រា ៩៤.–** អានុភាពនៃស្ថានសម្រាលទោស

កាលណាតុលាការផ្តល់ឱ្យជនជាប់ចោទនូវស្ថានសម្រាលទោស អប្បបរមានៃមូលទោសនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដូចខាងក្រោម :



kel

**មាត្រា ១២៩.–** ការគិតបញ្ចូលរយៈពេលនៃពាក់កណ្ដាលសេរីភាពទៅក្នុងទោស

រយៈពេលនៃពាក់កណ្ដាលសេរីភាព ត្រូវគិតបញ្ចូលទៅក្នុងថិរវេលានៃទោសដែលកំពុងអនុវត្ត ។

**មាត្រា ១៣០.–** ការរៀបចំ និងការលុបចោលនៃរបបពាក់កណ្ដាលសេរីភាព

នៅគ្រប់ពេល តុលាការអាចរៀបចំរយៈពេលនៃពាក់កណ្ដាលសេរីភាព ឬ ក៏លុបចោលនូវរបបពាក់កណ្ដាលសេរីភាព តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ។

តុលាការត្រូវបានទទួលដំណឹងនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១៣១.–** ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មកពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃពាក់កណ្ដាលសេរីភាព ។

## ផ្នែកទី ៦

## ការបែងចែកទោសជាប្រភាគ

**មាត្រា ១៣២.–** លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬ ស្មើនឹង ១ (មួយ) ឆ្នាំ តុលាការអាចសម្រេចថា ទោសនោះត្រូវអនុវត្តជាប្រភាគ ដោយមូលហេតុធ្ងន់ធ្ងរដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬ ជាសង្គម ។

**មាត្រា ១៣៣.–** បែបបទនៃការបែងចែកទោសជាប្រភាគ

ប្រភាគនៃទោសនីមួយៗ មិនត្រូវតិចជាង ១ (មួយ) ខែ ទេ ។ ថិរវេលាសរុបនៃការអនុវត្តទោសមិនអាចលើសពី ២ (ពីរ) ឆ្នាំ ទេ ដោយរាប់បញ្ចូលទាំងការផ្អាកការអនុវត្តទោស ។

តុលាការកំណត់ក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីបែបបទនៃការបែងចែកទោសជាប្រភាគ ។

**មាត្រា ១៣៤.–** ការកែប្រែរបបនៃការបែងចែកទោសជាប្រភាគ

គ្រប់ពេលវេលា តុលាការអាចរៀបចំបែបបទនៃការបែងចែកទោសជាប្រភាគ ... របបនៃការបែងចែកទោសជាប្រភាគ តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ។

## គន្ថីទី ៣

## បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ

## មាតិកាទី ១

## ការយកទ្រព្យសម្បត្តិអ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយទុច្ចរិត

## ជំពូកទី ១

## ការលួច និងបទល្មើសប្រហាក់ប្រហែល

### ផ្នែកទី ១

### ការលួច

**មាត្រា ៣៥៣.–** និយមន័យនៃអំពើលួច

អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬ វត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

**មាត្រា ៣៥៤.–** អំពើលួចថាមពល

ត្រូវចាត់ទុកជាអំពើលួច អំពើប្រើប្រាស់ដោយទុច្ចរិតនូវថាមពល ដែលនាំឱ្យខូចប្រយោជន៍អ្នកដទៃ ។

**មាត្រា ៣៥៥.–** អភ័យឯកសិទ្ធិគ្រួសារ

មិនអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបានទេ :

១-អំពើលួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬបច្ឆាញាតិ ។

២-អំពើលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធ ។

**មាត្រា ៣៥៦.–** ទោសដែលត្រូវអនុវត្ត

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៣៥៧.–** ស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ក្នុងករណី

១-អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើហិង្សា ។

២-អំពើលួចនេះ ប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយ ។

**មាត្រា ៣៥៨.-** ស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬ ពិការភាព

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើហិង្សាដែលនាំឱ្យមានការកាត់អវយវៈ ឬ ពិការភាពជាអចិន្ត្រៃយ៍ ។

**មាត្រា ៣៥៩.-** ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬ អំពើឃោរឃៅ

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើទារុណកម្ម ឬ អំពើឃោរឃៅ ។

**មាត្រា ៣៦០.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

អំពើលួចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើហិង្សា ដែលបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់ ។

**មាត្រា ៣៦១.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៣៦២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែម ដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៥-ការហាមឃាត់ជនជាតិបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៨-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៩-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត ។

១០-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

១១-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១២-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ត្រៀម ឬ ប្រព្រឹត្តបទល្មើស ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៤-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១៥-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៦-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ផ្នែកទី ២

## ការកំហែងយក

**មាត្រា ៣៦៣.–** និយមន័យនៃការកំហែងយក

អំពើកំហែងយក គឺជាអំពើដែលប្រព្រឹត្តដោយការប្រើហិង្សា ការគំរាមកំហែងថានឹងប្រើហិង្សា ឬ ដោយការបង្ខិតបង្ខំ ដើម្បីទទួលបាននូវ :

១-ហត្ថលេខា ឬ ស្នាមម្រាមដៃ ។

២-ការសន្យា ឬ ការបោះបង់ចោលអ្វីមួយ ។

៣-ការបង្ហាញអាថ៌កំបាំងណាមួយ ។

៤-ការប្រគល់មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយ ។

**មាត្រា ៣៦៤.–** ទោសដែលត្រូវអនុវត្ត

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៣៦៥.–** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើអំពើនេះបានប្រព្រឹត្តទៅលើ :

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ ត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬ ពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

**មាត្រា ៣៦៦.–** ស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់អាវុធ

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តដោយមានការប្រើប្រាស់អាវុធ ឬ ដោយការគំរាមកំហែង

ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៣៨៩.–** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៣៩០.–** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងនៅក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ)ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣- ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៣
## ការរំលោភលើទំនុកចិត្ត និងអំពើប្រវ័ញ្ចប្រវ័ញ្ច
## ផ្នែកទី ១
## ការរំលោភលើទំនុកចិត្ត

**មាត្រា ៣៩១.–** និយមន័យនៃការរំលោភលើទំនុកចិត្ត

អំពើរំលោភលើទំនុកចិត្ត គឺជាអំពើកែបំបាត់មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយ ទាំ

ឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឱ្យបុគ្គលនោះ ហើយបុគ្គលនោះ បានយល់ព្រមដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬ យកមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់ ។

**មាត្រា ៣៩២.–** ទោសដែលត្រូវអនុវត្ត

អំពើរំលោភលើទំនុកចិត្ត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៣៩៣.–** បទរំលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬ បុគ្គលផ្សេងទៀត

គ្រប់អភិបាល ឬ អ្នកត្រួតពិនិត្យរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលមូលនិធិ ឬ បុគ្គលដែលត្រូវបានតុលាការជ្រើសតាំងឱ្យធ្វើជំនួសនូវកិច្ចការរបស់អ្នកទាំងនេះ ឬ និយោជិតដែលទទួលអាណត្តិពីនីតិបុគ្គល ដែលប្រព្រឹត្តអំពើណាមួយដែលជាការរំលោភលើទំនុកចិត្ត ក្នុងគោលបំណងទទួលផលប្រយោជន៍ដល់ខ្លួន ឬ តតិយជន ឬ ក្នុងគោលបំណងធ្វើឱ្យខូចខាតដល់នីតិបុគ្គល ហើយបានបណ្តាលឱ្យមានការខូចខាតទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

បទប្បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកជម្រះបញ្ជីរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលមូលនិធិ ឬ បុគ្គលដែលត្រូវបានតុលាការជ្រើសតាំងឱ្យធ្វើជំនួសនូវកិច្ចការរបស់អ្នកជម្រះបញ្ជី បានប្រព្រឹត្តអំពើដូចបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ហើយបានបណ្តាលឱ្យមានការខូចខាតទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ ។

ការប៉ុនប៉ងប្រព្រឹត្តបទល្មើសដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ នឹងត្រូវផ្តន្ទាទោសដូចគ្នាដែរ ។

**មាត្រា ៣៩៤.–** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនល្មើស

អំពើរំលោភលើទំនុកចិត្ត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ក្នុងករណីបើបទល្មើសនេះបានប្រព្រឹត្តឡើង :

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងយុត្តិធម៌

# សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី

## វិភាគទានចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ

# PROJET DE NOUVEAU CODE PENAL

## COMMENTE ET COMPARE

### CONTRIBUTION A L´ETUDE DU DROIT PENAL KHMER



Sous la haute autorité de S.E ANG VONG Vathana , Ministre de la Justice

MICHEL BONNIEU

PHOV SAMPHY
HEL CHAMROEUN
CHAING SINATH
KOEUT RITH
MARION COUVIDAT

2005

# ព្រះរាជាណាចក្រកម្ពុជា

មីសែល បូនីញ៉ើ
ចៅក្រម
ទីប្រឹក្សារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា
ប្រធានគំរោង « គាំទ្រនីតិរដ្ឋ »
សហប្រតិបត្តិការបារាំង

# សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី

## អត្ថាធិប្បាយ និងប្រៀបធៀប

## វិភាគទាន ចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ

ផ្សូវ សំភី

ហ៊ែល ចំរើន

ចាំង ស៊ីណាត

កើត រិទ្ធ

ម៉ារីយ៉ុង គូរីដាត៍

មាត្រា ១៥៨ នៃក្រមឆ្នាំ ១៩៥៥ មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងមាត្រា ១៥៨ នៃក្រមឆ្នាំ ១៩២៨ នេះដែរ ។

បទប្បញ្ញត្តិរបស់អ៊ុនតាក់ ពុំបានលើកមកនិយាយពីការមិនរាងចាលទេ ។

## មាត្រា កម ១២២១-៧ បទល្មើសប្រជុំ ដើម្បីបង្កើត ឱ្យមានការមិនរាងចាល

ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល បទលួចបទរំលោភលើទំនុកចិត្ត និងបទឆបោក ត្រូវចាត់ទុកថាជាបទល្មើសដូចគ្នាដដែល ។

បទល្មើសទទួលផលចោរកម្ម ត្រូវប្រៀបដូចជាបទល្មើស ដែលជាប្រភពនៃទ្រព្យសម្បត្តិដែលទទួលលាក់បំបាំង ។

បទល្មើសសំអាតប្រាក់កខ្វក់ ត្រូវប្រៀបដូចជាបទល្មើស ដែលការសំអាតប្រាក់ក្រខ្វក់នេះបានសម្រេច ។

### សេចក្តីព្រាងក្រមព្រហ្មទណ្ឌ :

ការមិនរាងចាល ក្នុងបទមជ្ឈិមមានលក្ខណៈពិសេស (ចូរមើលមាត្រា កម ១២២១-៦) ។ មាត្រានេះមានកម្មវត្ថុពង្រីក ដែនអនុវត្តនៃការមិនរាងចាលក្នុងបទមជ្ឈិមរហូតដល់ចំនួនកំណត់មួយ នៃបទល្មើសដែលត្រូវបានចាត់ទុកថាប្រហាក់ប្រហែលគ្នា ប៉ុន្តែពុំបានបំលែងការមិនរាងចាលនេះឱ្យទៅជាការមិនរាងចាលទូទៅនោះទេ ។ តាមពិតគេចាត់ទុកថា មានបទល្មើសមជ្ឈិមមួយចំនួនមានលក្ខណៈស្រដៀងគ្នាខ្លាំងណាស់ ហើយដូច្នេះត្រូវតែប្រដូចគ្នាបានជួនកាលតំលៃខាងផ្នែកសង្គម ដែលត្រូវបានរំលោភបំពានមានលក្ខណៈដូចគ្នា (ការលួចរំលោភលើទំនុកចិត្ត ការឆបោក) ជួនកាលបទល្មើសទាំងពីរដែល ប្រដូចគ្នានោះជាប់ទាក់ទងគ្នានិងបង្ហាញថា ទណ្ឌិតពុំបានលើកយកមកពិចារណានូវការព្រមានជាផ្លូវការលើកទីមួយ ដែលធ្វើឡើងដោយតុលាការ តាមរយៈការផ្តន្ទាទោសជាលើកដំបូងទេ (ការទទួលផលចោរកម្ម និងបទល្មើសដែលជាប្រភពនៃទ្រព្យផលចោរកម្ម ។ ការសំអាតប្រាក់កខ្វក់ និងបទល្មើសដែលក្នុងឱកាសប្រព្រឹត្តបទល្មើសនេះ ការសំអាតប្រាក់កខ្វក់ត្រូវបានសំរេចឡើង) ។

### អត្ថបទយោង :

### ប្រភពប្រវត្តិសាស្ត្រកម្ពុជា :

មាត្រា ១៥៩ នៃក្រមឆ្នាំ ១៩២៨ បានធ្វើការប្រដូចបទល្មើសមួយចំនួនសំរាប់បង្កើតឱ្យមានការមិនរាងចាល ។ ដូច្នេះ ហើយបានជាបទល្មើសមជ្ឈិមដែលស្ថិតនៅក្នុងជំពូកតែមួយនៃក្រមនេះ ត្រូវបានគេប្រដូចគ្នា ។ រាល់អំពើហឹង្សាដោយឆន្ទៈ ទោះជាអសមត្ថភាពការងារដែលកើត

មាត្រា ១៥៨ នៃក្រមឆ្នាំ ១៩៥៥ មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងមាត្រា ១៥៨ នៃក្រមឆ្នាំ ១៩២៥ នេះដែរ ។ បទប្បញ្ញត្តិរបស់អ៊ុនតាក់ ពុំបានលើកមកនិយាយពីការមិនរាងចាលទេ ។

## *មាត្រា កម ១២២១-៧ បទល្មើសប្រដូច ដើម្បីបង្កើត ឱ្យមានការមិនរាងចាល*

ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល បទលួចបទរំលោភលើទំនុកចិត្ត និងបទឆបោក ត្រូវចាត់ទុកថាជាបទល្មើសដូចគ្នាដដែល ។

បទល្មើសទទួលផលចោរកម្ម ត្រូវប្រៀបដូចជាបទល្មើស ដែលជាប្រភពនៃទ្រព្យសម្បត្តិដែលទទួលលាក់បំបាំង ។

បទល្មើសសំអាតប្រាក់កខ្វក់ ត្រូវប្រៀបដូចជាបទល្មើស ដែលការសំអាតប្រាក់ក្រខ្វក់នេះបានសម្រេច ។

### សេចក្តីព្រាងក្រមព្រហ្មទណ្ឌ :

ការមិនរាងចាល ក្នុងបទមជ្ឈិមមានលក្ខណៈពិសេស (ចូរមើលមាត្រា កម ១២២១-៦) ។ មាត្រានេះមានកម្មវត្ថុពង្រីក វិជ្ជនអនុវត្តនៃការមិនរាងចាលក្នុងបទមជ្ឈិមរហូតដល់ចំនួនកំណត់មួយ នៃបទល្មើសដែលត្រូវបានចាត់ទុកថាប្រហាក់ប្រហែលគ្នា ប៉ុន្តែពុំបានបំលែងការមិនរាងចាលនេះឱ្យទៅជាការមិនរាងចាលទូទៅនោះទេ ។ តាមពិតគេចាត់ទុកថា មានបទល្មើសមជ្ឈិមមួយចំនួនមានលក្ខណៈស្រដៀងគ្នាខ្លាំងណាស់ ហើយដូច្នេះត្រូវតែប្រដូចគ្នាបានជួនកាលតំលៃខាងផ្នែកសង្គម ដែលត្រូវបានរំលោភបំពានមានលក្ខណៈដូចគ្នា (ការលួចរំលោភលើទំនុកចិត្ត ការឆបោក) ជួនកាលបទល្មើសទាំងពីរដែល ប្រដូចគ្នានោះជាប់ទាក់ទងគ្នានិងបង្ហាញថា ទណ្ឌិតពុំបានលើកយកមកពិចារណានូវការព្រមានជាផ្លូវការលើកទីមួយ ដែលធ្វើឡើងដោយតុលាការ តាមរយៈការផ្តន្ទាទោសជាលើកដំបូងទេ (ការទទួលផលចោរកម្ម និងបទល្មើសដែលជាប្រភពនៃទ្រព្យផលចោរកម្ម ។ ការសំអាតប្រាក់កខ្វក់ និងបទល្មើសដែលក្នុងឱកាសប្រព្រឹត្តបទល្មើសនេះ ការសំអាតប្រាក់កខ្វក់ត្រូវបានសំរេចឡើង) ។

### អត្ថបទយោង :

### ប្រភពប្រវត្តិសាស្ត្រកម្ពុជា :

មាត្រា ១៥៩ នៃក្រមឆ្នាំ ១៩២៥ បានធ្វើការប្រដូចបទល្មើសមួយចំនួនសំរាប់បង្កើតឱ្យមានការមិនរាងចាល ។ ដូច្នេះ ហើយបានជាបទល្មើសមជ្ឈិមដែលស្ថិតនៅក្នុងជំពូកតែមួយនៃក្រមនេះ ត្រូវបានគេប្រដូចគ្នា ។ រាល់អំពើហឹង្សាដោយឆន្ទៈ ទោះជាអសមត្ថភាពការងារដែលកើត

ក្រមនៅឆ្នាំ ១៩២៩ និង១៩៥៥ បានតាំងបទប្បញ្ញត្តិស្ដីពីការលួច នៅត្រង់មាត្រា ៥១៥ នៃក្រម ទាំងនោះ ។ ដូច្នេះការលួច ត្រូវបានឱ្យនិយមន័យថា ជាអំពើនៃការដណ្ដើមយកដោយគ្មានសិទ្ធិ និងដោយទុច្ចរិត «នូវរបស់អ្វីៗដែលមិនមែនជាកម្មសិទ្ធិរបស់ខ្លួន» ។ លើសពីនេះទៅទៀតមាត្រានេះបានប្រមូលផ្ដុំ ការលួច ការរំលោភលើទំនុកចិត្ត និងការឆបោក ទៅក្នុងប្រភេទនៃបទល្មើសទាំងឡាយដែលត្រូវនិគ្រោះដោយទោសដូចគ្នា ហើយដែលបានសម្រេចលទ្ធផលដូចគ្នា ពោលគឺការប៉ះពាល់ដល់កម្មសិទ្ធិអ្នកដទៃ ។ នៅក្នុងក្រមឆ្នាំ ១៩២៩ ជំពូកដែលមានមាត្រា ៥១៥ មានចំណងជើងថា «បទល្មើស ប្រឆាំងទៅលើទ្រព្យសម្បត្តិរបស់បុគ្គលឯកជន» ។ ក្រមនៅឆ្នាំ ១៩៥៥ បានកែប្រែដោយស្រាលៗ នូវចំណងជើងនេះ ឱ្យទៅជា «បទល្មើសប្រឆាំងទៅនឹងភោគទ្រព្យរបស់បុគ្គលឯកជន» ហើយបានបញ្ចូល វាក្យខ័ណ្ឌទី៤ មួយទៀតដែលប្បញ្ញត្តិអំពី ការលួចលក់ ឬការលួចបញ្ចាំអចលនវត្ថុ មានន័យថា អំពើរបស់បុគ្គលម្នាក់ដែលបង្ហាញនូវ «អចលនវត្ថុមួយថាជារបស់ខ្លួន ហើយដែលខ្លួនដឹងថា មិនមែនជាកម្មសិទ្ធិរបស់ខ្លួន ឬក៏បង្ហាញថា អចលនវត្ថុមួយដែលទំនេរ និងរួចផុតពីសិទ្ធិភណ្ឌិកគ្រប់ប្រភេទ ហើយដែលខ្លួនដឹងថា អចលនវត្ថុនេះមានជាប់បន្ទុកផ្សេងៗ ឬមានជាប់ប្រាតិភោគភណ្ឌិក» ។ លើសពីនេះទៅទៀត មាត្រា២១៦ នៃក្រមឆ្នាំ១៩៥៥ បានចែងអំពីការលួចពិសេស មួយគឺការលួចទ្រព្យសម្បត្តិសាសនា ដោយបានឱ្យនិយមន័យ និគ្រោះចំពោះការលួចនេះដូចគ្នា ទៅនឹងការលួចនៃនីតិរូបដែរ ។

បទប្បញ្ញត្តិអន្តរកាលទាំងឡាយ នៅក្នុងសម័យអ៊ុនតាក់ បានចែងទុកនៅក្នុងមាត្រា ៣៤ នូវប្បញ្ញត្តិស្ដីពីការលួចដោយមានស្ថានទម្ងន់ទោសដែលមានចរិតលក្ខណៈគតិយុត្តជាបទឧក្រិដ្ឋ និងនៅក្នុង មាត្រា៤៣ ស្ដីពីការលួចធម្មតា ។

រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បានសំដែងទុកនៅក្នុងមាត្រា ៤៤ ថា «ជនណាក៏ដោយ ទោះជាបុគ្គលក្ដី ជាសមូហភាពក្ដី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ» ហើយ «កម្មសិទ្ធិឯកជនស្របច្បាប់ស្ថិតក្រោមការគាំពារនៃច្បាប់» ។

### *មាត្រា កម ៣១១១-២* *ការលួចថាមពល*

ត្រូវចាត់ទុកជាការលួច អំពើប្រើប្រាស់ដោយទុច្ចរិតនូវថាមពលដែលនាំឱ្យខូចប្រយោជន៍អ្នកដទៃ ។

### សេចក្ដីព្រាងក្រមព្រហ្មទណ្ឌ :

ការដកហូតដោយទុច្ចរិតនូវថាមពល និងមានជាអាទិ៍ ថាមពលអគ្គីសនី ត្រូវចាត់ទុកថា ជាការលួច វៀរលែងតែការដកហូតនេះបានមក បន្ទាប់ពីមានឧបាយកលទុច្ចរិត ដែលករណីនេះជាការឆបោក ។

ការលួចថាមពលអាចយកទៅអនុវត្តចំពោះ នីតិបុគ្គលបានដែរ ។

# ជំពូកទី ២ : ការកំហែងយក

***មាត្រា កម ៣១១២-១*** ***ធាតុផ្សំនៃការកំហែងយក***

ការកំហែងយក គឺជាអំពើដែលប្រព្រឹត្តដោយប្រើហិង្សា កំហែងគំរាមថានឹង ប្រើហិង្សា ឬ ការបង្ខិតបង្ខំ ដើម្បីទទួលបាននូវ :

១- ហត្ថលេខា ។

២- ការសន្យា ឬការបោះបង់ចោល ។

៣- ការបង្ហាញអាថ៌កំបាំង ។

៤- ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ។

## សេចក្តីព្រាងក្រមព្រហ្មទណ្ឌ :

ការកំហែងយកត្រូវតែបែងចែកឱ្យដាច់ស្រលះ ពីការលួចដោយហិង្សា ទោះជាការកំហែងយកនេះ ក៏ជាការយកទ្រព្យសម្បត្តិគេមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដោយទុច្ចរិតដែលអាចកើតចេញពីអំពើហិង្សាក៏ដោយ ។ ពិតណាស់ ផ្ទុយពីការលួច បទល្មើសនេះ តំរូវឱ្យជនរងគ្រោះលះបង់ចោលដោយខ្លួនឯង នូវទ្រព្យសម្បត្តិដែលត្រូវបានគេកំហែងយកដែលជាហេតុបង្កឱ្យ ប៉ះពាល់ដល់បុគ្គលយ៉ាងធ្ងន់ធ្ងរជាងការលួចដោយហិង្សា ។ សញ្ញាណនៃការបង្ខិតបង្ខំអាចមានន័យជា ការបង្ខិតបង្ខំខាង រូបកាយ និង ខាងផ្លូវចិត្ត ។

ដើម្បីយកមកពិចារណា នូវមូលហេតុផ្សេងៗការកំហែងយកក៏ត្រូវបានផ្តន្ទាទោសផងដែរ នៅពេលដែលការកំហែងយក នេះមានបំណងលាតត្រដាងនូវការលាក់សំងាត់ ។

## អត្ថបទយោង :

## ប្រភពប្រវត្តិសាស្ត្រកម្ពុជា :

ថ្វីត្បិតតែ ជាការពិតឥតមន្ទិលសង្ស័យ ដែលថាសកម្មភាពប្រភេទនេះ ត្រូវបានប្រព្រឹត្តឡើងនៅក្នុងសង្គមខ្មែរមែន តែនីតិនិពន្ធខ្មែរដែលបានបែងចែកការលួចជា ៥ ប្រភេទនោះ ហាក់ដូចជាពុំយកមក ពិចារណាទេនូវសម្មតិកម្មនៃការលះបង់ចោល ដោយជនរងគ្រោះខ្លួនឯងនូវទ្រព្យសម្បត្តិរបស់ខ្លួន ដោយហេតុមានហិង្សា ឬមានការគំរាមកំហែងមកលើខ្លួន ។

ក្រមឆ្នាំ ១៩២៨ ត្រង់មាត្រា ៥២២ ដែលត្រូវបានចំលងយកដោយក្រមឆ្នាំ ១៩៥៥ ក៏បានលើកឡើងពីអំពើនៃការកំហែង យកនូវមូលនិធិ និង ការកំហែងគំរាមបែកកេរ្តិ៍ផងដែរ ។

បទបញ្ញត្តិអន្តរកាល នៅក្នុងសម័យអ៊ុនតាក់គ្មានទោសបញ្ញត្តិទាល់តែសោះ ស្តីពីការកំហែងយកនេះ ។

# ជំពូកទី ៣ : ការគំរាមកំហែងហែកកេរ្តិ៍

## *មាត្រា កម ៣១១៣-១* *ធាតុផ្សំនៃការគំរាមកំហែងហែកកេរ្តិ៍*

ការកំហែងគំរាមហែកកេរ្តិ៍ គឺជាអំពើប្រព្រឹត្តដោយកំហែងគំរាមបើកកកាយ ឬទំលាក់កំហុសទៅលើអំពើដែលនាំឱ្យ ប៉ះពាល់ដល់កិត្តិយស ឬការរាប់អាន ដើម្បីទទួលបាននូវ ៖

១- ហត្ថលេខា ។

២- ការសន្យា ឬការបោះបង់ចោល ។

៣- ការបង្ហាញអាថិកំបាំង ។

៤- ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ។

### សេចក្តីព្រាងក្រមព្រហ្មទណ្ឌ :

ការគំរាមកំហែង អាចធ្វើឡើងដោយពាក្យសំដី ឬដោយលាយលក្ខណ៍អក្សរ និង អាចជាអំពើ ទោះជាពិតប្រាកដ ឬមិនពិតប្រាកដក៏ដោយឱ្យតែអំពើនោះមានចរិតបណ្តាលឱ្យប៉ះពាល់ដល់កិត្តិយស ឬ ដល់ការរាប់អាន ។ ដូចគ្នានឹងការកំហែងយកដែរ (មាត្រា កម ៣១១២-១ ខាងលើ) ដែនអនុវត្តនៃ ការគំរាមកំហែងហែកកេរ្តិ៍អាចលាតសន្ធឹងដល់ករណី ដែលមានបំណងណាមួយក្នុងចំណោមបំណងទាំង ៤ គឺជាការលាតត្រដាងនូវការណ៍សម្ងាត់ ។

### អត្ថបទយោង :

### ប្រភពប្រវត្តិសាស្ត្រកម្ពុជា :

គេពុំឃើញមាន នៅក្នុងនីតិកម្មខ្មែរពីបុរាណកាលនូវបទប្បញ្ញត្តិ ដែលមាននិន្នាការទៅរកការនិគ្រោះ ការគំរាមកំហែងហែកកេរ្តិ៍តាមនិយមន័យទំនើបនេះទេ ។ម្យ៉ាងទៀតវាហាក់ដូចជាចំលែកណាស់ដែលថា អំពើរបៀបនេះមិនត្រូវបាននិគ្រោះ នៅក្នុងសង្គមមួយដែលកិត្តិយស និងការរាប់អានបានតាំងជាតំលៃដ៏មានសារសំខាន់ ។

មាត្រា ៣៩ នៃក្រមវិវាទ ក្នុងក្រមកម្ពុជា ភាគទី ២ ទំព័រ ៤៦១ លើកឡើងពីការគំរាមកំហែងធម្មតា ដោយពុំបានបញ្ជាក់ពីបំណងដែលស្វែងរក ។

មាត្រា ៥២២ នៃក្រមឆ្នាំ ១៩២៥ ដែលត្រូវបានចំលងដោយក្រមឆ្នាំ ១៩៥៥ បានតាំងទោសប្បញ្ញត្តិ ដោយពុំប្រើពាក្យថា ការកំហែងគំរាមហែកកេរ្តិ៍ ចំពោះអំពើបង្ខំ ដោយការគំរាមកំហែងដល់បុគ្គលណាម្នាក់ឱ្យបំពេញនូវ កាតព្វកិច្ចមួយ ហើយការគំរាមកំហែងនេះ «អាចធ្វើឡើង ជាលាយលក្ខណ៍អក្សរ ឬដោយពាក្យសំដី និងស្ថិតនៅក្នុង ការហែកកេរ្តិ៍ ឬការទំលាក់កំហុស ដោយថាហេតុនូវអំពើ ពិតប្រាកដ ឬអំពើមិនពិត ដែលមានចរិតធ្វើឱ្យប៉ះពាល់ ដល់កិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ» ។

# មាតិកាទី ៣ : ការរំលោភលើទំនុកចិត្ត និងអំពើប្រហាក់ប្រហែល

## ជំពូកទី ១ : ការរំលោភលើទំនុកចិត្ត

### *មាត្រា កម ៣១៣១-១* *នាតុផ្សំនៃការរំលោភលើទំនុកចិត្ត*

ការរំលោភលើទំនុកចិត្ត គឺជាអំពើកែបំបាត់មូលនិធិតម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយនាំឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ដែលគេបាន ប្រគល់ឱ្យបុគ្គលនោះ ហើយបុគ្គលនោះបានយល់ព្រមដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬយកមូលនិធិតម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់ ។

#### សេចក្ដីព្រាងក្រមព្រហ្មទណ្ឌ :

សេចក្ដីព្រាងក្រមព្រហ្មទណ្ឌថ្មី មិននិគ្រោះគ្រប់ការរំលោភសីលធម៌លើទំនុកចិត្តរបស់តតិយជននោះទេ តែនិគ្រោះចំពោះ តែការកែបំបាត់របស់អ្វីមួយ ដែលតតិយជននោះបានប្រគល់ឱ្យ ដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬទៅធ្វើការប្រើប្រាស់ ជាកំណត់មួយប៉ុណ្ណោះ ។ ទោសប្បញ្ញត្តិនេះ សន្មត ដូច្នេះថា :

ចោរីបានទទួលរបស់ដោយរបៀបស្របច្បាប់

មានអំពើនៃការរំលោភដោយមានចេតនាទុច្ចរិត : នេះគឺជាអំពើនៃការប្រកាន់កិរិយាជាកម្មសិទ្ធិករ ដោយបដិសេធមិន ព្រមប្រគល់សងវិញដោយ អំពើនៃការចាយខ្ជះខ្ជាយ ដោយការយឺតយ៉ាវ ក្នុងការប្រគល់សងវិញនូវវត្ថុនោះ..... ។ល ។

អត្ថបទច្បាប់ មិនតំរូវឱ្យការប្រគល់នូវមូលនិធិដែលត្រូវបានកែបំបាត់ ឬត្រូវបានចាយខ្ជះខ្ជាយ នោះមានប្រភពចេញពីកិច្ចសន្យាមួយប្រភេទដ៏ ជាក់លាក់នោះទេ ។

ដូច្នេះ គ្មានបទល្មើសណាមួយអាចត្រូវបានបង្កើតឡើងទេ ក្នុងករណីដែលគ្មានការទូទាត់សងវិញ នូវទឹកប្រាក់ដែលបានទទួលបន្ទាប់ពីមានកិច្ចសន្យាខ្ចីប្រាក់ ហើយកូនបំណុលក្លាយជាកម្មសិទ្ធិករនៃមូលនិធិ ដែលគេបានប្រគល់ឱ្យខ្លួនឡើយ ។

#### អត្ថបទយោង :

#### ប្រភពប្រវត្តិសាស្ត្រកម្ពុជា :

នៅក្នុងការស្រាវជ្រាវរបស់លោក លើនីតិកម្មវិស័យឧក្រិដ្ឋកម្ម ក្រោមចំណងជើងថា «ការឆបោក និង ការបន្លំផ្សេងទៀត» **អាដេម៉ាឡឺក្លែរ** បានលើកឡើងនូវករណីមួយនៃការរំលោភទំនុកចិត្ត : «ជនណាដែលចាយប្រាក់ដែលមិនមែនជារបស់ខ្លួន តែជាប្រាក់ដែលគេប្រគល់ឱ្យខ្លួនជនណាដែលលក់ទំនិញ ដែលគេបានប្រគល់ភារកិច្ចឱ្យលក់ ហើយបានចាយនូវតំលៃនៃការលក់នេះ ត្រូវចាត់ទុកថាជាកូនបំណុល ។ ជននេះត្រូវតែត្រូវបានធ្វើការវិនិច្ឆ័យសេចក្ដីដោយអនុលោមតាម លក្ខណៈបំណុល ប្រសិនបើជន

# ឧបសម្ព័ន្ធទី២៖ច្បាប់ផ្សេងៗ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលបំណងធានាការគោរពសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងការពារនូវផលិតផលវប្បធម៌ជាស្នាដៃអ្នកនិពន្ធ អ្នកសម្តែង ផលិតករ ហ្វូណូក្រាមនិងអង្គភាពទូរផ្សាយ សំដៅធានាការធ្វើអាជីវកម្មមួយត្រឹមត្រូវ ស្របច្បាប់លើផលិតផលវប្បធម៌ទាំងនោះ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យវប្បធម៌ ។

**មាត្រា ២.–**

ក្នុងន័យនៃច្បាប់នេះ ពាក្យមួយចំនួនដូចខាងក្រោមមានអត្ថន័យដូចតទៅ :

**ក-ស្នាដៃ** ជាផលិតផលខាងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រី កើតចេញពីការច្នៃប្រឌិត បង្កើតឡើងដោយគំនិតប្រាជ្ញា ឬមនោសញ្ចេតនា ។

**ខ-អ្នកនិពន្ធ** ជាជនដែលបង្កើតបានស្នាដៃ ។

**គ-ការសម្តែង** ជាការបញ្ចាញស្នាដៃលើឆាកដូចជារាំ ប្រគំតន្ត្រី ច្រៀង ឬបង្ហាញតាមមធ្យោបាយនិងវិធីផ្សេងៗទៀតនូវស្នាដៃសិល្បៈប្រពៃណី ទំនៀមទម្លាប់ អក្សរសាស្ត្រ ការអប់រំឬវិទ្យាសាស្ត្រ ។

**ឃ-ការសូត្រ** ជាការបញ្ចាញសម្លេងដោយការនិយាយ ការអាននិងការសូត្រនូវស្នាដៃផ្សេងៗ ។

**ង-អ្នកសម្តែង** ជាសិល្បករ អ្នករបាំ តន្ត្រីករ អ្នកចម្រៀង ឬជនដែលធ្វើការសម្តែង ។

**ច-ប្រព័ន្ធទិន្នន័យ** ជាសំណុំព័ត៌មាន អត្ថបទ លេខ ឌីយ៉ាក្រាម ដែលបង្កើតនិងស្រាវជ្រាវដោយប្រព័ន្ធកុំព្យូទ័រ ។

**ឆ-ស្នាដៃសោតទស្សន៍** ជាស្នាដៃបង្កើតឡើងដោយមានរូបភាពតគ្នាជាឈុតៗភ្ជាប់គ្នា បង្កើតបានជាចលនាអាចឱ្យមើលឃើញបាន ទោះបីមានឬពុំមានបញ្ចូលសម្លេង ហើយបើមានបញ្ចូលសម្លេងគឺអាចស្តាប់ឮសូរសម្លេងបាន ។

**ជ-ទូរផ្សាយ** ជាការផ្សាយសម្លេង រូបភាព ឯកសារ ឬសារនានាគ្រប់ប្រ-

ភេទតាមវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាបឬផ្កាយរណប ។

**ឈ-ការផ្សព្វផ្សាយជាសាធារណៈ**: ជាការផ្សាយតាមខ្សែ ឬគ្មានខ្សែក្រៅវង្វង់គ្រួសារនូវរូបភាព ឬសម្លេង ឬរូបភាពជាមួយសម្លេងនៃស្នាដៃណាមួយ ដែលអាចឱ្យសាធារណជនទទួលបាននៅទីកន្លែងដើម ឬទីកន្លែងដទៃទៀត ដោយមិនគិតថា ជននោះទទួលឬមិនទទួលនូវរូបភាព ឬសម្លេងនោះ ក្នុងពេលនិងទីកន្លែងជាមួយគ្នា ឬក្នុងពេលនិងទីកន្លែងខុសគ្នាតាមការជ្រើសរើសផ្ទាល់ខ្លួនរបស់គេ ។

**ញ-ហ្វូណូក្រាម** ជាវត្ថុដែលបានថតបញ្ចូលសម្លេងនៃការសម្តែង ឬសម្លេងផ្សេងៗទៀត ឬនិមិត្តសញ្ញានៃសម្លេង ក្រៅពីទម្រង់នៃការថតបញ្ចូលជាខ្សែភាពយន្ត ឬស្នាដៃសោតទស្សន៍ផ្សេងៗទៀត ។

**ដ-ផលិតករហ្វូណូក្រាម** ជាជនដែលផលិតហ្វូណូក្រាម ដូចមានចែងនៅក្នុងចំណុច **ញ** ។

**ឋ-កម្មវិធីកុំព្យូទ័រ** ជាសំណុំនៃសេចក្តីណែនាំដែលធ្វើឡើងតាមអក្សរ ឬលេខកូដ ឬគំនូសបំព្រួញ ឬតាមទម្រង់ណាមួយជាហេតុធ្វើឱ្យគេបំពេញបាន ឬទទួលបាននូវកិច្ចការ ឬលទ្ធផលពិសេសណាមួយតាមមធ្យោបាយកុំព្យូទ័រ ឬតាមវិធីសាស្ត្រអេឡិចត្រូនិច ដើម្បីបំពេញកិច្ចការពត៌មានបាន កាលណាកម្មវិធីនោះត្រូវបានបញ្ចូលក្នុងកុំព្យូទ័រ ។

**ឌ-ការផលិតឡើងវិញ** ជាការចម្លងទាំងស្រុង ឬភាគខ្លះនៃស្នាដៃ ឬហ្វូណូក្រាម បង្កើតជាផលិតផលចម្លងមួយច្បាប់ ឬច្រើនច្បាប់តាមមធ្យោបាយ ឬទម្រង់ណាមួយគិតបញ្ចូលទាំងស្នាដៃ ឬហ្វូណូក្រាមដែលរក្សាទុកជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នតាមទម្រង់អេឡិចត្រូនិច ។

**ឍ-អង្គភាពទូរផ្សាយ** គឺស្ថានីយវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប ឬផ្កាយរណប ។

**ណ-សិទ្ធិប្រហាក់ប្រហែល** ជាសិទ្ធិអ្នកសម្តែង សិទ្ធិផលិតករហ្វូណូក្រាម និងសិទ្ធិអង្គភាពទូរផ្សាយ ។

បង្កើតស្នាដៃនោះ ។

ស្នាដៃបន្តជាស្នាដៃបង្កើតឡើងផ្អែកតាមស្នាដៃដើម តាមរយៈការបកប្រែ ការយកលំនាំតាមឬការសម្រួល ។

ស្នាដៃសមូហភាពគឺជាស្នាដៃបង្កើតឡើងដោយរូបវន្តបុគ្គលច្រើននាក់ តាមគំនិតផ្តួចផ្តើមរបស់រូបវន្តបុគ្គលម្នាក់ដែលបានធ្វើការបោះពុម្ពផ្សាយក្រោមការដឹកនាំនិងក្នុងនាមរបស់បុគ្គលនោះ ។

**មាត្រា ៧.–**

ស្នាដៃទាំងឡាយ យោងតាមមាត្រា ៣ ដែលត្រូវទទួលបានការការពារក្រោមច្បាប់នេះមាន :

**ក**-សៀវភៅអានគ្រប់ប្រភេទ ឬឯកសារផ្សេងៗទៀតស្តីពីអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រនិងការអប់រំ ។

**ខ**-អត្ថបទបាឋកថា សង្កថា ធម្មទេសនា ការការពារខ្លួនដោយនិយាយ ឬដោយសរសេរនិងស្នាដៃផ្សេងៗទៀត ដែលមានប្រភេទដូចគ្នា ។

**គ**-ស្នាដៃនាដកម្ម ឬនាដកម្ម-តូរ្យតន្ត្រី ។

**ឃ**-ស្នាដៃរបាំសម័យ ឬយកលំនាំតាមស្នាដៃបុរាណ ឬប្រពៃណី ។

**ង**-ការសម្តែងសៀកនិងការសម្តែងកាយវិការ ។

**ច**-ការតែងបទភ្លេងដោយមាន ឬគ្មានទំនុកច្រៀង ។

**ឆ**-ស្នាដៃសោតទស្សន៍ ។

**ជ**-ស្នាដៃជាផ្ទាំងគំនូរ ផ្ទាំងចម្លាក់ រូបចម្លាក់ ឬស្នាដៃផ្សេងៗទៀតខាងសិល្បៈសូនរូបឬសិល្បៈអនុវត្ត ។

**ឈ**-ស្នាដៃថតរូបនិងស្នាដៃទាំងឡាយដែលសម្រេចបានដោយសារមានជំនួយបច្ចេកទេសដូចគ្នានឹងការថតរូប ។

**ញ**-ស្នាដៃស្ថាបត្យកម្ម ។

**ដ**-ផែនទី ប្លង់ គំនូសវាស ឬស្នាដៃស្តែងចេញជារូបដែលទាក់ទងនឹងភូមិសាស្ត្រ ឋានលេខា ឬវិទ្យាសាស្ត្រនានា ។

ច-កម្មវិធីកុំព្យូទ័រនិងគម្រោងឯកសារសមោធានដែលទាក់ទងទៅនឹងកម្មវិធីទាំងនោះ ។

ឆ-ផលិតផលផ្នែកសិប្បកម្ម តម្បាញ ឬម៉ូតសម្លៀកបំពាក់ផ្សេងៗ ។

**មាត្រា ៨.-**

ស្នាដៃបន្តដែលនៅក្នុងនោះមាន ការបកប្រែ ការយកលំនាំតាម ការសម្រួល ការកែច្នៃ ឬការកែលំអស្នាដៃផ្សេងទៀត ឬការចងក្រងជាប្រព័ន្ធទិន្នន័យ ទោះបីជាក្នុងម៉ាស៊ីនដែលអាចអានបាន ឬក៏ជាទម្រង់ផ្សេងទៀត ក៏ត្រូវទទួលបាននូវកិច្ចការពារពីច្បាប់នេះដែរ ។

កិច្ចការពារស្នាដៃណាមួយដែលមានចែងក្នុងវាក្យខ័ណ្ឌខាងលើ មិនធ្វើឱ្យបាត់បង់សិទ្ធិចំពោះកិច្ចការពារស្នាដៃដើមដែលត្រូវបានបញ្ចូល ឬប្រើប្រាស់សម្រាប់ការបង្កើតស្នាដៃថ្មី ។

**មាត្រា ៩.-**

ចំណងជើងនៃស្នាដៃណាមួយដែលបង្ហាញពីលក្ខណៈស្នូលនៃស្នាដៃដើម ចំណងជើងនោះត្រូវទទួលបាននូវកិច្ចការពារពីច្បាប់ដូចគ្នានឹងស្នាដៃនោះដែរ ។

ស្នាដៃមួយ ទោះបីលែងទទួលបាននូវកិច្ចការពារពីច្បាប់តាមមាត្រា ៣០ និងមាត្រា ៣១ នៃច្បាប់នេះក៏ដោយ ក៏គ្មានបុគ្គលណាម្នាក់មានសិទ្ធិប្រើប្រាស់ចំណងជើងនៃស្នាដៃនោះសម្រាប់ធ្វើជាចំណងជើងនៃស្នាដៃមួយផ្សេងទៀត ជាហេតុបង្កឱ្យមានការភ័ន្តច្រឡំ ។

**មាត្រា ១០.-**

ស្នាដៃដែលមិនស្ថិតនៅក្រោមការការពារនៃច្បាប់នេះមាន :

ក-រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យនិងលិខិតបទដ្ឋានផ្លូវការនានា ។

ខ-ប្រកាស សេចក្តីសម្រេច លិខិតបញ្ជាក់ សារាចរណែនាំផ្សេងៗដែលចេញដោយអង្គការរដ្ឋ ។

**មាត្រា ២១.-**

សិទ្ធិបេតិកភណ្ឌជាសិទ្ធិប្រកបអាជីវកម្មរបស់អ្នកនិពន្ធលើទ្រព្យជាស្នាដៃរបស់ខ្លួន តាមរយៈការផលិតឡើងវិញ ការផ្សព្វផ្សាយជាសាធារណៈនិងការបង្កើតស្នាដៃបន្ត ។

លើកលែងតែក្នុងករណីនៃបទប្បញ្ញត្តិចែងក្នុងមាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៧ មាត្រា ២៨ និងមាត្រា ២៩ នៃច្បាប់នេះ អ្នកនិពន្ធមានសិទ្ធិផ្ដាច់មុខធ្វើ ដោយខ្លួនឯងឬអនុញ្ញាតឱ្យគេធ្វើកិច្ចការដូចតទៅ :

**ក**-ការបកប្រែជាភាសាបរទេសនូវស្នាដៃរបស់ខ្លួន ។

**ខ**-ការយកលំនាំតាមឬការកែសម្រួលផ្សេងៗទៀតនៃស្នាដៃ ។

**គ**-ការជួលស្នាដៃច្បាប់ដើម ឬច្បាប់ចម្លងស្នាដៃសោតទស្សន៍ ឬស្នាដៃថតបញ្ចូលជាហ្វូណូក្រាម កម្មវិធីកុំព្យូទ័រ ប្រព័ន្ធទិន្នន័យ ឬស្នាដៃតូរ្យតន្ត្រីជាអក្សរភ្លេង ។

**ឃ**-ការចែកចាយជាសាធារណៈតាមការលក់ ការជួល ឬតាមមធ្យោបាយផ្សេងទៀតនូវច្បាប់ដើម ឬច្បាប់ចម្លងដែលពុំទាន់បានលក់ ឬផ្ទេរកម្មសិទ្ធិ ។

**ង**-ការនាំចូលក្នុងប្រទេសនូវស្នាដៃចម្លងចេញពីស្នាដៃរបស់សាមីខ្លួនដែលជាអ្នកនិពន្ធ ។

**ច**-ការផលិតស្នាដៃឡើងវិញ ។

**ឆ**-ការសម្ដែងស្នាដៃជាសាធារណៈ ។

**ជ**-ការបង្ហាញស្នាដៃជាសាធារណៈ ។

**ឈ**-ការផ្សាយស្នាដៃតាមទូរផ្សាយ ។

**ញ**-ការផ្សព្វផ្សាយស្នាដៃជាសាធារណៈតាមវិធីផ្សេងៗទៀត ។

សិទ្ធិដាក់ជួលដូចមានចែងក្នុងចំណុច **គ** នៃមាត្រានេះ មិនត្រូវអនុវត្តចំពោះការ

ទាំងឡាយនៃកិច្ចសន្យាផ្ទេរសិទ្ធិនោះ ។

## ផ្នែកទី ៨
## ការតម្កល់ និង ការចុះបញ្ជីនៃស្នាដៃ

**មាត្រា ៣៨.–**

រាល់ស្នាដៃទាំងអស់ត្រូវទទួលបាននូវកិច្ចការពារពីច្បាប់នេះជាស្វ័យប្រវត្តិ ។ អ្នកនិពន្ធឬម្ចាស់សិទ្ធិអាចតម្កល់ទុកស្នាដៃនៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

**មាត្រា ៣៩.–**

ការចុះបញ្ជីអាចធ្វើឡើងបានដោយស្ម័គ្រចិត្តនៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។ ការចុះបញ្ជីត្រូវចុះឈ្មោះពិតប្រាកដរបស់អ្នកនិពន្ធ ចុះថ្ងៃ ខែ ឆ្នាំ នៃស្នាដៃដែលបានផ្សព្វផ្សាយជាលើកដំបូង និងចុះថ្ងៃ ខែ ឆ្នាំ នៃការបង្កើតស្នាដៃព្រមទាំងចុះពីសិទ្ធិរបស់អ្នកនិពន្ធ ។

**មាត្រា ៤០.–**

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវចេញវិញ្ញាបនប័ត្រចំពោះស្នាដៃដែលបានចុះបញ្ជី ។ អ្នកស្នើសុំចុះបញ្ជីត្រូវបង់កម្រៃទៅតាមប្រកាសរួមរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី ៣
## សិទ្ធិប្រហាក់ប្រហែល
## ផ្នែកទី ១
## សិទ្ធិអ្នកសម្ដែង

**មាត្រា ៤១.–**

អ្នកសម្ដែងមានសិទ្ធិផ្ដាច់មុខក្នុងការធ្វើដោយផ្ទាល់ឬអនុញ្ញាត :

**ក**-ការផ្សាយតាមទូរផ្សាយនិងការផ្សព្វផ្សាយជាសាធារណៈ នូវការសម្ដែង

របស់ខ្លួន លើកលែងតែការផ្សាយទាំងនោះបានផ្សាយចេញពីហ្វូណូក្រាមស្តីពីការសម្តែងដែលបានអនុញ្ញាតពីអ្នកសម្តែង ឬបានផ្សាយឡើងវិញតាមទូរផ្សាយ ឬបានការអនុញ្ញាតពីអង្គភាពទូរផ្សាយដែលបានផ្សាយមុនគេនូវការសម្តែង ។

ខ-ការថតបញ្ចូលជាហ្វូណូក្រាមនូវការសម្តែងរបស់ខ្លួនដែលមិនទាន់បានថតបញ្ចូលហ្វូណូក្រាម ។

គ-ការផលិតឡើងវិញនូវការសម្តែងដែលបានថតបញ្ចូលជាហ្វូណូក្រាម ។

ឃ-ការចែកចាយជាសាធារណៈតាមការលក់ឬការផ្ទេរកម្មសិទ្ធិនូវហ្វូណូក្រាមច្បាប់ដើមដែលអ្នកសម្តែងពុំទាន់បានអនុញ្ញាតឱ្យធ្វើការចែកចាយ ។

ង-ការដាក់ជួលឬការឱ្យខ្ចីជាសាធារណៈនូវហ្វូណូក្រាមច្បាប់ដើម ឬហ្វូណូក្រាមច្បាប់ចម្លងស្តីពីការសម្តែង ។

បើគ្មានកិច្ចព្រមព្រៀង ផ្ទុយពីនេះ អ្នកសម្តែងមានសិទ្ធិ :

-អនុញ្ញាតចាក់ផ្សាយតាមអង្គភាពទូរផ្សាយណាមួយ ប៉ុន្តែអង្គភាពទូរផ្សាយដទៃទៀតពុំមានសិទ្ធិធ្វើការចាក់ផ្សាយនូវការសម្តែងរបស់ខ្លួនបានទេ

-អនុញ្ញាតចាក់ផ្សាយតាមអង្គភាពទូរផ្សាយណាមួយ ប៉ុន្តែអង្គភាពទូរផ្សាយនោះពុំមានសិទ្ធិថតបញ្ចូលជាហ្វូណូក្រាមនូវការសម្តែងរបស់ខ្លួនទេ ។

**មាត្រា ៤២.–**

ទោះបីមានការផ្ទេរសិទ្ធិបេតិកភណ្ឌរបស់ខ្លួនហើយក៏ដោយ អ្នកសម្តែងនៅមានសិទ្ធិតម្រូវឱ្យគេសរសេរឈ្មោះខ្លួនលើការសម្តែងផ្ទាល់ ឬការសម្តែងដែលបានថតទុក លើកលែងតែក្នុងករណីដែលវិធីប្រើប្រាស់នៃការសម្តែងនោះពុំតម្រូវឱ្យមានការសរសេរឈ្មោះ ។ អ្នកសម្តែងនៅមានសិទ្ធិជំទាស់គ្រប់រូបភាពនៃការបំផ្លើស ការកាត់តខ្លឹមសារខ្លះឬកែប្រែខ្លឹមសារនៃការសម្តែងជាហេតុធ្វើឱ្យខូចកេរ្តិ៍ឈ្មោះអ្នកសម្តែង ។

**មាត្រា ៤៣.–**

អ្នកសម្តែងមិនអាចហាមឃាត់នូវការផលិតឡើងវិញនិងការផ្សព្វផ្សាយជាសាធារណៈស្តីពីការសម្តែងរបស់ខ្លួនបានឡើយ បើការសម្តែងនោះមានលក្ខណៈបន្ទាប់បន្សំនៅក្នុងសាច់រឿងស្នូលរបស់ឈុត ឬស្នាដៃ ឬឯកសារសោតទស្សន៍ ។

## ផ្នែកទី ២

## សិទ្ធិរបស់ផលិតករហ្វូណូក្រាម

**មាត្រា ៤៤.–**

ផលិតករហ្វូណូក្រាមមានសិទ្ធិផ្តាច់មុខក្នុងការថត ឬការផលិតឡើងវិញ ឬការផ្សព្វផ្សាយជាសាធារណៈនូវហ្វូណូក្រាមរបស់ខ្លួន ។

**មាត្រា ៤៥.–**

រាល់ការផលិតឡើងវិញ ការលក់ ការប្តូរ ការជួល ឬការផ្សព្វផ្សាយជាសាធារណៈនូវហ្វូណូក្រាមត្រូវមានការអនុញ្ញាតពីផលិតករហ្វូណូក្រាម ។

ផលិតករហ្វូណូក្រាមមានសិទ្ធិចែកចាយជាសាធារណៈតាមការលក់ ឬការផ្ទេរកម្មសិទ្ធិនូវច្បាប់ដើមឬច្បាប់ចម្លង ក្នុងករណីដែលផលិតករហ្វូណូក្រាមនោះពុំទាន់អនុញ្ញាតឱ្យជនណាម្នាក់ធ្វើការចែកចាយ ។

ផលិតករហ្វូណូក្រាមមានសិទ្ធិនាំចូលនូវច្បាប់ចម្លងនៃហ្វូណូក្រាមរបស់ខ្លួនក្នុងទិសដៅធ្វើការផ្សព្វផ្សាយជាសាធារណៈ ។

## ផ្នែកទី ៣

## សិទ្ធិផលិតករវីដេអូ

**មាត្រា ៤៦.–**

ផលិតករវីដេអូគឺជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានការផ្តួចផ្តើមគំនិតនិងការទទួលខុសត្រូវក្នុងការថតបញ្ចូលតាមបច្ចេកទេសផ្សាយនូវរូបភាពជាឈុតៗដែលមានឬគ្មានសម្លេងដើម្បីផលិតវីដេអូ ។

រាល់ការផលិតឡើងវិញនូវវីដេអូដើម្បីផ្សព្វផ្សាយជាសាធារណៈ លក់ ដូរ ឬជួលចាំបាច់ត្រូវតែមានការអនុញ្ញាតពីផលិតករវីដេអូ ។

ការផ្ទេរសិទ្ធិរបស់ផលិតករវីដេអូដូចមានចែងក្នុងមាត្រានេះ មិនអាចធ្វើឡើងដាច់ដោយឡែកពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិអ្នកសម្តែងដែលបានរួមសហការផលិតជាវីដេអូបានឡើយ ។

ហេតុបាន ។

អ្នកប្តឹងត្រូវតែជួសជុលការខូចខាតដែលបណ្តាលមកពីការឃាត់ទុកទំនិញនោះ ប្រសិនបើបណ្តឹងរបស់ខ្លួនត្រូវបានរកឃើញថាជាបណ្តឹងគ្មានមូលដ្ឋានត្រឹមត្រូវ ។

បទប្បញ្ញត្តិស្តីពីវិធានការតាមមាត់ច្រកព្រំដែននៃច្បាប់ស្តីពី "ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់" ត្រូវយកមកអនុវត្តបន្ថែមក្នុងមាត្រានេះ ។

**មាត្រា ៦៤.–**

ការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធដូចមានកំណត់ក្នុងច្បាប់នេះ តាមរយៈការផលិត ការផលិតឡើងវិញ ឬការសម្តែង ឬការផ្សព្វផ្សាយនូវស្នាដៃដោយប្រើមធ្យោបាយបែបណាក៏ដោយ គឺជាបទល្មើសដែលត្រូវទទួលទោសតាមច្បាប់ ។

បទល្មើសនៃការផលិតឬការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២៥.០០០.០០០(ម្ភៃប្រាំលាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ១២(ដប់ពីរ)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

ការនាំចូលឬនាំចេញនូវផលិតផលបានពីបទល្មើសដែលជាការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ១២ (ដប់ពីរ)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

បទល្មើសនៃការសម្តែង ឬការផ្សព្វផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៣(បី)ខែ ។ ករណីបទល្មើសបានប្រព្រឹត្តច្រើនដង ការផ្តន្ទាទោសត្រូវគុណនឹងចំនួននៃការប្រព្រឹត្ត ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដងនៃទោសពីមុន ។

**មាត្រា ៦៥.–**

ការផលិតឬការផលិតឡើងវិញដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬពីផលិតករហ្វូណូក្រាម ឬពីផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី

៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២៥.០០០.០០០(ម្ភៃប្រាំលាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ១២(ដប់ពីរ)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

ការនាំចូលឬនាំចេញនូវហ្វូណូក្រាម កាសែ្សត ឬកាសែ្សតវីដេអូដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬផលិតករហ្វូណូក្រាម ឬផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៣(បី)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

ការចាក់ផ្សាយតាមទូរផ្សាយដោយគ្មានការអនុញ្ញាតពីអ្នកសម្តែង ឬពីផលិតករហ្វូណូក្រាម ឬពីផលិតករវីដេអូ ឬអង្គភាពទូរផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ឬនិងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៣(បី)ខែ ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

**មាត្រា ៦៦.–**

គ្រប់ករណីដូចមានចែងក្នុងមាត្រា ៦៤ និងមាត្រា ៦៥ នៃច្បាប់នេះ តុលាការមានសមត្ថកិច្ចចេញសេចក្តីសម្រេចដូចតទៅ :

-រឹបអូសមួយភាគឬទាំងស្រុងនូវប្រាក់ចំណូលបានមកពីបទល្មើសនិងឧបករណ៍ដែលដាក់តាំងដោយឡែកសម្រាប់ការប្រព្រឹត្តទៅនូវបទល្មើសនោះ

-បង្គាប់ឱ្យយកឧបករណ៍ឬសម្ភារៈដែលរឹបអូសទៅប្រគល់ជូនម្ចាស់សិទ្ធិអ្នកនិពន្ធ ឬម្ចាស់សិទ្ធិប្រហាក់ប្រហែលដោយមិនទាន់គិតគូរដល់ការសងសោហ៊ុយជម្ងឺចិត្ត

-បង្គាប់ឱ្យបំផ្លាញចោលនូវសម្ភារៈនិងឧបករណ៍ដែលបានពីការរឹបអូស ។

ក្រុមមេធាវី ខេមឡ
CAMLAW GROUP

# ច្បាប់
# ស្តីពី
# ភូមិបាល
# ២០០១

WWW.CAMLAW.COM.KH

ផ្សព្វផ្សាយភក្ដីឡូជី PHEAKDEYLAW.COM.KH

នស/រកម/០៨០១/១៤

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណា-ចក្រកម្ពុជា

# ប្រកាសឱ្យប្រើ

ច្បាប់ភូមិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី ៥ នីតិកាលទី ១ ហើយដែលមាន សេចក្ដីទាំងស្រុងដូចតទៅ :

**មាត្រា ២៥៤.-**

គ្មានករណីណាមួយដែលអនុញ្ញាតឱ្យប្រើប្រាស់កម្លាំងឯកជន ដើម្បីធានាចំពោះការគោរពប័ណ្ណកម្មសិទ្ធិ ឬចំពោះការប្រតិបត្តិសេចក្តីសំរេចរបស់តុលាការក្នុងការបណ្តេញចេញ ឬក្នុងការបង្គាប់ឱ្យចាកចេញបានឡើយ ។ ជនណាដែលប្រើកម្លាំងឯកជនក្នុងហេតុផលនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៣.០០០.០០០ (បីលាន) រៀល ដល់ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ២ (ពីរ) ឆ្នាំ ។

**មាត្រា ២៥៥.-**

ជនណាដែលបានលួចលក់ឬលួចបញ្ចាំអចលនវត្ថុដែលមិនមែនជារបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ដល់ ៣ (បី) ឆ្នាំ ដោយមិនគិតដល់ល្មសនកម្មដែលបណ្តាលមកពីអំពើរបស់ខ្លួន ។

**មាត្រា ២៥៦.-**

កម្មសិទ្ធិករណាដែលបានធ្វើការដាំដុះលើដីរបស់ខ្លួន ឬប្រគល់ដី ឬផ្តល់ដីឱ្យតតិយជនដាំដុះដោយចេតនានូវមុខដំណាំដែលច្បាប់ឬបទបញ្ញាហាមឃាត់ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១៥.០០០.០០០ (ដប់ប្រាំលាន)រៀល ដល់ ៤៥.០០០.០០០ (សែសិបប្រាំលាន) រៀល ឬ/និងផ្តន្ទាទោសដាក់ពន្ធនាគារតាមច្បាប់ជាធរមាន ។

**មាត្រា ២៥៧.-**

សហកម្មសិទ្ធិករអវិភាគដែលធ្វើឱ្យប៉ះពាល់ដល់ចំណែករួមដូចមានចែងក្នុងមាត្រា ១៨០ នៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.៥០០.០០០ (មួយលានប្រាំសែន) រៀលដល់ ៩.០០០.០០០ (ប្រាំបួនលាន) រៀល ។ ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទ្វេដង ។

**មាត្រា ២៥៨.-**

សហកម្មសិទ្ធិករដែលមិនព្រមចូលរួមទទួលបន្ទុកថែទាំចំណែករួមនៃសហកម្មសិទ្ធិខ្លួន ឬមិនគោរពតាមលក្ខខណ្ឌនៃសណ្ដាប់ធ្នាប់សាធារណៈដូចមានចែងក្នុងមាត្រា ១៨៥ នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០(ប្រាំសែន) រៀល ដល់ ៣.០០០.០០០ (បីលាន) រៀល ។

## អនុផ្នែកទី ២ : អំពីការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ

**មាត្រា ២៥៩.-**

ការប៉ះពាល់កម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ៥០.០០០.០០០(ហាសិបលាន) រៀល ឬ/និងផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ។

ចារីត្រូវមានកាតព្វកិច្ចចាកចេញពីទ្រព្យសម្បត្តិសាធារណៈនោះជាបន្ទាន់ ។ ចារីគ្មានសិទ្ធិទារកំរៃអំពីពលកម្មឬការរៀបចំដែលបានធ្វើលើទ្រព្យនោះឡើយ ។

ក្នុងករណីដែលអ្នកកំពុងកាន់កាប់ទ្រព្យសម្បត្តិសាធារណៈ មុនច្បាប់នេះចូលជាធរមាន ហើយមានឯកសារសំអាងនិងបញ្ជាក់ជាក់លាក់ថា ខ្លួនបានទិញពីជនណាម្នាក់ អាចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីអនុវត្តតាមវិធានច្បាប់ចំពោះបុគ្គលដែលបានលក់ទ្រព្យសម្បត្តិសាធារណៈនេះដោយខុសច្បាប់ និងដើម្បីជាប្រយោជន៍របស់ខ្លួនដែលបានរងគ្រោះដោយសារទង្វើនេះ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ជនរងគ្រោះនេះពុំមានសិទ្ធិកាន់កាប់បន្តលើទ្រព្យសម្បត្តិសាធារណៈបានឡើយ ។

**មាត្រា ២៦០.-**

ជនណាដែលបានលើកចេញ ឬរំកិលចេញ ឬបំផ្លាញចោលនូវបង្គោលស៊ីម៉ង់ត៍ដៅចំណុចឋានលេខានិងទីតាំងផ្លាកសញ្ញាសុរិយោដី ត្រូវទទួលការព្រមានពីអាជ្ញាធរមានសមត្ថកិច្ច ។ ក្នុងករណីមិនរាងចាល ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០ (ប្រាំសែន) រៀល ដល់ ៣.០០០.០០០ (បីលាន) ឬ/និងផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ៦ (ប្រាំមួយ) ខែ ដោយមិនគិតដល់ឲ្យសនកម្មដែលបណ្ដាលមកពីអំពើរបស់ខ្លួន ។